# ព្រះអភិធម្ម

## មេរៀនដំបូង



# ពាក្យប្រារព្ធ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងនូវបរមត្ថធម៌ ទ្រង់គង់ពិចារណានូវបដិច្ចសមុប្បាទធម៌ និង ព្រះអភិធម្ម អស់ ៧ សប្តាហ៍ នៅនាសត្តមហាឋាន មានគល់ព្រះពោធិព្រឹក្ស កន្លែងព្រះអង្គត្រាស់ដឹងជាដើម ។

ព្រះបរមសាស្តា បន្ទាប់អំពីព្រះអង្គសម្តែងនូវយមកប្បាដិហារិយ៍នៅជិតខ្លោងទ្វារក្រុងសាវត្ថីរួចហើយ ទ្រង់បានយាងទៅកាន់តាវត្តិង្សទេវលោក ប្រកាសសម្តែងនូវព្រះអភិធម្មប្រោសព្រះពុទ្ធមាតា និង ពួកទេវតាដ៏ច្រើនទៀត ឱ្យតាំងនៅក្នុងអរិយភូមិ ក្នុងពុទ្ធវស្សាទី ៧ ។

ព្រមពេលគ្នាក្នុងវេលា ៣ ខែនោះ ព្រះអង្គទ្រង់និម្មិតនូវព្រះពុទ្ធមួយព្រះអង្គ ទ្រង់អធិដ្ឋានថា ព្រះពុទ្ធនិម្មិតចូរសម្តែងនូវធម៌ឈ្មោះនេះរហូតដល់តថាគតត្រឡប់មកវិញ ។ ចំណែកព្រះអង្គទ្រង់ស្តេចយាងទៅបិណ្ឌបាតនៅឧត្តរកុរុទ្វីប ទ្រង់យាងមកធ្វើភត្តកិច្ចនៅនាដែនដីក្នុងព្រៃហិមពាន្ត ក្បែរអនោតត្តស្រះ ។ ព្រះបរមសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ត្រាស់នូវអភិធម្មកថា ដល់ព្រះសារីបុត្ត ដែលលោកបាននិមន្តទៅថ្វាយបង្គំព្រះអង្គក្នុងព្រៃហិមពាន្តនោះ ដោយព្រះអង្គត្រាស់ថា ម្នាលសារីបុត្ត ថ្ងៃនេះតថាគតសម្តែងធម៌ប៉ុណ្ណេះ អ្នកចូរសម្តែងប្រាប់ដល់ភិក្ខុជាសទ្ធិវិហារិករបស់អ្នក ។

ព្រះបរមសាស្តា ទ្រង់បានត្រាស់សម្តែងនូវព្រះអភិធម្មដល់ព្រះ-សារីបុត្តរួចហើយ ទ្រង់ស្តេចយាងទៅកាន់ទេវលោកវិញ ត្រាស់សម្តែងបន្តអំពីព្រះពុទ្ធនិម្មិត ចំណែកព្រះសារីបុត្ត ក៏បានត្រឡប់ទៅកាន់នគរសង្កស្ស បង្រៀនព្រះអភិធម្មដល់ភិក្ខុ ៥០០ អង្គដែលទើបតែបួស ព្រោះជ្រះថ្លានឹងយមកប្បាដិហារិយ៍របស់ព្រះពុទ្ធអង្គ ភិក្ខុទាំង ៥០០ អង្គនោះសម្រេចព្រះអរហត្តផល ក្នុងពេលព្រះពុទ្ធអង្គទ្រង់យាងចុះពីទេវលោកមកកាន់ដែនសង្កស្ស នៅថ្ងៃ ១៥ កើត ខែអស្សុជ ។

សូមពុទ្ធបរិស័ទ រីករាយជ្រះថ្លាសិក្សាព្រះអភិធម្ម ជាប្រយោជន៍ដល់ការយល់ដឹងនូវ **ធម្ម** តាមសេចក្តីពិត និង ដើម្បីជួយរក្សានូវមរតករបស់ព្រះសម្មាសម្ពុទ្ធ ជាព្រះបរមគ្រូនៃយើង ។

សៀវភៅ **ព្រះអភិធម្ម** មេរៀនដំបូង នេះ មានពន្យល់ធម៌តាមលេខយោង ចាប់ពីទំព័រ ៩៨ ទៅរហូតដល់ចប់ ។

**សូមអនុមោទនាអស្សុជបូជា !**

បាត់ដំបង ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស. ២៥៥៤

**ខ្ញុំព្រះករុណា ខ្ញុំបាទ ម៉ុត សារឧទ្យ**

# មាតិកាធម៌

**លំដាប់មាតិកា** **ទំព័រ**


✶- **ចេតសិក ៥២** ................................ ១

- អញ្ញសមានាចេតសិក ១៣ ........................... ១

- អកុសលចេតសិក ១៤ ................................ ២

- សោភណចេតសិក ២៥ ................................ ៣

✶- **ចិត្ត ៨៩ ឬ ១២១ ដួង** ............................. ៥

- កុសលចិត្ត ៣៧ ដួង ................................ ៥

- អកុសលចិត្ត ១២ ដួង ................................ ៩

- វិបាកចិត្ត ៥២ ដួង ................................ ១២

- កិរិយាចិត្ត ២០ ដួង ................................ ១៧

- ចិត្តមាន ៤ ភូមិ ................................ ១៩

✶- **សង្គហៈ ៦** ................................ ២១

- វេទនាសង្គហៈ ................................ ២១

- ហេតុសង្គហៈ ................................ ២៦

- កិច្ចសង្គហៈ ................................ ៣០

- ទ្វារសង្គហៈ ................................ ៣៣

- អារម្មណសង្គហៈ ........................................ ៣៩

- វត្ថុសង្គហៈ ........................................ ៤១

★- ស្ថានរបស់ចិត្ត ........................................ ៤៣

★- អំពីប្រភេទអារម្មណ៍ ........................................ ៤៨

★- អំពីរូប ........................................ ៤៩

- ចែករូបតាមសមុដ្ឋាន ........................................ ៥០

- កលាបរូប ........................................ ៥១

- ចែករូប ២៨ ជាពីរៗ ........................................ ៥៧

★- អប្បនាជវ័ន ៥៨ ដួង ........................................ ៥៩

★- ចិត្តកើតក្នុងភព ៣០ ជាន់ ........................................ ៦០

- អធិប្បាយចិត្តកើតក្នុងភព ៣០ ជាន់ ............... ៦១

★- សរុបចិត្តក្នុងភពផ្សេងៗ ........................................ ៦៦

★- សរុបចិត្តក្នុងបុគ្គល ៨ ពួក ........................................ ៦៩

★- ចិត្តនិយាម ........................................ ៧៣

★- អភិធម្ម ធម្មសង្គណី តិកមាតិកា ២២ ............ ៧៥

★- ពន្យល់ធម៌តាមលេខយោង ........................................ ៩៨

# ចេតសិក[១] ៥២

| | | | |
|---|---|---|---|
| I ~ | អញ្ញសមានាចេតសិក | ១៣ | ៥២ |
| II ~ | អកុសលចេតសិក | ១៤ | |
| III ~ | សោភណចេតសិក | ២៥ | |

## I ~ អញ្ញសមានាចេតសិក[២] ១៣ គឺ

១~ ផស្សោ : ប៉ះអារម្មណ៍

២~ វេទនា : សោយអារម្មណ៍

៣~ សញ្ញា : សម្គាល់អារម្មណ៍

៤~ ចេតនា : គិតចាត់ចែងអារម្មណ៍

៥~ ឯកគ្គតា : ផ្គងចិត្តឱ្យមានអារម្មណ៍តែមួយ

៦~ ជីវិតិន្ទ្រិយំ : ញុំាងសហជាតធម៌ឱ្យរស់នៅ

៧~ មនសិការោ : ធ្វើទុកក្នុងចិត្ត ។

ចេតសិក ៧ នេះជា សព្វចិត្តសាធារណចេតសិក[៣] ។

### នៅសល់ ៦ ទៀត គឺ

១~ វិតក្កោ : ត្រិះរិះនូវអារម្មណ៍

២~ វិចារោ : ពិចារណានូវអារម្មណ៍

៣. **អធិមោក្ខោ** : ចុះស៊ប់ក្នុងអារម្មណ៍

៤. **វីរិយំ** : ព្យាយាម

៥. **បីតិ** : ឆ្អែតក្នុងកាយក្នុងចិត្ត

៦. **ឆន្ទោ** : បំណងក្នុងអារម្មណ៍ ។

**ចេតសិក ៦** នេះជា **បកិណ្ណកចេតសិក** (៤)

រួមជា **អញ្ញសមានាចេតសិក ១៣** ។

## II . អកុសលចេតសិក (៥) ១៤ គឺ

១. **មោហោ** : វង្វេងក្នុងអារម្មណ៍

២. **អហិរិកំ** : មិនខ្មាសបាប

៣. **អនោត្តប្បំ** : មិនតក់ស្លុតក្នុងបាប

៤. **ឧទ្ធច្ចំ** : រវើរវាយក្នុងអារម្មណ៍

៥. **លោភោ** : ជាប់ជំពាក់ក្នុងអារម្មណ៍

៦. **ទិដ្ឋិ** : ការយល់ខុស

៧. **មានោ** : រឹងត្អឹង

៨. **ទោសោ** : ប្រទូស្តក្នុងអារម្មណ៍

៩. **ឥស្សា** : ច្រណែន

១០. **មច្ឆរិយំ** : កំណាញ់

១១~ កុក្កុច្ចំ : ក្តៅក្រហាយស្តាយក្រោយ

១២~ ថីនំ : រួញរាចំពោះកុសល

១៣~ មិទ្ធំ : ងងុយងោកងក់

១៤~ វិចិកិច្ឆា : សង្ស័យ ។

## III~ សោភណចេតសិក[៦] ២៥ គឺ

១~ សទ្ធា : ជឿកម្មផល

២~ សតិ : រលឹកដឹងខុសត្រូវ

៣~ ហិរិ : ខ្មាសបាប

៤~ ឱត្តប្ប : តក់ស្លុតក្នុងអំពើបាប

៥~ អលោភោ : មិនជាប់ជំពាក់

៦~ អទោសោ : មិនប្រទូស្ត

៧~ តត្រមជ្ឈត្តតា : សម្លឹងកណ្តាល

៨~ កាយបស្សទ្ធិ : ស្ងប់កាយ

៩~ ចិត្តបស្សទ្ធិ : ស្ងប់ចិត្ត

(២នេះបដិបក្ខនឹងឧទ្ធច្ចៈ)

១០~ កាយលហុតា : ស្រាលកាយ

១១~ ចិត្តលហុតា : ស្រាលចិត្ត

(២នេះបដិបក្ខនឹងថីនំ-មិទ្ធំ)

**១២- កាយមុទុតា** : ទន់ភ្លន់កាយ } បដិបក្ខនឹងទិដ្ឋិមានះ
**១៣- ចិត្តមុទុតា** : ទន់ភ្លន់ចិត្ត

**១៤- កាយកម្មញ្ញតា** : កាយគួរដល់ការងារ } បដិបក្ខនឹងនីវរណៈ
**១៥- ចិត្តកម្មញ្ញតា** : ចិត្តគួរដល់ការងារ

**១៦- កាយបាគុញ្ញតា** : កាយស្ទាត់ជំនាញ } បដិបក្ខនឹងអស្សទ្ធា
**១៧- ចិត្តបាគុញ្ញតា** : ចិត្តស្ទាត់ជំនាញ

**១៨- កាយុជុកតា** : កាយត្រឹមត្រូវ } បដិបក្ខនឹងកិលេសជាគ្រឿងវៀចវេរ
**១៩- ចិត្តុជុកតា** : ភាវៈនៃចិត្តត្រង់

ទាំង ១៩ នេះហៅថា **សោភណសាធារណចេតសិក** (៧)។

**២០- សម្មាវាចា** : សម្តីប្រពៃ

**២១- សម្មាកម្មន្តោ** : ការងារប្រពៃ

**២២- សម្មាអាជីវោ** : អាជីវៈប្រពៃ

ទាំង ៣ នេះហៅថា **វិរតិចេតសិក** (៨)។

**២៣- ករុណា** : អាណិត

**២៤- មុទិតា** : ទន់ភ្លន់

ទាំង ២ នេះហៅថា **អប្បមញ្ញាចេតសិក** (៩)។

**២៥- បញ្ញិន្ទ្រិយំ** : ភាវៈជាធំក្នុងការចេះដឹងគឺបញ្ញា។

# ចិត្ត ៨៩ ឬ ១២១ ដួង[១០]

## កុសលចិត្ត ៣៧ ដួង

### I ~ មហាកុសលចិត្ត[១១] ៨ ដួង គឺ

**១~ សោមនស្សសហគតញាណសម្បយុត្តអសង្ខារិក**

**២~ សោមនស្សសហគតញាណសម្បយុត្តសសង្ខារិក**

**ចិត្ត ២ ដួងនេះមានចេតសិក ៣៨ ដូចគ្នា គឺ**

អញ្ញសមានា ១៣ និង សោភណៈ ២៥ ។

**៣~ សោមនស្សសហគតញាណវិប្បយុត្តអសង្ខារិក**

**៤~ សោមនស្សសហគតញាណវិប្បយុត្តសសង្ខារិក**

**ចិត្ត ២ ដួងនេះមានចេតសិក ៣៧ គឺ**

អញ្ញសមានា ១៣ និង សោភណៈ ២៤ (វៀរបញ្ញា) ។

**៥~ ឧបេក្ខាសហគតញាណសម្បយុត្តអសង្ខារិក**

**៦~ ឧបេក្ខាសហគតញាណសម្បយុត្តសសង្ខារិក**

**ចិត្ត ២ ដួងនេះមានចេតសិក ៣៧ គឺ**

អញ្ញសមានា ១២ ( វៀរបីតិ ) និង សោភណៈ ២៥ ។

**៧- ឧបេក្ខាសហគតញាណវិប្បយុត្តអសង្ខារិក**

**៨- ឧបេក្ខាសហគតញាណវិប្បយុត្តសសង្ខារិក**

**ចិត្ត ២ ដួងនេះមានចេតសិក ៣៦ គឺ**

- អញ្ញសមានា ១២ (វៀរបីតិ)

- សោភណៈ ២៤ (វៀរបញ្ញា) ។

## II - រូបាវចរកុសលចិត្ត [១២] ៥ ដួង គឺ

**១- បឋមជ្ឈានមានអង្គ ៥ គឺ វិតក្ក ១ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ។**

**មានចេតសិក ៣៥ គឺ**

អញ្ញសមានា ១៣ និង សោភណៈ ២២ (វៀរវិរតិ ៣) ។

**២- ទុតិយជ្ឈានមានអង្គ ៤ គឺ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ។**

**មានចេតសិក ៣៤ គឺ**

- អញ្ញសមានា ១២ ( វៀរវិតក្ក ១ )

- សោភណៈ ២២ ( វៀរវិរតិ ៣ ) ។

**៣- តតិយជ្ឈានមានអង្គ ៣ គឺ បីតិ ១ សុខ ១ ឯកគ្គតា ១ ។**

**មានចេតសិក ៣៣ គឺ**

- អញ្ញសមានា ១១ ( វៀរវិតក្ក ១ វិចារ ១ )

- សោភណៈ ២២ ( វៀរវិរតិ ៣ ) ។

**៤. ចតុត្ថជ្ឈានមានអង្គ ២ គឺ សុខ ១ ឯកគ្គតា ១ ។**

**មានចេតសិក ៣២ គឺ**

- អញ្ញសមានា ១០ ( វៀរវិតក្ក ១ វិចារ ១ បីតិ ១ )

- សោភណៈ ២២ ( វៀរវិរតិ ៣ )។

**៥. បញ្ចមជ្ឈានមានអង្គ ២ គឺ ឧបេក្ខា ១ ឯកគ្គតា ១ ។**

**មានចេតសិក ៣០ គឺ**

- អញ្ញសមានា ១០ ( វៀរវិតក្ក ១ វិចារ ១ បីតិ ១ )

- សោភណៈ ២០ ( វៀរវិរតិ ៣ អប្បមញ្ញា ២ ) ។

**III . អរូបាវចរកុសលចិត្ត (១៣) ៤ ដួង គឺ**

**អាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ នេវសញ្ញានាសញ្ញាយតនៈ ១ ។**

**ចិត្ត ៤ ដួងនេះមានចេតសិក ៣០ ដូចគ្នា គឺ**

- អញ្ញសមានា ១០ ( វៀរវិតក្ក ១ វិចារ ១ បីតិ ១ )

- សោភណៈ ២០ ( វៀរវិរតិ ៣ អប្បមញ្ញា ២ ) ។

## IV ~ លោកុត្តរកុសលចិត្ត(១៤) ២០ ដួង គឺ

### ១~ បឋមជ្ឈានមគ្គ ៤ មានចេតសិក ៣៦ គឺ

- អញ្ញសមានា ១៣
- សោភណៈ ២៣ ( វៀរអប្បមញ្ញា ២ ) ។

### ២~ ទុតិយជ្ឈានមគ្គ ៤ មានចេតសិក ៣៥ គឺ

- អញ្ញសមានា ១២ ( វៀរវិតក្ក ១ )
- សោភណៈ ២៣ ( វៀរអប្បមញ្ញា ២ ) ។

### ៣~ តតិយជ្ឈានមគ្គ ៤ មានចេតសិក ៣៤ គឺ

- អញ្ញសមានា ១១ ( វៀរវិតក្ក ១ វិចារ ១ )
- សោភណៈ ២៣ ( វៀរអប្បមញ្ញា ២ ) ។

### ៤~ ចតុត្ថជ្ឈានមគ្គ ៤ មានចេតសិក ៣៣ គឺ

- អញ្ញសមានា ១០ ( វៀរវិតក្ក ១ វិចារ ១ បីតិ ១ )
- សោភណៈ ២៣ ( វៀរអប្បមញ្ញា ២ ) ។

### ៥~ បញ្ចមជ្ឈានមគ្គ ៤ មានចេតសិក ៣៣ គឺ

- អញ្ញសមានា ១០ ( វៀរវិតក្ក ១ វិចារ ១ បីតិ ១ )
- សោភណៈ ២៣ ( វៀរអប្បមញ្ញា ២ )។

# សរុបកុសលចិត្ត (ពិស្ដារ)

| | |
|---|---|
| - មហាកុសលចិត្ត ៨ | កុសលចិត្ត ៣៧ ដួង |
| - រូបាវចរកុសលចិត្ត ៥ | |
| - អរូបាវចរកុសលចិត្ត ៤ | |
| - លោកុត្តរកុសលចិត្ត ២០ | |

# អកុសលចិត្ត ១២ ដួង

## I - លោភមូលចិត្ត[១៥] ៨ ដួង គឺ

**១- សោមនស្សសហគតទិដ្ឋិគតសម្បយុត្តអសង្ខារិក**

**មានចេតសិក ១៩ គឺ**

- អញ្ញសមានា ១៣
- មោចតុក: ៤ + លោភ: ១ ទិដ្ឋិ ១ ។

**២- សោមនស្សសហគតទិដ្ឋិគតសម្បយុត្តសសង្ខារិក**

**មានចេតសិក ២១ គឺ**

- អញ្ញសមានា ១៣
- មោចតុក: ៤ + លោភ: ១ ទិដ្ឋិ ១ ថីនំ១ មិទ្ធំ១ ។

**៣- សោមនស្សសហគតទិដ្ឋិគតវិប្បយុត្តអសង្ខារិក**

**មានចេតសិក ១៩ គឺ**

- អញ្ញសមានា ១៣

- មោចតុកៈ ៤ + លោភៈ ១ មានះ ១ ។

**៤. សោមនស្សសហគតទិដ្ឋិគតវិប្បយុត្តសសង្ខារិក**

**មានចេតសិក ២១ គឺ**

- អញ្ញសមានា ១៣

- មោចតុកៈ ៤ + លោភៈ ១ មានះ ១ ថីនំ១ មិទ្ធំ១ ។

**៥. ឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្តអសង្ខារិក**

**មានចេតសិក ១៨ គឺ**

- អញ្ញសមានា ១២ (វៀរបីតិ)

- មោចតុកៈ ៤ + លោភៈ ១ ទិដ្ឋិ ១ ។

**៦. ឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្តសសង្ខារិក**

**មានចេតសិក ២០ គឺ**

- អញ្ញសមានា ១២ (វៀរបីតិ)

- មោចតុកៈ ៤ + លោភៈ ១ ទិដ្ឋិ ១ ថីនំ១ មិទ្ធំ១ ។

**៧. ឧបេក្ខាសហគតទិដ្ឋិគតវិប្បយុត្តអសង្ខារិក**

**មានចេតសិក ១៨ គឺ**

- អញ្ញសមានា ១២ ( វៀរបីតិ )

- មោចតុក: ៤ + លោភ: ១ មានះ ១ ។

**៨. ឧបេក្ខាសហគតទិដ្ឋិគតវិប្បយុត្តសសង្ខារិក**

**មានចេតសិក ២០ គឺ**

- អញ្ញសមានា ១២ ( វៀរបីតិ ១ )

- មោចតុក: ៤ + លោភ: ១ មានះ ១ ថីនំ១ មិទ្ធំ១ ។

**II . ទោសមូលចិត្ត [១៦] ២ ដួង គឺ**

**១. ទោមនស្សសហគតបដិឃសម្បយុត្តអសង្ខារិក**

**មានចេតសិក ២០ គឺ**

- អញ្ញសមានា ១២ ( វៀរបីតិ )

- មោចតុក: ៤ + ទោចតុក: ៤ ។

**២. ទោមនស្សសហគតបដិឃសម្បយុត្តសសង្ខារិក**

**មានចេតសិក ២២ គឺ**

- អញ្ញសមានា ១២ ( វៀរបីតិ )

- មោចតុក: ៤ + ទោចតុក: ៤ + ថីនំ១ មិទ្ធំ១ ។

**III . មោហមូលចិត្ត [១៧] ២ ដួង គឺ**

**១. ឧបេក្ខាសហគតវិចិកិច្ឆាសម្បយុត្ត**

**មានចេតសិក ១៥ គឺ**

- អញ្ញសមានា ១០ ( វៀរបីតិ១ ឆន្ទៈ១ អធិមោក្ខ ១ )

- មោចតុក: ៤ + វិចិកិច្ឆា ១ ។

**២. ឧបេក្ខាសហគតឧទ្ធច្ចសម្បយុត្ត**

**មានចេតសិក ១៥ គឺ**

- អញ្ញសមានា ១១ ( វៀរបីតិ ១ ឆន្ទៈ ១ )

- មោចតុក: ៤ ។

(ចប់អកុសលចិត្ត ១២ ដួង )

## វិបាកចិត្ត ៥២ ដួង

### I . អកុសលវិបាកចិត្ត (១៨) ៧ ដួង គឺ

**១. ឧបេក្ខាសហគតចក្ខុវិញ្ញាណ** ចិត្តឃើញច្បាស់នូវរូបជាអនិដ្ឋារម្មណ៍ ( អារម្មណ៍មិនជាទីគាប់ចិត្ត ) ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ ។**

**២. ឧបេក្ខាសហគតសោតវិញ្ញាណ** ចិត្តឮច្បាស់នូវសំឡេងជាអនិដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ ។**

**៣. ឧបេក្ខាសហគតឃានវិញ្ញាណ** ចិត្តដឹងច្បាស់នូវក្លិនជាអនិដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ ។.**

**៤. ឧបេក្ខាសហគតជិវ្ហាវិញ្ញាណ** ចិត្តដឹងច្បាស់នូវរសជាអនិដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**៥. ទុក្ខសហគតកាយវិញ្ញាណ** ចិត្តដឹងច្បាស់នូវផោដ្ឋព្វៈជាអនិដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**៦. ឧបេក្ខាសហគតសម្បដិច្ឆន្នៈ** ចិត្តទទួលនូវអនិដ្ឋារម្មណ៍ ក្នុងទ្វារទាំង ៥ ។

**មានចេតសិក ១០ គឺ**

សព្វចិត្តសាធារណៈ ៧ + វិតក្ក ១ វិចារ ១ អធិមោក្ខ ១។

**៧. ឧបេក្ខាសហគតមនោវិញ្ញាណ** ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ ក្នុងទ្វារទាំង ៦ និង ក្រៅទ្វារ ៦ ។

**មានចេតសិក ១០ គឺ**

សព្វចិត្តសាធារណៈ ៧ +វិតក្ក ១ វិចារ ១ អធិមោក្ខ ១ ។

## II ~ កុសលវិបាកអហេតុកចិត្ត[១៩] ៨ ដួង គឺ

**១~ ឧបេក្ខាសហគតចក្ខុវិញ្ញាណ** ចិត្តឃើញច្បាស់នូវរូបជាឥដ្ឋារម្មណ៍ ( អារម្មណ៍ជាទីគាប់ចិត្ត )។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**២~ ឧបេក្ខាសហគតសោតវិញ្ញាណ** ចិត្តឮច្បាស់នូវសំឡេងជាឥដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**៣~ ឧបេក្ខាសហគតឃានវិញ្ញាណ** ចិត្តដឹងច្បាស់នូវក្លិនជាឥដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**៤~ ឧបេក្ខាសហគតជិវ្ហាវិញ្ញាណ** ចិត្តដឹងច្បាស់នូវរសជាឥដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**៥~ សុខសហគតកាយវិញ្ញាណ** ចិត្តដឹងច្បាស់នូវផោដ្ឋព្វៈជាឥដ្ឋារម្មណ៍ ។

**សព្វចិត្តសាធារណចេតសិក ៧ កើតជាមួយ។**

**៦. ឧបេក្ខាសហគតសម្បដិច្ឆន្នៈ** ចិត្តទទួលនូវ
ឥដ្ឋារម្មណ៍ ក្នុងទ្វារទាំង៥ ។

**មានចេតសិក ១០ គឺ**

សព្វចិត្តសាធារណៈ ៧ + វិតក្ក ១ វិចារ ១ អធិមោក្ខ ១។

**៧. សោមនស្សសហគតមនោវិញ្ញាណ** ចិត្តពិចារណា
នូវអតិឥដ្ឋារម្មណ៍ ក្នុងទ្វារទាំង ៦ ។

**មានចេតសិក ១១ គឺ**

សព្វចិត្តសាធារណៈ ៧ + វិតក្ក ១ វិចារ ១ អធិមោក្ខ ១
បីតិ ១ ។

**៨. ឧបេក្ខាសហគតមនោវិញ្ញាណ** ចិត្តដឹងច្បាស់នូវ
ឥដ្ឋមជ្ឈត្តារម្មណ៍ក្នុងទ្វារទាំង ៦ និង ក្រៅទ្វារ ៦ ។

**មានចេតសិក ១០ គឺ**

សព្វចិត្តសាធារណៈ ៧ +វិតក្ក ១ វិចារ ១ អធិមោក្ខ ១ ។

## III . មហាវិបាកចិត្ត[២០] ៨ ដួង គឺ

ឈ្មោះចិត្តដូចមហាកុសលដែរ ខុសតែចេតសិកមិនមាន
វិរតិ ៣ និង អប្បមញ្ញា ២ ។

**. មហាវិបាក ទី១ និង ទី២ មានចេតសិក ៣៣ គឺ**

- អញ្ញសមានា ១៣
- សោភណៈ ២០ ( វៀរវិរតិ ៣ និង អប្បមញ្ញា ២ )។

**- មហាវិបាក ទី៣ និង ទី៤ មានចេតសិក ៣២ គឺ**

- អញ្ញសមានា ១៣
- សោភណៈ ១៩ (វៀរវិរតិ ៣ អប្បមញ្ញា ២ និង បញ្ញា )។

**- មហាវិបាក ទី៥ និង ទី៦ មានចេតសិក ៣២ គឺ**

- អញ្ញសមានា ១២ ( វៀរបីតិ )
- សោភណៈ ២០ (វៀរវិរតិ ៣ និង អប្បមញ្ញា ២ ) ។

**- មហាវិបាក ទី៧ និង ទី៨ មានចេតសិក ៣១ គឺ**

- អញ្ញសមានា ១២ ( វៀរបីតិ )
- សោភណៈ ១៩ (វៀរវិរតិ ៣ អប្បមញ្ញា ២ និង បញ្ញា )។

## IV - រូបាវចរវិបាកចិត្ត[២១] ៥ ដួង

មានចេតសិកដូចរូបាវចរកុសលដែរ។

## V - អរូបាវចរវិបាកចិត្ត[២២] ៤ ដួង

មានចេតសិកដូចអរូបាវចរកុសលដែរ។

## VI - លោកុត្តរវិបាកចិត្ត[២៣] ២០ ដួង

មានចេតសិកដូចលោកុត្តរកុសលដែរ។

# វិបាកចិត្ត ៥២ (ពិស្តារ)

- អកុសលវិបាកចិត្ត ៧
- កុសលវិបាកអហេតុកៈ ៨
- មហាវិបាកចិត្ត ៨

} កាមាវចរវិបាក ២៣

- រូបាវចរវិបាកចិត្ត ៥
- អរូបាវចរវិបាកចិត្ត ៤

} មហគ្គតវិបាក ៩

} **លោកិយវិបាក៣២**

- លោកុត្តរវិបាកចិត្ត ២០

(ចប់វិបាកចិត្ត)

*****

# កិរិយាចិត្ត ២០ ដួង

## I- អហេតុកកិរិយា[២៤] ៣ គឺ

**១- ឧបេក្ខាសហគតបញ្ចទ្វារាវជ្ជនចិត្ត[២៥]**

**មានចេតសិក ១០ គឺ**

សព្វចិត្តសាធារណៈ ៧ +វិតក្ក ១ វិចារ ១ អធិមោក្ខ ១ ។

**២- ឧបេក្ខាសហគតមនោទ្វារាវជ្ជនចិត្ត[២៦]**

**មានចេតសិក ១១ គឺ**

- សព្វចិត្តសាធារណៈ ៧
- វិតក្ក ១ វិចារ ១ អធិមោក្ខ ១ វីរិយ ១។

**៣. សោមនស្សសហគតហសិតុប្បាទចិត្ត[២៧]**

**មានចេតសិក ១២ គឺ**

- សព្វចិត្តសាធារណៈ ៧
- វិតក្ក ១ វិចារ ១ អធិមោក្ខ ១ វីរិយ ១ បីតិ ១។

## II. មហាកិរិយាចិត្ត[២៨] ៨ គឺ

ឈ្មោះដូចមហាកុសលចិត្តនិងមហាវិបាកចិត្តដែរ ។

**- មហាកិរិយា ទី១ និង ទី២ មានចេតសិក ៣៥ គឺ**

អញ្ញសមានា ១៣ + សោភណៈ ២២ ( វៀរវិរតិ ៣ )។

**- មហាកិរិយា ទី៣ និង ទី៤ មានចេតសិក ៣៤ គឺ**

អញ្ញសមានា ១៣ + សោភណៈ ២១ (វៀរវិរតិ ៣ និង បញ្ញា )។

**- មហាកិរិយា ទី៥ និង ទី៦ មានចេតសិក ៣៤ គឺ**

អញ្ញសមានា ១២ (វៀរបីតិ ) + សោភណៈ ២២ ( វៀរវិរតិ ៣ ) ។

**- មហាកិរិយា ទី៧ និង ទី៨ មានចេតសិក ៣៣ គឺ**

- អញ្ញសមានា ១២ (វៀរបីតិ )
- សោភណៈ ២១ (វៀរវិរតិ ៣ និង បញ្ញា ) ។

## III. មហគ្គតកិរិយាចិត្ត[២៩] ៩ គឺ

មហគ្គតកុ.វិ.កិ. មានចេតសិកដូចគ្នា តាមលំដាប់ឈាន ។

## សរុបកិរិយាចិត្ត ២០ គឺ

- អហេតុកកិរិយាចិត្ត ៣ ⎫
- មហាកិរិយាចិត្ត ៨ ⎬ កិរិយាចិត្ត ២០ ដួង
- មហគ្គតកិរិយាចិត្ត ៩ ⎭

(ចប់កិរិយាចិត្ត ២០)

## សរុបចិត្តទាំងអស់ ពិស្តារ ១២១ សង្ខេប ៨៩ គឺ

| | | | | |
|---|---|---|---|---|
| - កុសលចិត្ត | ពិស្តារ | ៣៧ | សង្ខេប | ២១ |
| - អកុសលចិត្ត | - | ១២ | - | ១២ |
| - វិបាកចិត្ត | ពិស្តារ | ៥២ | សង្ខេប | ៣៦ |
| - កិរិយាចិត្ត | - | ២០ | - | ២០ |

# ចិត្តមាន ៤ ភូមិ

## I- កាមាវចរចិត្ត[៣០] ៥៤ ដួង គឺ

- មហាកុសលចិត្ត ៨
- អកុសលចិត្ត ១២
- កាមាវចរវិបាក ២៣ ⎫
- អហេតុកកិរិយា ៣ ⎬ អព្យាកតចិត្តជាកាមាវចរ ៣៤
- មហាកិរិយា ៨ ⎭

**II. រូបាវចរចិត្ត[៣១] ១៥ ដួង គឺ**

កុសល ៥ វិបាក ៥ កិរិយា ៥ ។

**III. អរូបាវចរចិត្ត[៣២] ១២ ដួង គឺ**

កុសល ៤ វិបាក ៤ កិរិយា ៤ ។

**IV. លោកុត្តរចិត្ត[៣៣] ៤០ ដួង គឺ**

កុសល ២០ វិបាក ២០ ។

## រួមចិត្តតាមភូមិ ៤ គឺ

- **កាមាវចរចិត្ត ៥៤ គឺ កាមាវចរភូមិ**
- **រូបាវចរចិត្ត ១៥ គឺ រូបាវចរភូមិ**
- **អរូបាវចរចិត្ត ១២ គឺ អរូបាវចរភូមិ**
- **លោកុត្តរចិត្ត ៤០ គឺ លោកុត្តរភូមិ**

**១២១ ដួង**

## សំណួរ

១. កុសលចិត្ត ៣៧ មានប៉ុន្មានភូមិ ?

២. អកុសលចិត្ត ១២ មានប៉ុន្មានភូមិ ?

៣. វិបាកចិត្ត ៥២ មានប៉ុន្មានភូមិ ?

៤. កិរិយាចិត្ត ២០ មានប៉ុន្មានភូមិ ?

# សង្គហៈ ៦

## I- វេទនាសង្គហៈ[៣៤]

១. សុខវេទនាកើតក្នុងចិត្ត ១ គឺ **សុខសហគតកាយវិញ្ញាណ**[៣៥]

២. ទុក្ខវេទនាកើតក្នុងចិត្ត ១ គឺ **ទុក្ខសហគតកាយវិញ្ញាណ**[៣៦]

៣. សោមនស្សវេទនាកើតជាមួយនឹងចិត្ត ៦២ ដួង គឺ

***- សោមនស្សកាមាវចរ ១៨ គឺ**

- **សោមនស្សសន្តីរណៈ ១**[៣៧]
- **សោមនស្សហសិតុប្បាទ ១**[៣៨]
- **សោមនស្សលោភមូល ៤**[៣៩]
- **សោមនស្សមហាកុសល ៤**[៤០]
- **សោមនស្សមហាវិបាក ៤**[៤១]
- **សោមនស្សមហាកិរិយា ៤**[៤២] ។

***- សោមនស្សឈានចិត្ត ៤៤ គឺ**

- **សោមនស្សបឋមជ្ឈាន ១១**[៤៣]
- **សោមនស្សទុតិយជ្ឈាន ១១**[៤៤]

- **សោមនស្សតតិយជ្ឈាន ១១**[៤៥]
- **សោមនស្សចតុត្ថជ្ឈាន ១១**[៤៦] ។

រួមសោមនស្សកាមាវចរ ១៨ និង សោមនស្សឈានចិត្ត ៤៤ ត្រូវជា សោមនស្ស ៦២ ។

៤. ទោមនស្សវេទនា កើតជាមួយនឹងចិត្ត ២ ដួង គឺ

**ទោសមូលចិត្ត ២ ដួង**[៤៧] ។

៥. ឧបេក្ខាវេទនា កើតជាមួយនឹងចិត្ត ៥៥ ដួង គឺ

***- ឧបេក្ខាកាមាវចរ ៣២ គឺ**

- **ឧបេក្ខាអកុសលវិបាក ៦**[៤៨]
- **ឧបេក្ខាកុសលវិបាកអហេតុកៈ ៦**[៤៩]
- **ឧបេក្ខាកិរិយាអហេតុកៈ ២**[៥០]
- **ឧបេក្ខាអកុសល ៦**[៥១]
- **ឧបេក្ខាមហាកុសល ៤**[៥២]
- **ឧបេក្ខាមហាវិបាក ៤**[៥៣]
- **ឧបេក្ខាមហាកិរិយា ៤**[៥៤]

***- ឧបេក្ខាបញ្ចមជ្ឈាន ២៣ គឺ**

- **រូបាវចរបញ្ចមជ្ឈាន ៣**[៥៥]

- **អរូបាវចរបញ្ចមជ្ឈាន ១២**[៥៦]
- **លោកុត្តរបញ្ចមជ្ឈាន ៨**[៥៧]។

រួមឧបេក្ខាកាមាវចរ ៣២ និង ឧបេក្ខាឈានចិត្ត ២៣ ត្រូវជា ឧបេក្ខា ៥៥ ។

## សរុបវេទនា

| | | |
|---|---|---|
| ១. សុខវេទនា | ១ | សរុបវេទនា ១២១ |
| ២. ទុក្ខវេទនា | ១ | |
| ៣. សោមនស្សវេទនា | ៦២ | |
| ៤. ទោមនស្សវេទនា | ២ | |
| ៥. ឧបេក្ខាវេទនា | ៥៥ | |

# តារាងវេទនាសង្គហៈ

I

| សោមនស្ស | កុសលចិត្ត ៣៧ | ឧបេក្ខា |
|---|---|---|
| ៤ | មហាកុសល ៨ | ៤ |
| ៤ | រូបាវចរកុសល ៥ | ១ |
| | អរូបាវចរកុសល ៤ | ៤ |
| ១៦ | លោកុត្តរកុសល ២០ | ៤ |

II

| សោមនស្ស | ទោមនស្ស | អកុសលចិត្ត ១២ | ឧបេក្ខា |
|---|---|---|---|
| ៤ | | លោភៈ ៨ | ៤ |
| | ២ | ទោសៈ ២ | |
| | | មោហៈ ២ | ២ |

## III

| សុខ | ទុក្ខ | វិបាកចិត្ត ៥២ | សោមនស្ស | ឧបេក្ខា |
|---|---|---|---|---|
| | ១ | អកុសលវិបាក ៧ | | ៦ |
| ១ | | កុសលវិបាក ៨ | ១ | ៦ |
| | | មហាវិបាក ៨ | ៤ | ៤ |
| | | រូបាវចរវិបាក ៥ | ៤ | ១ |
| | | អរូបាវចរវិបាក ៤ | | ៤ |
| | | លោកុត្តរវិបាក ២០ | ១៦ | ៤ |

## IV

| សោមនស្ស | កិរិយាចិត្ត ២០ | ឧបេក្ខា |
|---|---|---|
| ១ | អហេតុកកិរិយា ៣ | ២ |
| ៤ | មហាកិរិយា ៨ | ៤ |
| ៤ | មហគ្គតកិរិយា ៩ | ៥ |

## II. **ហេតុសង្គហៈ**[៥៨]

ហេតុមាន ៦ គឺ លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ និង អមោហៈ ( អមោហៈគឺបញ្ញា ) ចេតសិក ៦ នេះ ជាតួ **ហេតុ** (**ហេតូ ធម្មា** )។

**១. អហេតុកចិត្ត ១៨**[៥៩] មិនប្រកបដោយហេតុ គឺ ចេតសិកដែលកើតជាមួយចិត្ត មិនមានចេតសិកជាតួហេតុ ៦ នេះ ទើបហៅថា **អហេតុកចិត្ត** ។

**២. ឯកហេតុកចិត្ត ២ ដួង**[៦០] គឺ **មោហមូលចិត្ត ២ ដួង** ព្រោះក្នុងចេតសិក ១៥ ដែលកើតក្នុងចិត្ត ២ ដួងនេះ មានតែមោហចេតសិកមួយប៉ុណ្ណោះជាតួហេតុ ។

**៣. ទុហេតុកចិត្ត ២២ ដួង**[៦១] គឺ **លោភមូលចិត្ត ៨ ដួង** ប្រកបដោយហេតុ ២ ។ នៅក្នុងចិត្តមួយៗ គ្រប់ទាំង ៨ ដួង មាន **លោភចេតសិក** និង **មោហចេតសិក** ។

**ទោសមូលចិត្ត ២ ដួង**[៦២] ជា **ទុហេតុកចិត្ត** ដែរ ព្រោះក្នុងចិត្តមួយៗ មានហេតុ ២ គឺ **ទោសចេតសិក** និង **មោហចេតសិក** ។

- មហាកុសលញាណវិប្បយុត្ត ៤[៦៣]
- មហាវិបាកញាណវិប្បយុត្ត ៤[៦៤]
- មហាកិរិយាញាណវិប្បយុត្ត ៤[៦៥]

ចិត្ត ១២ ដួងនេះ ក៏ជា **ទុហេតុកចិត្ត** ដែរ គឺក្នុងចិត្តមួយៗ មាន **អលោភចេតសិក** និង **អទោសចេតសិក** ជាហេតុ ២ ។

**រួមទុហេតុកចិត្ត ២២ គឺ**

- **អកុសល = លោភមូលចិត្ត ៨**
- **អកុសល = ទោសមូលចិត្ត ២**
- **កាមាវចរសោភណញាណវិប្បយុត្ត ១២ ៗ**

**៤- តិហេតុកចិត្ត ៤៧ គឺ**

- **កាមាវចរញាណសម្បយុត្តចិត្ត ១២**[៦៦]
- **រូបាវចរចិត្ត ១៥**[៦៧]
- **អរូបាវចរចិត្ត ១២**[៦៨]
- **លោកុត្តរចិត្ត ៨**[៦៩]

ក្នុងចិត្តនីមួយៗ មានចេតសិកហេតុ៣ គឺ : **អលោភ-ចេតសិក អទោសចេតសិក** និង **អមោហចេតសិក** ។

**សរុបចិត្តប្រកបដោយហេតុ និង អត់ហេតុ គឺ**

ឯកហេតុកចិត្ត ២
ទុហេតុកចិត្ត ២២ សហេតុកចិត្ត ៧១
តិហេតុកចិត្ត ៤៧
ត្រូវជាចិត្ត ៨៩។
អហេតុកចិត្ត .................... ១៨

## តារាងហេតុសង្គហៈ

### I

| ទុហេតុកចិត្ត | កុសលចិត្ត ២១ | តិហេតុកចិត្ត |
|---|---|---|
| ៤ | មហាកុសល ៨ | ៤ |
| | មហគ្គតកុសល ៩ | ៩ |
| | លោកុត្តរកុសល ៤ | ៤ |

### II

| ឯកហេតុកចិត្ត | អកុសលចិត្ត ១២ | ទុហេតុកចិត្ត |
|---|---|---|
| | លោភមូល ៨ | ៨ |
| | ទោសមូល ២ | ២ |
| ២ | មោហមូល ២ | |

# III

| អហេតុកចិត្ត | វិបាកចិត្ត ៣៦ | ទុហេតុកចិត្ត | តិហេតុកចិត្ត |
|---|---|---|---|
| ៧ | អកុសលវិបាក ៧ | | |
| ៨ | កុសលវិបាក ៨ | | |
| | មហាវិបាក ៨ | ៤ | ៤ |
| | មហគ្គតវិបាក ៩ | | ៩ |
| | លោកុត្តរវិបាក ៤ | | ៤ |

# IV

| អហេតុកចិត្ត | កិរិយាចិត្ត ២០ | ទុហេតុកចិត្ត | តិហេតុកចិត្ត |
|---|---|---|---|
| ៣ | អហេតុកកិរិយា ៣ | | |
| | មហាកិរិយា ៨ | ៤ | ៤ |
| | មហគ្គតកិរិយា ៩ | | ៩ |

## សំណួរ

១. កាមាវចរ អហេតុកចិត្ត ប៉ុន្មាន ?

២. កាមាវចរ សហេតុកចិត្ត ប៉ុន្មាន ?

៣. កុសល ទុហេតុកចិត្ត ប៉ុន្មាន ?

៤. កាមាវចរ តិហេតុកចិត្ត ប៉ុន្មាន ?

## III. កិច្ចសង្គហៈ[៧០]

**១. បដិសន្ធិកិច្ច**[៧១] មានចិត្ត ១៩ គឺ

**- ឧបេក្ខាសន្តីរណៈ ២ មហាវិបាក ៨ មហគ្គតវិបាក ៩ ។**

**ឧបេក្ខាសន្តីរណៈ** ជាអកុសលវិបាក បដិសន្ធិក្នុងអបាយភូមិ ៤ ។

**ឧបេក្ខាសន្តីរណៈ** ជាកុសលវិបាក បដិសន្ធិក្នុងកាមសុគតិភព ជាមនុស្សនិងទេវតាថ្នាក់ក្រោម ពិការខ្វាក់ខ្វិនជាដើមអំពីកំណើត ។

**មហាវិបាក ៨** បដិសន្ធិក្នុងមនុស្ស ទេវតាដោយបុណ្យច្រើន ។

**មហគ្គតវិបាក** បដិសន្ធិក្នុងព្រហ្មលោកតាមលំដាប់ថ្នាក់ ។

**២. ភវង្គកិច្ច**[៧២] ចិត្ត ១៩ ដួង ដូចបដិសន្ធិ ជាអង្គភព ។

**៣. អាវជ្ជនកិច្ច**[៧៣] កិច្ចរាវរកអារម្មណ៍ មានចិត្ត ២ ដួង។

**៤. ទស្សនកិច្ច**[៧៤] ចក្ខុវិញ្ញាណ ២ ដួង។

**៥. សវនកិច្ច**[៧៥] សោតវិញ្ញាណ ២ ដួង។

**៦. ឃាយនកិច្ច**[៧៦] ឃានវិញ្ញាណ ២ ដួង។

**៧. សាយនកិច្ច**[៧៧] ជិវ្ហាវិញ្ញាណ ២ ដួង។

**៨. ផុស្សនកិច្ច**[៧៨] កាយវិញ្ញាណ ២ ដួង។

**៩. សម្បដិច្ឆន្នកិច្ច**[៧៩] វិបាកមនោធាតុ ២ ដួង។

១០. **សន្តីរណកិច្ច**[៨០] សន្តីរណចិត្ត ៣ ដួង។

១១. **វោដ្ឋព្វនកិច្ច**[៨១] មនោទ្វារាវជ្ជនចិត្ត ១ ដួង។

១២. **ជវនកិច្ច**[៨២] ចិត្ត ៥៥ ដួង គឺ

- **មហាកុសល ៨**
- **អកុសល ១២**
- **មហាកិរិយា ៨**
- **ហសិតុប្បាទ ១**

} **កាមជវន័ ២៩ ដួង**

- **មហគ្គតកុសល ៩**
- **មហគ្គតកិរិយា ៩**
- **លោកុត្តរចិត្ត ៨**

} **អប្បនាជវន័ ២៦ ដួង**

} **៥៥ ដួង ។**

១៣. **តទាលម្ពណកិច្ច**[៨៣] ចិត្ត ១១ ដួង គឺ មហាវិបាក ៨ និង សន្តីរណៈ ៣ ។

១៤. **ចុតិកិច្ច**[៨៤] មានចិត្ត១៩ ដូចបដិសន្ធិ ភវង្គ ដែរ ។

## សរុបចិត្តក្នុងកិច្ចសង្គហៈ[៨៥]

*- ចិត្ត ២ ដួងគឺ **ឧបេក្ខាសន្តីរណៈ ២** ចិត្តពីរដួងនេះ មួយៗ ធ្វើកិច្ច ៥ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច សន្តីរណកិច្ច និង តទាលម្ពណកិច្ច។

*- **មហាវិបាក ៨** ធ្វើកិច្ច ៤ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និង តទាលម្ពណកិច្ច ក្នុងកាមសុគតិភព ៧ ជាន់តែប៉ុណ្ណោះ។

*- **មហគ្គតវិបាក ៩** ធ្វើកិច្ច ៣ គឺបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ក្នុងព្រហ្មលោកតែប៉ុណ្ណោះ។

*- ចិត្ត ២ ធ្វើកិច្ច ពីរ១ គឺ

**មនោទ្វារាវជ្ជនចិត្ត** ធ្វើកិច្ចពីរ គឺ វោដ្ឋព្វនកិច្ច ក្នុងបញ្ចទ្វារ និង អាវជ្ជនកិច្ច ក្នុងមនោទ្វារ។

**សោមនស្សសន្តីរណចិត្ត** ធ្វើកិច្ចពីរ គឺសន្តីរណកិច្ច ក្នុងបញ្ចទ្វារ និង តទាលម្ពណកិច្ច ក្នុងទ្វារ ៦ ។

*- នៅចិត្ត ៦៨ ដួងទៀតធ្វើកិច្ចមួយ១ រៀង១ខ្លួន គឺ **ជវ័ន ៥៥ ដួង ទ្វិបញ្ចវិញ្ញាណ ១០ ដួង និង មនោធាតុ ៣ ដួង។**

- ទ្វិបញ្ចវិញ្ញាណ ១០ គឺ ចក្ខុវិញ្ញាណ ២ ដួង សោត-វិញ្ញាណ ២ ដួង ឃានវិញ្ញាណ ២ ដួង ជិវ្ហាវិញ្ញាណ ២ ដួង និង កាយវិញ្ញាណ ២ ដួង ។

- មនោធាតុ ៣ ដួង គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង និង សម្បដិច្ឆន្នចិត្ត ២ ដួង ។

សរុបចិត្ត ៨៩ ដួង ធ្វើកិច្ច ១៤ ដោយប្រការដូច្នេះឯង ។

## IV. ទ្វារសង្គហៈ[៨៦]

**១. ចក្ខុបសាទ[៨៧]ជាចក្ខុទ្វារ។** មានចិត្ត ៤៦ ដួង កើតតាមចក្ខុទ្វារ គឺ បញ្ចទ្វារាវជ្ជនៈ ១ ដួង ចក្ខុវិញ្ញាណ ២ ដួង សម្បដិច្ឆន្នៈ ២ ដួង សន្តីរណៈ ៣ ដួង វោដ្ឋព្វនៈ ១ ដួង កាមជវ័ន ២៩ ដួង មហាវិបាក ៨ ដួង ។

**២. សោតប្បសាទ[៨៨]ជា សោតទ្វារ**

**៣. ឃានប្បសាទ[៨៩] ជា ឃានទ្វារ**

**៤. ជិវ្ហាបសាទ[៩០] ជា ជិវ្ហាទ្វារ**

**៥. កាយប្បសាទ[៩១] ជា កាយទ្វារ ។**

បញ្ចទ្វារនេះ តែងមានចិត្តក្នុងទ្វារមួយៗ ៤៦ ដួង ប៉ុន្តែសោតទ្វារ មានសោតវិញ្ញាណ ២ ដួង មិនមានចក្ខុវិញ្ញាណទេ ។ ឃានទ្វារមានឃានវិញ្ញាណ ២ ដួង ជិវ្ហាទ្វារមានជិវ្ហាវិញ្ញាណ ២ ដួង និង កាយទ្វារមានកាយវិញ្ញាណ ២ ដួង ។

ចិត្តទាំងអស់តាមបញ្ចទ្វារ មានអារម្មណ៍ជាបច្ចុប្បន្ន ទាំងជាអារម្មណ៍បរមត្ថសុទ្ធៗ មិនមែនមនុស្ស សត្វ ឬ វត្ថុអ្វីទាំងអស់ ។

**៦. មនោទ្វារ**[៩២] គឺ **តទាលម្ពន** (ភវង្គចុងក្រោយ)។

មានចិត្តក្នុងមនោទ្វារ ៦៧ ដួង គឺ មនោទ្វារាវជ្ជនៈ ១ ដួង ជវ័ន ៥៥ ដួង តទាលម្ពណៈ ១១ ដួង ( តទាលម្ពណៈ ១១ គឺ មហាវិបាក ៨ និង សន្តីរណៈ ៣ )។

**៧. ទ្វារវិមុត្តចិត្ត**[៩៣] គឺ ឧបេក្ខាសន្តីរណៈ ២ ដួង មហាវិបាក ៨ ដួង មហគ្គតវិបាក ៩ ដួង។ ចិត្ត ១៩ ដួងនេះ កើតក្រៅទ្វារ ៦ ធ្វើកិច្ច **បដិសន្ធិ ភវង្គ ចុតិ** ។

✶. ចិត្ត ៣៦ ដួងកើតតាមទ្វារមួយ រៀងៗខ្លួន គឺ

- **ទ្វិបញ្ចវិញ្ញាណ ១០**
- **មហគ្គតកុសល ៩**
- **មហគ្គតកិរិយា ៩**
- **លោកុត្តរចិត្ត ៨**

} **ឯកទ្វារិកចិត្ត ៣៦ ដួង**

✶. ចិត្ត ៣ ដួងកើតតែតាមទ្វារ ៥ គឺ

- **បញ្ចទ្វារាវជ្ជនចិត្ត ១**
- **សម្បដិច្ឆន្នចិត្ត ២**

} **បញ្ចទ្វារិកចិត្ត ៣ ដួង**

★- ចិត្ត ៣១ ដួងកើតតាមទ្វារ ៦ គឺ

- **មនោទ្វារាវជ្ជនៈ ១**
- **កាមជវន៍ ២៩**
- **សោមនស្សសន្តីរណៈ ១**

} **ឆទ្វារិកចិត្ត ៣១ ដួង**

★- ចិត្ត ១០ ដួងកើតក្នុងទ្វារ ៦ ផង ក្រៅទ្វារ ៦ ផង គឺ

- **មហាវិបាកចិត្ត ៨**
- **ឧបេក្ខាសន្តីរណៈ ២**

} **ឆទ្វារិកចិត្តផង ទ្វារវិមុត្តចិត្តផង**

★- ចិត្ត ៩ ដួងកើតក្រៅទ្វារ ៦ តែម្យ៉ាង គឺ

- **មហគ្គតវិបាកចិត្ត ៩ ជាទ្វារវិមុត្តចិត្តសុទ្ធ ។**

**ចំណាំ**: បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច គឺ ជាកិច្ចក្រៅទ្វារ ៦ កិច្ច ១១ ទៀត នៅក្នុងទ្វារ រួមត្រូវជាកិច្ចរបស់ចិត្ត ១៤ កិច្ច ។

## សរុបចិត្តតាមទ្វារ

- **ឯកទ្វារិកចិត្ត ៣៦**
- **បញ្ចទ្វារិកចិត្ត ៣**
- **ឆទ្វារិកចិត្ត ៣១**
- **ក្នុងទ្វារ៦ផង ក្រៅទ្វារ៦ផង ១០**
- **ទ្វារវិមុត្តចិត្តសុទ្ធ ៩**

} **ចិត្ត ៨៩ ដួង**

## សំណួរ

១. ចិត្តប៉ុន្មាន មិនដែលកើតក្រៅទ្វារ ?

២. ចិត្តប៉ុន្មាន មិនដែលកើតក្នុងទ្វារ ?

៣. ចិត្តប៉ុន្មាន កើតក្រៅទ្វារផង កើតក្នុងទ្វារផង ?

៤. កាមាវចរចិត្តប៉ុន្មាន អាចកើតតាមមនោទ្វារបាន ?

៥. លោកុត្តរចិត្ត កើតតាមទ្វារណា ?

## ចម្លើយ

១. ចិត្ត ៧០ ដួងមិនដែលកើតក្រៅទ្វារ

២. ចិត្ត ៩ ដួងមិនដែលកើតក្នុងទ្វារ

៣. ចិត្ត ១០ ដួងកើតក្រៅទ្វារផង កើតក្នុងទ្វារផង

៤. កាមាវចរចិត្ត ៤១ ដួងអាចកើតតាមមនោទ្វារបាន

៥. លោកុត្តរចិត្ត កើតតែតាមមនោទ្វារប៉ុណ្ណោះ ។

# I. តារាងវិថីចិត្ត[៩៤]

<table>
<tr><th></th><th>១</th><th>២</th><th>៣</th><th>៤</th><th>៥</th><th>៦</th><th>៧</th><th>សរុប</th></tr>
<tr><td>ចក្ខុ-ទ្វារ</td><td>បញ្ច-ទ្វារាវជ្ជនៈ ១</td><td>ចក្ខុ-វិញ្ញាណ ២</td><td>សម្ប-ដិច្ឆន្នៈ ២</td><td>សន្តី-រណៈ ៣</td><td>វោដ្ឋ-ព្វនៈ ១</td><td>កាម-ជវនៈ ២៩</td><td>តទា-លម្ពណៈ ៨</td><td>៤៦</td></tr>
<tr><td>សោត-ទ្វារ</td><td>១</td><td>សោតវិ. ២</td><td>២</td><td>៣</td><td>១</td><td>២៩</td><td>៨</td><td>៤៦</td></tr>
<tr><td>ឃាន-ទ្វារ</td><td>១</td><td>ឃានវិ. ២</td><td>២</td><td>៣</td><td>១</td><td>២៩</td><td>៨</td><td>៤៦</td></tr>
<tr><td>ជិវ្ហា-ទ្វារ</td><td>១</td><td>ជិវ្ហាវិ. ២</td><td>២</td><td>៣</td><td>១</td><td>២៩</td><td>៨</td><td>៤៦</td></tr>
<tr><td>កាយ-ទ្វារ</td><td>១</td><td>កាយវិ. ២</td><td>២</td><td>៣</td><td>១</td><td>២៩</td><td>៨</td><td>៤៦</td></tr>
<tr><td rowspan="2">មនោ-ទ្វារ</td><td colspan="2">១</td><td colspan="2">២</td><td colspan="3">៣</td><td>សរុប</td></tr>
<tr><td colspan="2">មនោទ្វារាវជ្ជនៈ ១</td><td colspan="2">ជវនៈ ៥៥</td><td colspan="3">តទាលម្ពណៈ ១១</td><td>៦៧</td></tr>
<tr><td>ទ្វារ-វិមុត្តិ</td><td colspan="2">អបាយភូមិ<br>អកុសលវិបាក ១</td><td>កាមសុគតិ<br>អហេតុក-កុសលវិ.១</td><td>មនុ.+ទេ.<br>មហា-វិបាក ៨</td><td colspan="3">ព្រហ្មលោក<br>មហគ្គតវិបាក ៩</td><td>១៩</td></tr>
</table>

# II~ តារាងវិថីចិត្ត[(៩៥)]

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
|---|---|---|---|---|---|---|---|
| ចក្ខុទ្វារ | បញ្ចទ្វារាវជ្ជនៈ ១ | ចក្ខុវិញ្ញាណ ២ | សម្បដិច្ឆនៈ ២ | សន្តីរណៈ ៣ | វោដ្ឋព្វនៈ ១ | កាមជវនៈ ២៩ | តទាលម្ពណៈ ១១ |
| សោតទ្វារ | ១ | សោតវិញ្ញាណ ២ | ២ | ៣ | ១ | ២៩ | ១១ |
| ឃានទ្វារ | ១ | ឃានវិញ្ញាណ ២ | ២ | ៣ | ១ | ២៩ | ១១ |
| ជិវ្ហាទ្វារ | ១ | ជិវ្ហាវិញ្ញាណ ២ | ២ | ៣ | ១ | ២៩ | ១១ |
| កាយទ្វារ | ១ | កាយវិញ្ញាណ ២ | ២ | ៣ | ១ | ២៩ | ១១ |
| មនោទ្វារ | ១ | | ២ | | ៣ | | |
| | មនោទ្វារាវជ្ជនៈ ១ | | ជវនៈ ៥៥ | | តទាលម្ពណៈ ១១ | | |
| ទ្វារវិមុត្តិ | អបាយភូមិ អកុសលវិបាក ១ | | កាមសុ.អហេតុក-កុសលវិ. ១ | មនុស្ស.ទេវតា មហាវិបាក ៨ | ព្រហ្មលោក មហគ្គតវិបាក ៩ | | |

## V. **អារម្មណសង្គហៈ**[៩៦]

១. ចិត្ត ២៥ មាន **កាមាវចរ** ជាអារម្មណ៍ គឺ កាមាវចរវិបាក ២៣ បញ្ចទ្វារាវជ្ជនៈ ១ ហសិតុប្បាទចិត្ត ១[៩៧] ។

២. ចិត្ត ២០ មាន **កាមាវចរ រូបាវចរ អរូបាវចរ** និង **បញ្ញត្តិ** ជាអារម្មណ៍ គឺ អកុសលចិត្ត ១២ មហាកុសលញាណវិប្បយុត្ត ៤ មហាកិរិយាញាណវិប្បយុត្ត ៤[៩៨] ។

៣. ចិត្ត ៥ មាន **អារម្មណ៍ទាំងអស់** វៀរតែអរហត្តមគ្គ និង អរហត្តផល គឺ មហាកុសលញាណសម្បយុត្ត ៤ និង អភិញ្ញាកុសល ១[៩៩] ។

៤. ចិត្ត៦ មាន **អារម្មណ៍ទាំងអស់** គឺមហាកិរិយាញាណសម្បយុត្ត ៤ អភិញ្ញាកិរិយា ១ និង មនោទ្វារាវជ្ជនៈ ១[១០០] ។

៥. ចិត្ត ២១ មាន **បញ្ញត្តិ** ជាអារម្មណ៍គឺ រូបាវចរចិត្ត ១៥ អាកាសានញ្ចាយតនៈ ៣ និង អាកិញ្ចញ្ញាយតនៈ ៣[១០១] ។

៦. ចិត្ត ៦ មាន **មហគ្គតៈ** ជាអារម្មណ៍ គឺ វិញ្ញាណញ្ចាយតនៈ ៣ និង នេវសញ្ញានាសញ្ញាយតនៈ ៣[១០២] ។

៧. លោកុត្តរចិត្ត ៨ មាន **ព្រះនិព្វាន** ជាអារម្មណ៍[១០៣] ។

## សរុបចិត្ត[១០៤]

២៥ +២០ +៥ +៦ +២១ +៦ +៨= ៩១ លើសអភិញ្ញា ២ គឺ បញ្ចមជ្ឈានកុសលអភិញ្ញា ១ និង បញ្ចមជ្ឈានកិរិយាអភិញ្ញា ១ ។

## សំណួរ

១. ចិត្តប៉ុន្មាន មានតែកាមាវចរជាអារម្មណ៍ ?

២. ចិត្តប៉ុន្មាន មានអារម្មណ៍ទាំងអស់ ?

៣. ចិត្តប៉ុន្មាន មានបញ្ញត្តិជាអារម្មណ៍ ?

៤. ចិត្តប៉ុន្មាន មានបរមត្ថជាអារម្មណ៍ ?

៥. ចិត្តប៉ុន្មាន មានកាមាវចរជាអារម្មណ៍ ?

៦. ចិត្តប៉ុន្មាន មាននិព្វានជាអារម្មណ៍ ?

៧. ចិត្តប៉ុន្មាន មិនមានអារម្មណ៍ ?

៨. ចិត្តប៉ុន្មាន មានអារម្មណ៍ខ្លះ មិនមានអារម្មណ៍ខ្លះ ?

៩. ចិត្តប៉ុន្មាន មានតែបញ្ញត្តិជាអារម្មណ៍ ?

១០. ចិត្តប៉ុន្មាន មានតែបរមត្ថជាអារម្មណ៍ ?

## VI. វត្ថុសង្គហៈ[១០៥]

១. ចក្ខុវិញ្ញាណ ២ ដួង អាស្រ័យ **ចក្ខុវត្ថុ**[១០៦]

២. សោតវិញ្ញាណ ២ ដួង អាស្រ័យ **សោតវត្ថុ**[១០៧]

៣. ឃានវិញ្ញាណ ២ ដួង អាស្រ័យ **ឃានវត្ថុ**[១០៨]

៤. ជិវ្ហាវិញ្ញាណ ២ ដួង អាស្រ័យ **ជិវ្ហាវត្ថុ**[១០៩]

៥. កាយវិញ្ញាណ ២ ដួង អាស្រ័យ **កាយវត្ថុ**[១១០]

៦. មនោធាតុ ៣ ដួង អាស្រ័យ **ហទយវត្ថុ**[១១១]

៧. មនោវិញ្ញាណធាតុ ៣០ ដួង គឺ រូបាវចរចិត្ត ១៥ តទាលម្ពណចិត្ត ១១ ទោសចិត្ត ២ ហសិតុប្បាទចិត្ត ១ និង សោតាបត្តិមគ្គ ១។ ចិត្ត ៣០ ដួងនេះអាស្រ័យ **ហទយវត្ថុ**[១១២] ។

៨. ចិត្ត ៤២ ដួង ក៏ជាមនោវិញ្ញាណធាតុដែរ គឺ មហាកុសលចិត្ត ៨ អរូបាវចរកុសលចិត្ត ៤ លោកុត្តរកុសលចិត្ត ៣ (វៀរសោតាបត្តិមគ្គ ) លោភមូលចិត្ត ៨ មោហមូលចិត្ត ២ លោកុត្តរវិបាកចិត្ត ៤ មនោទ្វារាវជ្ជនចិត្ត ១ មហាកិរិយាចិត្ត ៨ និង អរូបាវចរកិរិយាចិត្ត ៤ ។ ចិត្ត ៤២ ដួងនេះសរុបតាមជាតិ គឺ

- កុសលចិត្ត ១៥ ដួង
- អកុសលចិត្ត ១០ ដួង
- វិបាកចិត្ត ៤ ដួង
- កិរិយាចិត្ត ១៣ ដួង

} ៤២ ដួង។

ចិត្ត ៤២ ដួងនេះក្នុងបញ្ចវោការភព គឺភពដែលមានខន្ធ ៥ អាស្រ័យ **ហទយវត្ថុ** បើនៅក្នុងចតុវោការភព គឺភពដែលមានខន្ធ ៤ មិនអាស្រ័យ **វត្ថុរូប** ឡើយ[១១៣] ។

៩. អរូបាវចរវិបាកចិត្ត ៤ ដួងមិនអាស្រ័យ **វត្ថុរូប**ទេ[១១៤]។

## សំណួរទូទៅ

១. បញ្ចទ្វារាវជ្ជនចិត្ត ជាតិអ្វី ភូមិអ្វី ?

២. បញ្ចវិញ្ញាណចិត្ត ជាតិអ្វី ភូមិអ្វី ?

៣. សម្បដិច្ឆន្នចិត្ត ជាតិអ្វី ភូមិអ្វី ?

៤. សន្តីរណចិត្ត ជាតិអ្វី ភូមិអ្វី ?

៥. វោដ្ឋព្វនចិត្ត ជាតិអ្វី ភូមិអ្វី ?

៦. កាមជវនចិត្ត ជាតិអ្វី ភូមិអ្វី ?

៧. តទាលម្ពណចិត្ត ជាតិអ្វី ភូមិអ្វី ?

៨. មនោទ្វារាវជ្ជនចិត្ត ជាតិអ្វី ភូមិអ្វី ?

៩. ជវនចិត្ត ៥៥ ដួង ជាតិអ្វី ភូមិអ្វី ?

១០. ទ្វារវិមុត្តចិត្ត ១៩ ជាតិអ្វី ភូមិអ្វី ?

១១. ហទយវត្ថុ ជាទីអាស្រ័យនៃចិត្តប៉ុន្មាន ?

១២. ចិត្តប៉ុន្មានលុះត្រាតែអាស្រ័យ **ហទយវត្ថុ** ទើបកើតឡើងបាន ?

១៣. វត្ថុរូបប៉ុន្មានជាទីអាស្រ័យនៃចិត្តបានតែចិត្ត ២ ដួង ?

១៤. វត្ថុ ៦ និង ទ្វារ ៦ ជារូប ឬ ជានាម ?

## ស្ថានរបស់ចិត្ត(១១៥)

**ដោយសង្ខេប ១០ ដោយពិស្តារ ២៥**

| | | | |
|---|---|---|---|
| ១. | **បដិសន្ធិស្ថាន** | **មាន ១** | **កន្លែង** |
| ២. | **ភវង្គស្ថាន** | **ពិស្តារ ៦** | **កន្លែង** |
| ៣. | **អាវជ្ជនស្ថាន** | **ពិស្តារ ២** | **កន្លែង** |
| ៤. | **បញ្ចវិញ្ញាណស្ថាន** | **មាន ១** | **កន្លែង** |
| ៥. | **សម្បដិច្ឆន្នស្ថាន** | **មាន ១** | **កន្លែង** |

| | | | |
|---|---|---|---|
| ៦- សន្តីរណស្ថាន | មាន | ១ | កន្លែង |
| ៧- វោដ្ឋព្វនស្ថាន | ពិស្តារ | ២ | កន្លែង |
| ៨- ជវនស្ថាន | ពិស្តារ | ៦ | កន្លែង |
| ៩- តទាលម្ពណស្ថាន | ពិស្តារ | ២ | កន្លែង |
| ១០- ចុតិស្ថាន | ពិស្តារ | ៣ | កន្លែង |

## អធិប្បាយស្ថានរបស់ចិត្តដោយពិស្តារ ២៥

**១- បដិសន្ធិស្ថាន មាន ១ កន្លែង គឺ**

រវាងចុតិ និង ភវង្គ[១១៦] ។

**២- ភវង្គស្ថាន មាន ៦ កន្លែង គឺ**

(១)- រវាង បដិសន្ធិ និង អាវជ្ជនៈ[១១៧]

(២)- រវាង តទាលម្ពណៈ និង អាវជ្ជនៈ[១១៨]

(៣)- រវាង ជវនៈ និង អាវជ្ជនៈ[១១៩]

(៤)- រវាង វោដ្ឋព្វនៈ និង អាវជ្ជនៈ[១២០]

(៥)- រវាង តទាលម្ពណៈ និង ចុតិ[១២១]

(៦)- រវាង ជវនៈ និង ចុតិ[១២២] ។

**៣- អាវជ្ជនស្ថាន មាន ២ កន្លែង គឺ**

(១)_ រវាង ភវង្គ និង បញ្ចវិញ្ញាណ[១២៣]

(២)_ រវាង ភវង្គ និង ជវ័នក្នុងមនោទ្វារ [១២៤] ។

**៤_ បញ្ចវិញ្ញាណស្ថាន មាន ១ កន្លែង គឺ**

រវាង អាវជ្ជនៈ និង សម្បដិច្ឆន្នៈ[១២៥] ។

**៥_ សម្បដិច្ឆន្នស្ថាន មាន ១ កន្លែង គឺ**

រវាង បញ្ចវិញ្ញាណ និង សន្តីរណៈ[១២៦] ។

**៦_ សន្តីរណស្ថាន មាន ១ កន្លែង គឺ**

រវាង សម្បដិច្ឆន្នៈ និង វោដ្ឋព្វនៈ[១២៧] ។

**៧_ វោដ្ឋព្វនស្ថាន មាន ២ កន្លែង គឺ**

(១)_ រវាង សន្តីរណៈ និង កាមជវ័ន[១២៨]

(២)_ រវាង សន្តីរណៈ និង ភវង្គ[១២៩] ។

**៨_ ជវនស្ថាន មាន ៦ កន្លែង គឺ**

(១)_ រវាង វោដ្ឋព្វនៈ និង តទាលម្ពណៈ[១៣០]

(២)_ រវាង វោដ្ឋព្វនៈ និង ភវង្គ[១៣១]

(៣)_ រវាង វោដ្ឋព្វនៈ និង ចុតិ[១៣២]

(៤)_ រវាង មនោទ្វារាវជ្ជនៈ និង តទាលម្ពណៈ[១៣៣]

(៥)_ រវាង មនោទ្វារាវជ្ជនៈ និង ភវង្គ[១៣៤]

(៦)_ រវាង មនោទ្វារាវជ្ជនៈ និង ចុតិ[១៣៥] ។

**៩_ តទាលម្ពណស្ថាន មាន ២ កន្លែង គឺ**

(១)_ រវាង ជវន៍ និង ភវង្គ[១៣៦]

(២)_ រវាង ជវន៍ និង ចុតិ[១៣៧] ។

**១០_ ចុតិស្ថាន មាន ៣ កន្លែង គឺ**

១_ រវាង ជវន៍ និង បដិសន្ធិ[១៣៨]

២_ រវាង តទាលម្ពណៈ និង បដិសន្ធិ[១៣៩]

៣_ រវាង ភវង្គ និង បដិសន្ធិ[១៤០] ។

## សរុបស្ថាន ២៥ គឺ

**១,២,៣,៤,៥,៦,៧,៨,៩,១០ = ១០ ស្ថាន**

**១+៦+២+១+១+១+២+៦+២+៣ = ២៥ ស្ថាន**

## សំណួរ

១_ ចិត្តអ្វីខ្លះ ដែលអាចកើតខាងមុខបដិសន្ធិចិត្ត ?

២_ ចិត្តអ្វីខ្លះដែលអាចកើតខាងមុខចក្ខុវិញ្ញាណចិត្ត ?

៣_ ចិត្តអ្វីខ្លះ ដែលអាចកើតខាងមុខវោដ្ឋព្វនចិត្ត ?

៤_ ចិត្តអ្វីខ្លះ ដែលអាចកើតខាងមុខជវនចិត្ត ?

៥. ចិត្តអ្វីខ្លះ ដែលអាចកើតខាងមុខភវង្គចិត្ត ?

៦. ចុតិ កើតខាងមុខចិត្តអ្វីខ្លះ ?

៧. សត្វខាងមុខអំពីចុតិចិត្តហើយ តើអាចមានចិត្តអ្វីដទៃក្រៅអំពីបដិសន្ធិឬទេ ?

៨. សម្រាន្តលក់ស៊ប់មានចិត្តឬទេ ? បើមានតើជាចិត្តអ្វី ?

៩. នៅពេលយល់សប្តិតើជាភវង្គចិត្ត ឬ ជាវិថីចិត្ត ?

១០. តើចិត្តក្នុងទ្វារណាដែលបានដឹងថាមានមនុស្ស ហើយចិត្តក្នុងទ្វារនោះ ជាមនុស្ស ឬទេ ?

១១. សភាវៈប្រាកដតាមទ្វារណាដែលជាមនុស្ស ឬ ជាកូន ?

១២. ចិត្តតាមចក្ខុទ្វារ មានអ្វីជាអារម្មណ៍ ?

១៣. ចិត្តតាមបញ្ចទ្វារ មានអ្វីជាអារម្មណ៍ ?

១៤. បសាទរូប ៥ ជាធម្មារម្មណ៍ឬ ?

១៥. ធម្មារម្មណ៍ មានអ្វីខ្លះ ?

១៦. ខន្ធ ៥, ខន្ធអ្វីជារូប ? ខន្ធអ្វីជានាម ?

១៧. អាយតនៈ ១២, អាយតនៈប៉ុន្មានជារូប ប៉ុន្មានជានាម ?

១៨. ចក្ខុវិញ្ញាណចិត្តុប្បាទ មានខន្ធប៉ុន្មាន ?

# អំពីប្រភេទអារម្មណ៍[១៤១]

**១. អតិមហន្តារម្មណ៍** គឺអារម្មណ៍របស់បញ្ចទ្វារវិថីចិត្ត វិថីចិត្តមានដល់ **តទាលម្ពណវិថី**[១៤២] ។

**២. មហន្តារម្មណ៍** គឺអារម្មណ៍របស់បញ្ចទ្វារវិថីចិត្ត វិថីចិត្តមានដល់ **ជវន័** រួចធ្លាក់ចុះ ***ភវង្គ***[១៤៣] ។

**៣. បរិត្តារម្មណ៍** គឺអារម្មណ៍របស់បញ្ចទ្វារវិថីចិត្ត វិថីចិត្តមានដល់ **វោដ្ឋព្វនៈ** រួចធ្លាក់ចុះ ***ភវង្គ***[១៤៤] ។

**៤. អតិបរិត្តារម្មណ៍** គឺអារម្មណ៍របស់បញ្ចទ្វារវិថីចិត្ត ប៉ុន្តែមិនមានវិថីចិត្តកើតឡើងទេ គ្រាន់តែញ័រ***ភវង្គ***ប៉ុណ្ណោះ[១៤៥] ។

**៥. វិភូតារម្មណ៍** គឺអារម្មណ៍របស់មនោទ្វារវិថីចិត្ត វិថីចិត្តមានដល់ **តទាលម្ពណវិថី**[១៤៦] ។

**៦. អវិភូតារម្មណ៍** គឺអារម្មណ៍របស់មនោទ្វារវិថីចិត្ត វិថីចិត្តមានដល់ **ជវន័** ក៏ធ្លាក់ចុះកាន់ ***ភវង្គ***[១៤៧] ។

❖❖❖❖❖❖❖

# អំពីរូប(១៤៨)

I- មហាភូតរូប ៤ គឺ បឋវី អាបោ តេជោ វាយោ។

II- ឧបាទាយរូប ២៤ គឺ

- បសាទរូប ៥
- វិសយរូប ៤
- ហទយរូប ១
- ឥត្ថីភាវរូប ១
- បុរិសភាវរូប ១
- អាហាររូប ១
- ជីវិតរូប ១
- វិញ្ញត្តិរូប ២
- អាកាសរូប ១
- វិការរូប ៣
- លក្ខណរូប ៤

សរុបរូបទាំងអស់ត្រូវជា ២៨ រូប ។

## **ចែករូបតាមសមុដ្ឋាន**[១៤៩]

**I~ រូប ៩** កើតតែអំពីកម្មសុទ្ធ គឺ **បសាទរូប ៥ ភាវរូប ២ ជីវិតរូប ១ ហទយវត្ថុ១**[១៥០] ។

**II~ រូប ២** កើតតែអំពីចិត្តសុទ្ធ គឺ **កាយវិញ្ញត្តិរូប ១ វចីវិញ្ញត្តិរូប ១**[១៥១] ។

**III~ រូប ១** គឺ **សំឡេង** កើតអំពីចិត្តក៏មាន កើតអំពីឧតុក៏មាន[១៥២] ។

**IV~ វិការរូប ៣** គឺ **រូបស្រាល**(រូបស្ស លហុតា) **១ រូបទន់**(រូបស្ស មុទុតា) **១** និង **រូបគួរដល់ការងារ** (រូបស្ស កម្មញ្ញតា) **១** ។

វិការរូប ៣ នេះ កើតអំពីចិត្តក៏មាន កើតអំពីឧតុក៏មាន កើតអំពី អាហារក៏មាន[១៥៣] ។

**V~ រូប ៩** គឺ **មហាភូតរូប ៤** និង **វណ្ណោ** = ពណ៌ **១ គន្ធោ** = ក្លិន **១**, **រសោ** = រសជាតិ **១**, **ឱជា** = អាហាររូប **១**, **អាកាសធាតុ** = បរិច្ឆេទរូប **១** ។ រូប ៩ នេះកើតអំពីកម្មក៏មាន ចិត្តក៏មាន ឧតុក៏មាន អាហារក៏មាន[១៥៤] ។

**VI. លក្ខណរូប ៤** ជាលក្ខណៈរបស់សភាវរូប មិនចាំបាច់ ពោលដោយសមុដ្ឋានឡើយ[១៥៥] ។

## កលាបរូប[១៥៦]

### I. កម្មជកលាបរូប មាន ៩ សំណុំ[១៥៧]

**១. ចក្ខុទសកកលាប** ៖ សំណុំរូបមានភ្នែកជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨** (មហាភូតរូប ៤ + វណ្ណោ គន្ធោ រសោ ឱជា) + **ជីវិតរូប** + **ចក្ខុបសាទ** ជាគម្រប់ ១០[១៥៨] ។

**២. សោតទសកកលាប** ៖ សំណុំរូបមានត្រចៀកជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨** + **ជីវិតរូប** + **សោតប្បសាទ** ជាគម្រប់ ១០[១៥៩] ។

**៣. ឃានទសកកលាប**៖ សំណុំរូបមានច្រមុះជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨** + **ជីវិតរូប** + **ឃានប្បសាទ** ជាគម្រប់ ១០[១៦០] ។

**៤. ជិវ្ហាទសកកលាប**៖ សំណុំរូបមានអណ្តាតជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨** + **ជីវិតរូប** + **ជិវ្ហាបសាទ** ជាគម្រប់ ១០[១៦១] ។

**៥. កាយទសកកលាប** ៖ សំណុំរូបមានកាយជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨ + ជីវិតរូប + កាយប្បសាទ** ជាគម្រប់ ១០[១៦២]។

**៦. វត្ថុទសកកលាប** ៖ សំណុំរូបមានហទយវត្ថុជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨ + ជីវិតរូប + ហទយ-វត្ថុ** ជាគម្រប់ ១០[១៦៣]។

**៧. ឥត្ថីភាវទសកកលាប** ៖ សំណុំរូបមានឥត្ថីភាវរូបជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨ + ជីវិតរូប + ឥត្ថី-ភាវរូប** ជាគម្រប់ ១០[១៦៤]។

**៨. បុរិសភាវទសកកលាប** ៖ សំណុំរូបមានបុរិសភាវ-រូបជាគម្រប់ ១០ រូប គឺ **អវិនិព្ភោគរូប ៨ + ជីវិតរូប + បុរិស-ភាវរូប** ជាគម្រប់ ១០[១៦៥]។

**៩. ជីវិតនវកកលាប** ៖ សំណុំរូបមានជីវិតរូប ជាគម្រប់ ៩ រូប គឺ **អវិនិព្ភោគរូប ៨+ជីវិតរូប** ជាគម្រប់ ៩[១៦៦]។

✶. **សរុបកម្មជរូប ពិស្តារ ៨៩, សង្ខេប ១៨** ។

## សំណួរ

១. កម្មជរូប ៩ សំណុំ រាប់រាយមានប៉ុន្មាន ?

២. មនុស្សយើងម្នាក់ៗមានកម្មជរូបប៉ុន្មានសំណុំ ?

៣. រូបព្រហ្មមានកម្មជរូបប៉ុន្មានសំណុំ ?

៤. រូបព្រហ្ម មានវត្ថុរូបប៉ុន្មាន ?

៥. អសញ្ញីសត្វ មានកម្មជរូបប៉ុន្មានសំណុំ ?

៦. អសញ្ញីសត្វ មានវត្ថុរូប ឬទេ ?

## II. ចិត្តជកលាបរូប ៦ សំណុំ[១៦៧]

១. **សុទ្ធដ្ឋកកលាប** = សំណុំរូបមានតែ **អវិនិព្ភោគរូប** ៨ សុទ្ធ[១៦៨] ។

២. **កាយវិញ្ញត្តិនវកកលាប** = សំណុំរូបមានកាយ-វិញ្ញត្តិជាគម្រប់ ៩ គឺ **អវិនិព្ភោគរូប ៨** + **កាយវិញ្ញត្តិរូប** ជាគម្រប់ ៩[១៦៩] ។

៣. **វចីវិញ្ញត្តិសទ្ទទសកកលាប** = សំណុំរូបមានវចីវិញ្ញត្តិ និង សទ្ទរូបជាគម្រប់ ១០ គឺ **អវិនិព្ភោគរូប ៨** + **វចីវិញ្ញត្តិរូប** + **សទ្ទរូប** ជាគម្រប់ ១០[១៧០] ។

៤. **លហុតាទិត្រយេកាទសកកលាប** ៖ សំណុំរូបមានវិការរូប ៣ ជាគម្រប់ ១១ គឺ **អវិនិព្ភោគរូប ៨ + វិការរូប ៣** ជាគម្រប់ ១១[១៧១]។

៥. **កាយវិញ្ញត្តិលហុតាទិត្រយទ្វាទសកកលាប**៖ សំណុំរូបមានកាយវិញ្ញត្តិ ១ និង វិការរូប ៣ ជាគម្រប់ ១២ គឺ **អវិនិព្ភោគរូប ៨ + កាយវិញ្ញត្តិ ១ + វិការរូប ៣** ជាគម្រប់ ១២[១៧២] ។

៦. **វចីវិញ្ញត្តិសទ្ទលហុតាទិត្រយតេរសកកលាប** ៖ សំណុំរូបមានវចីវិញ្ញត្តិរូប ១ សទ្ទរូប ១ និងវិការរូប ៣ ជាគម្រប់ ១៣ គឺ **អវិនិព្ភោគរូប ៨ + វចីវិញ្ញត្តិរូប ១ + សទ្ទរូប ១ + វិការរូប ៣** ជាគម្រប់ ១៣[១៧៣]។

## សរុបចិត្តជរូប

| | | |
|---|---|---|
| (១) | ៨ ៖ អវិនិព្ភោគរូប ៨ | |
| (២) | ៩ ៖ ( ៨ + ១ ) | |
| (៣) | ១០ ៖ ( ៨ + ១ + ១ ) | ពិស្តារ ៦៣ រូប |
| (៤) | ១១ ៖ ( ៨ + ៣ ) | សង្ខេប ១៥ រូប |
| (៥) | ១២ ៖ ( ៨ + ១ + ៣ ) | |
| (៦) | ១៣ ៖ ( ៨ + ១ + ១ + ៣ ) | |

## **សំណួរ**

១. អវិនិព្ភោគរូប មានរូបប៉ុន្មាន ប្រែដូចម្តេច ?

២. សទ្ទរូបដែលកើតអំពីចិត្ត តើមានមិនប្រកបជាមួយនឹងវចីវិញ្ញត្តិដែរឬទេ ?

## **III. ឧតុជកលាបរូបមាន ៤ សំណុំ**[១៧៤]

១. **សុទ្ធដ្ឋកកលាប** = **អវិនិព្ភោគរូប ៨**[១៧៥]។

២. **សទ្ទនវកកលាប** មានសំឡេងជាគម្រប់ ៩[១៧៦] ។

៣. **លហុតាទិត្រយេកាទសកកលាប** មានវិការរូបជាគម្រប់ ១១ គឺ ៨ + ៣ = ១១[១៧៧] ។

៤. **សទ្ទលហុតាទិត្រយទ្វាទសកកលាប** មានសំឡេង និង វិការរូប ៣ ជាគម្រប់ ១២[១៧៨]។

★. **សរុបរួម** =៨+៩+១១+១២=៤០ រូប, សង្ខេប ១៣ រូប។

## **ឧតុជកលាបខាងក្រៅមាន ២ សំណុំ**[១៧៩]

១. **សុទ្ធដ្ឋកកលាប** = **អវិនិព្ភោគរូប ៨**[១៨០]។

២. **សទ្ទនវកកលាប**=មានសទ្ទរូបជាគម្រប់ ៩[១៨១]។

## IV- អាហារជកលាបរូបមាន ២ សំណុំ[១៨២]

១- **សុទ្ធដ្ឋកកលាប** = មានរូប ៨ សុទ្ធ[១៨៣] ។

២- **លហុតាទិត្រយេកាទសកកលាប** មានវិការរូប ៣ ជាគម្រប់ ១១[១៨៤] ។

✶- សរុបអាហារជរូប គឺ ១៩ រូប , សង្ខេប ១២ រូប ។

**សរុបរូបខាងក្នុងនាំង ៤ សមុដ្ឋានរូប**[១៨៥]

| | | | |
|---|---|---|---|
| - **កម្មជកលាបរូប** | ៩ | សំណុំ = ៨៩ | ឬ ១៨ រូប |
| - **ចិត្តជកលាបរូប** | ៦ | សំណុំ = ៦៣ | ឬ ១៥ រូប |
| - **ឧតុជកលាបរូប** | ៤ | សំណុំ = ៤០ | ឬ ១៣ រូប |
| - **អាហារជកលាបរូប** | ២ | សំណុំ = ១៩ | ឬ ១២ រូប |
| **សរុប** | ២១ | សំណុំ =២១១ | ឬ ៥៨ រូប |

✶- កម្ម ២៥ នាំឱ្យកើត **កម្មជរូប** ។ កម្ម ២៥ គឺ ចេតនាក្នុងអកុសលចិត្ត ១២, ចេតនាក្នុងមហាកុសលចិត្ត ៨, ចេតនាក្នុងរូបាវចរកុសលចិត្ត ៥[១៨៦] ។

✶- ចិត្ត ៧៥ ( វៀរទ្វិបញ្ចវិញ្ញាណ ១០ និង អរូបាវចរវិបាក ៤ ) នាំឱ្យកើត **ចិត្តជរូប** [១៨៧] ។

# ចែករូប ២៨ ជាពីរៗ

**១~ ឥន្ទ្រិយរូប ៨** គឺ បសាទរូប ៥ ភាវរូប ២ និង ជីវិតរូប ១ ។ រូប ២០ ទៀត ជា **អនិន្ទ្រិយរូប**[(១៨៨)] ។

**២~ វត្ថុរូប ៦** គឺ បសាទរូប ៥ ហទយវត្ថុរូប ១ ។ រូប ២២ ទៀតជា **អវត្ថុរូប**[(១៨៩)] ។

**៣~ ទ្វាររូប ៧** គឺ បសាទរូប ៥ វិញ្ញត្តិរូប ២។ រូប ២១ ទៀតជា **អទ្វាររូប**[(១៩០)] ។

**៤~ គោចររូប ៧** គឺ រូប ១ សទ្ទ ១ គន្ធ ១ រស ១ បឋវី ១ តេជោ ១ វាយោ ១។ រូប ២១ ទៀតជា **អគោចររូប**[(១៩១)] ។

**៥~ អវិនិព្ភោគរូប ៨** គឺ បឋវី អាបោ តេជោ វាយោ វណ្ណោ គន្ធោ រសោ ឱជា ( អាហារ ) ។ រូប ២០ ទៀតជា **វិនិព្ភោគរូប**[(១៩២)] ។

**៦~ សនិទស្សនរូប ១** គឺ រូបារម្មណ៍។ រូប ២៧ ទៀត ជា **អនិទស្សនរូប**[(១៩៣)] ។

**៧~ សប្បដិឃរូប ឬ ឱឡារិករូប ឬ សន្តិកេរូប ១២** គឺ បសាទរូប ៥ និង គោចររូប ៧ ។ រូប ១៦ ទៀតជា **អប្បដិឃរូប ឬ សុខុមរូប ឬ ទូរេរូប**[(១៩៤)] ។

**៨~ សភាវរូប ១៨** គឺ កម្មជរូប ១៧ (វៀរបរិច្ឆេទរូប) និង សទ្ទរូប ១ ។ នៅរូប ១០ ទៀតជា **អសភាវរូប**[១៩៥] ។

**៩~ អជ្ឈត្តិករូប ៥** គឺ បសាទរូប ៥ ។ នៅរូប ២៣ ទៀតជា **ពាហិររូប**[១៩៦] ។

**១០~ មហាភូតរូប ៤** គឺ បថវី ១ អាបោ ១ តេជោ ១ វាយោ ១ ។ នៅរូប ២៤ ទៀតជា **ឧបាទាយរូប**[១៩៧] ។

# អប្បនាជវ័ន ៥៨ ដួង[១៩៨]

មហគ្គតកុសលចិត្ត ៩ ដួង មហគ្គតកិរិយាចិត្ត ៩ ដួង និង លោកុត្តរចិត្តពិស្តារ ៤០ ដួង សម្បយុត្តដោយចេតសិក ។

## តារាងអប្បនាជវ័ន ៥៨

| ឈាន | កុសល | កិរិយា | មគ្គ | ផល | រួម |
|---|---|---|---|---|---|
| បឋម. | ១ | ១ | ៤ | ៤ = (៣+១) | ១០ |
| ទុតិ. | ១ | ១ | ៤ | ៤ = (៣+១) | ១០ |
| តតិ. | ១ | ១ | ៤ | ៤ = (៣+១) | ១០ |
| ចតុត្ថ. | ១ | ១ | ៤ | ៤ = (៣+១) | ១០ |
| បញ្ចម. | ៥=(១+៤) | ៥=(១+៤) | ៤ | ៤ = (៣+១) | ១៨ |
| សរុប | ៩ | ៩ | ២០ | ២០ =(១៥+៥) | ៥៨ |
| បុគ្គល | បុថុជ្ជន+សេក្ខ. | អសេក្ខ. | សេក្ខ. | សេក្ខ.+អសេក្ខ. | |

### សំណួរ

១. បុថុជ្ជនមាន អប្បនាជវ័នប៉ុន្មាន ?

២. សេក្ខបុគ្គលមាន អប្បនាជវ័នប៉ុន្មាន ?

៣. អសេក្ខបុគ្គលមាន អប្បនាជវ័នប៉ុន្មាន ?

# ចិត្តកើតក្នុងភព ៣០ ជាន់ (១៩៩)

១. ចិត្ត ៤ ដួង កើតក្នុងភព ១

២. ចិត្ត ៤ ដួង កើតក្នុងភព ៣

៣. ចិត្ត ១ ដួង កើតក្នុងភព ៦

៤. ចិត្ត ៨ ដួង កើតក្នុងភព ៧

៥. ចិត្ត ៨ ដួង កើតក្នុងភព ១១

៦. ចិត្ត ១ ដួង កើតក្នុងភព ១៧

៧. ចិត្ត ៤ ដួង កើតក្នុងភព ២១

៨. ចិត្ត ១១ ដួង កើតក្នុងភព ២២

៩. ចិត្ត ២ ដួង កើតក្នុងភព ២៣

១០. ចិត្ត ២ ដួង កើតក្នុងភព ២៤

១១. ចិត្ត ២ ដួង +៥ ដួង កើតក្នុងភព ២៥

១២. ចិត្ត ១០ ដួង +១៣ ដួង កើតក្នុងភព ២៦

១៣. ចិត្ត ១៤ ដួង កើតក្នុងភព ៣០

# អធិប្បាយចិត្តកើតក្នុងភព ៣០ ជាន់

**១~ ចិត្ត ៤ ដួងកើតក្នុងភព ១ គឺ អរូបាវចរវិបាក** ៤ អរូបវិបាក ១ កើតក្នុងអរូបភព ១ តាមជាន់ទាំង ៤ ដូចជា អាកាសានញ្ចាយតនវិបាក កើតក្នុងអរូបភពទី ១ ជាដើម ។

**២~ ចិត្ត ៤ ដួងកើតក្នុងភព ៣** គឺ

~ **បឋមជ្ឈានវិបាកចិត្ត** កើតក្នុងព្រហ្ម ៣ ជាន់ក្នុង បឋមជ្ឈានភូមិ គឺបារិសជ្ជា បរោហិតា និង មហាព្រហ្ម ។

~ **ទុតិយជ្ឈានវិបាកចិត្ត** និង **តតិយជ្ឈានវិបាកចិត្ត** ចិត្ត ២ ដួងនេះកើតក្នុងព្រហ្ម ៣ ជាន់ទៀតក្នុងទុតិយជ្ឈានភូមិ គឺ បរិត្តាភាព្រហ្ម អប្បមាណាភាព្រហ្ម និង អាភស្សរាព្រហ្ម ។

~ **ចតុត្ថជ្ឈានវិបាកចិត្ត** កើតក្នុងព្រហ្មបីជាន់ទៀត ក្នុង តតិយជ្ឈានភូមិ គឺបរិត្តសុភា អប្បមាណសុភា សុភកិណ្ហកា។

**៣~ ចិត្ត ១ ដួងកើតក្នុងភព ៦** គឺ **បញ្ចមជ្ឈានវិបាក** ចិត្តមួយនេះកើតក្នុងភព ៦ គឺ វេហប្ផលាព្រហ្ម ១ និង សុទ្ធា-វាសព្រហ្ម ៥ ជាន់ ។

**៤. ចិត្ត ៨ ដួងកើតក្នុងភព ៧ គឺ មហាវិបាក ៨** ចិត្ត ៨ ដួងនេះកើតក្នុងមនុស្ស ១ និង ទេវតា ៦ ជាន់។

**៥. ចិត្ត ៨ ដួងកើតក្នុងភព ១១ គឺ ឃានវិញ្ញាណ ២ ជិវ្ហាវិញ្ញាណ ២ កាយវិញ្ញាណ ២** និង **ទោសចិត្ត ២** ចិត្ត ៨ ដួងនេះកើតក្នុងកាមភព ១១ ជាន់ (សុគតិ ៧ + ទុគ្គតិ ៤ )។

**៦. សោតាបត្តិមគ្គចិត្ត** ចិត្ត ១ ដួងនេះកើតក្នុងកាម-សុគតិភព ៧ និង រូបព្រហ្ម ១០ ជាន់ ( វៀរសុទ្ធាវាស ៥ ) ។

**៧. ចិត្ត ៤ ដួងកើតក្នុងភព ២១** គឺ **សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១** និង **អនាគាមិមគ្គ ១** ។ ចិត្ត ៤ ដួងនេះ កើតក្នុងភព ២១ គឺ កាមសុគតិ ៧ + រូបព្រហ្ម ១០ ( វៀរសុទ្ធាវាស ៥ ) + អរូបព្រហ្ម ៤ ។

**៨. ចិត្ត ១១ ដួង កើតក្នុងភព ២២** គឺ **រូបាវចរ-កុសល ៥ រូបាវចរកិរិយា ៥** និង **ហសិតុប្បាទចិត្ត ១** ។ ភព ២២ គឺ កាមសុគតិ ៧ + រូបព្រហ្ម ១៥ ។

**៩. ចិត្ត ២ ដួងកើតក្នុងភព ២៣** គឺ **អាកាសា-នញ្ចាយតនកុសល ១ កិរិយា ១** ។ ភព ២៣ គឺ កាមសុគតិ ៧ + រូបព្រហ្ម ១៥ + អរូបព្រហ្ម ទី១ ។

**១០. ចិត្ត ២ ដួងកើតក្នុងភព ២៤ គឺ វិញ្ញាណញ្ចាយតនកុសល ១ កិរិយា ១** ។ ភព ២៤ គឺ កាមសុគតិ ៧+រូបព្រហ្ម ១៥ + អរូបព្រហ្មជាន់ក្រោម ២ (គឺ អាកាសានញ្ចាយតនភព ១ + វិញ្ញាណញ្ចាយតនភព ១ ) ។

**១១. ចិត្ត ២ ដួង+៥ ដួង កើតក្នុងភព ២៥ :**

- ចិត្ត ២ ដួង គឺ **អាកិញ្ចញ្ញាយតនកុសល ១ កិរិយា ១** ភព ២៥ គឺ កាមសុគតិ ៧ + រូបព្រហ្ម ១៥ + អរូបព្រហ្មជាន់ក្រោម ៣ ។

- ចិត្ត ៥ គឺ **លោភៈប្រកបដោយទិដ្ឋិ ៤** ដួង **មោហវិចិកិច្ឆាសម្បយុត្តចិត្ត ១** ។ ភព ២៥ គឺ កាមភព ១១ + រូបព្រហ្ម ១០ ( វៀរសុទ្ធាវាស ) +អរូបព្រហ្ម ៤ ។

**១២. ចិត្ត ១០ ដួង+១៣ ដួង កើតក្នុងភព ២៦ :**

- ចិត្ត ១០ ដួង គឺ **ចក្ខុវិញ្ញាណ ២ សោតវិញ្ញាណ ២ មនោធាតុ ៣ សន្តីរណៈ ៣** ។ ភព ២៦ គឺវៀរអរូបព្រហ្ម ៤ ។

- ចិត្ត ១៣ ដួង គឺ **មហាកិរិយា ៨ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ នេវសញ្ញានាសញ្ញាយតនកុសល ១ កិរិយា ១** ។ ភព ២៦ គឺ វៀរអបាយភូមិ ៤ ។

## ១៣. ចិត្ត ១៤ ដួង កើតក្នុងភព ៣០ :

ចិត្ត ១៤ ដួង គឺ **មហាកុសល ៨ មនោទ្វារាវជ្ជនៈ ១ លោភៈប្រាសចាកទិដ្ឋិ ៤** និង **មោហមូលចិត្តសម្បយុត្តចិត្ត ១** ។

ភព ៣០ គឺវៀរតែអសញ្ញីព្រហ្មដែលមិនមានចិត្តនោះឯង ។

### សំណួរ

១. អបាយភូមិ ៤ មានចិត្តប៉ុន្មាន ?

២. កាមសុគតិ ៧ មានចិត្តប៉ុន្មាន ?

៣. ព្រហ្មបឋមជ្ឈានភូមិ មានចិត្តប៉ុន្មាន ?

៤. ព្រហ្មទុតិយជ្ឈានភូមិ មានចិត្តប៉ុន្មាន ?

៥. ព្រហ្មតតិយជ្ឈានភូមិ មានចិត្តប៉ុន្មាន ?

៦. ព្រហ្មវេហប្ផលា មានចិត្តប៉ុន្មាន ?

៧. ព្រហ្មសុទ្ធាវាស មានចិត្តប៉ុន្មាន ?

៨. អរូបព្រហ្ម ទី១ មានចិត្តប៉ុន្មាន ?

៩. អរូបព្រហ្ម ទី២ មានចិត្តប៉ុន្មាន ?

១០. អរូបព្រហ្ម ទី៣ មានចិត្តប៉ុន្មាន ?

១១. អរូបព្រហ្ម ទី៤ មានចិត្តប៉ុន្មាន ?

១២. សត្វក្នុងអបាយភូមិមានចិត្តប៉ុន្មាន ?

១៣. មនុស្សទេវតាបុថុជ្ជនមានចិត្តប៉ុន្មាន ?

១៤. ព្រះសោតាបន្នក្នុងកាមភពមានចិត្តប៉ុន្មាន ?

១៥. ព្រះអនាគាមីក្នុងកាមភពមានចិត្តប៉ុន្មាន ?

១៦. ព្រះអនាគាមីក្នុងសុទ្ធាវាសព្រហ្មមានចិត្តប៉ុន្មាន ?

១៧. ព្រះអរហន្តក្នុងសុទ្ធាវាសព្រហ្មមានចិត្តប៉ុន្មាន ?

១៨. ព្រះអរហន្តក្នុងអរូបព្រហ្មទី ៤ មានចិត្តប៉ុន្មាន ?

# សរុបចិត្តក្នុងភពផ្សេងៗ[២០០]

**១~ ក្នុងអបាយភូមិ ៤ មានចិត្ត ៣៧ គឺ**

- មហាកុសលចិត្ត ៨ ដួង
- អកុសលចិត្ត ១២ ដួង
- អហេតុកវិបាកចិត្ត ១៥ ដួង
- អហេតុកកិរិយាចិត្ត ២ ដួង ។

**២~ ក្នុងកាមសុគតិ ៧ មានចិត្ត ៨០ គឺ**

- កុសលចិត្ត ២១ ដួង
- អកុសលចិត្ត ១២ ដួង
- វិបាកចិត្ត ២៧ ដួង (វៀរមហគ្គតវិបាក ៩)
- កិរិយាចិត្ត ២០ ដួង ។

**៣~ ក្នុងបឋមជ្ឈានភូមិ ៣ ជាន់ តតិយជ្ឈានភូមិ ៣ ជាន់ និង វេហប្ផលា រួមបានឋានព្រហ្ម ៧ ជាន់ មាន ចិត្ត ៦៥ ដួង គឺ**

- កុសលចិត្ត ២១ ដួង
- អកុសលចិត្ត ១០ ដួង (វៀរទោសមូលចិត្ត ២ ដួង)
- វិបាកចិត្ត ១៤ ដួង (កាមាវចរវិបាក ៩ រូបាវចរវិបាក ១

តាមភូមិរៀងខ្លួន និង លោកុត្តរវិបាក ៤ ) ។

- កិរិយាចិត្ត ២០ ដួង ។

**៤. ក្នុងទុតិយជ្ឈានភូមិ ៣ ជាន់មានចិត្ត ៦៦ ដួង គឺ**

- កុសលចិត្ត ២១ ដួង
- អកុសលចិត្ត ១០ ដួង
- វិបាកចិត្ត ១៥ ដួង (កាមាវចរវិបាក ៩ + ទុតិយជ្ឈាន-វិបាក ១ + តតិយជ្ឈានវិបាក ១ និង លោកុត្តរវិបាក ៤ ) ។
- កិរិយាចិត្ត ២០ ដួង ។

**៥. សុទ្ធាវាសព្រហ្ម ៥ ជាន់មានចិត្ត ៥៥ ដួង គឺ**

- កុសលចិត្ត ១៨ ដួង (វៀរមគ្គ ៣ ខាងក្រោម)
- អកុសលចិត្ត ៥ ដួង(វៀរទិដ្ឋិបដិឃវិចិកិច្ឆាសម្បយុត្តចិត្ត)
- វិបាកចិត្ត ១២ ដួង (លោកិយវិ.១០ +លោកុត្តរវិ. ២ )
- កិរិយាចិត្ត ២០ ដួង ។

**៦. អាកាសានញ្ចាយតនព្រហ្មមានចិត្ត ៤៣ ដួង គឺ**

- កុសលចិត្ត ១៥ ដួង (វៀររូបាវចរកុ.៥+សោតាបត្តិមគ្គ)
- អកុសលចិត្ត ១០ ដួង
- វិបាកចិត្ត ៥ ដួង (អរូបវិ.ទី១ +លោកុត្តរវិ. ៤ )

- កិរិយាចិត្ត ១៣ ដួង (កាមកិ. ៩ + អរូបកិ. ៤) ។

## ៧- វិញ្ញាណញ្ចាយតនព្រហ្មមានចិត្ត ៤១ ដួង គឺ

- កុសលចិត្ត ១៤ ដួង (វៀរអរូបកុ.ទី១)
- អកុសលចិត្ត ១០ ដួង
- វិបាកចិត្ត ៥ ដួង (អរូបវិ.ទី២ + លោកុត្តរវិ. ៤)
- កិរិយាចិត្ត ១២ ដួង (វៀរអរូបកិ.ទី ១) ។

## ៨- អាកិញ្ចញ្ញាយតនព្រហ្មមានចិត្ត ៣៩ ដួង គឺ

- កុសលចិត្ត ១៣ ដួង (វៀរអរូបកុ.ទី១ + ទី២)
- អកុសលចិត្ត ១០ ដួង
- វិបាកចិត្ត ៥ ដួង (អរូបវិ.ទី៣ + លោកុត្តរវិ. ៤)
- កិរិយាចិត្ត ១១ ដួង (វៀរអរូបកិ.ទី១ + ទី២) ។

## ៩- នេវសញ្ញានាសញ្ញា.ព្រហ្មមានចិត្ត ៣៧ ដួង គឺ

- កុសលចិត្ត ១២ ដួង (វៀរអរូបកុ.ក្រោម ៣)
- អកុសលចិត្ត ១០ ដួង
- វិបាកចិត្ត ៥ ដួង (អរូបវិ.ទី៤ + លោកុត្តរវិ. ៤)
- កិរិយាចិត្ត ១០ ដួង (វៀរអរូបកិ.ក្រោម ៣) ។

# សរុបចិត្តក្នុងបុគ្គល ៨ ពួក(២០១)

## បុគ្គល ៨ ពួក គឺ

១. ទុគ្គតិអហេតុកបុគ្គល

២. សុគតិអហេតុកបុគ្គល

៣. ទុហេតុកបុគ្គល

៤. តិហេតុកបុថុជ្ជន

៥. ព្រះសោតាបន្នបុគ្គល

៦. ព្រះសកទាគាមិបុគ្គល

៧. ព្រះអនាគាមិបុគ្គល

៨. ព្រះអរហន្ត ។

**✶. ក្នុងអបាយភូមិ ៤ មានបុគ្គលតែមួយពួក គឺ ទុគ្គតិអហេតុកបុគ្គល** មានចិត្ត ៣៧ ដួង :

- មហាកុសលចិត្ត ៨ ដួង
- អកុសលចិត្ត ១២ ដួង
- អហេតុកវិបាក ១៥ ដួង
- អហេតុកកិរិយា ២ ដួង ។

**៥. ក្នុងកាមសុគតិភព ៧ មានបុគ្គល ៧ ពួក គឺ**

**១. សុគតិអហេតុកបុគ្គល** មានចិត្ត ៣៧ ដួង ដូចទុគ្គតិអហេតុកបុគ្គលដែរ ។

**២. ទុហេតុកបុគ្គល** មានចិត្ត ៤១ ដួង គឺ ចិត្ត ៣៧ ដួងខាងដើម និង មហាវិបាកញាណវិប្បយុត្តចិត្ត ៤ ដួង។

**៣. តិហេតុកបុថុជ្ជន** មានចិត្ត ៥៤ ដួង គឺ ចិត្ត ៣៧ ដួងខាងដើម ថែមមហាវិបាក ៨ ដួង និង មហគ្គតកុសលចិត្ត ៩ ដួង។

**៤. ព្រះសោតាបន្នបុគ្គល** មានចិត្ត ៥០ ដួង គឺដូចជាតិហេតុកបុថុជ្ជនដែរ ប៉ុន្តែត្រូវដកអកុសលចិត្ត ៥ ដួង (ទិដ្ឋិវិចិកិច្ឆា-សម្បយុត្ត) ហើយថែមសោតាបត្តិផលចិត្ត ១ ដួងមកវិញ។

**៥. ព្រះសកទាគាមិបុគ្គល** មានចិត្ត ៥០ ដួង គឺដូចជាព្រះសោតាបន្នបុគ្គលដែរ គ្រាន់តែដូរសោតាបត្តិផលចិត្ត មកជាសកទាគាមិផលចិត្តវិញ (រាគៈទោសៈស្រាលស្តើង)។

**៦. ព្រះអនាគាមិបុគ្គល** មានចិត្ត ៤៨ ដួង ដោយដកទោសមូលចិត្ត ២ ដួងចេញពី ៥០ ដួងខាងដើម ហើយដូរមកជាអនាគាមិផលចិត្តវិញ។

**៧. ព្រះអរហន្ត** មានចិត្ត ៤៤ ដួង គឺ

- វិបាកចិត្ត ២៤ (កាមវិ.២៣+អរហត្តផលចិត្ត ១)

- កិរិយាចិត្ត ២០ ដួង ។

**✶~ ក្នុងព្រហ្មបឋមជ្ឈានភូមិ ៣ ជាន់ តតិយជ្ឈានភូមិ ៣ ជាន់ និង វេហប្ផលា មានបុគ្គល ៥ ពួក គឺ តិហេតុកបុថុជ្ជន ១ ពួក និង ព្រះអរិយបុគ្គល ៤ ពួក។**

**ព្រហ្មបុថុជ្ជន** មានចិត្ត ៣៩ ដួង (លោកិយកុសល ១៧ + អកុសល ១០ +វិបាក ១០ +កិរិយា ២ ) **ព្រះអរិយបុគ្គល ៣ ពួក** មានចិត្ត ៣៥ ដួង (លោកិយកុសល ១៧ +អកុសល ៥ +វិបាក ១១ +កិរិយា ២ ) **ព្រះអរហន្ត** មានចិត្ត ៣១ ដួង (វិបាក ១១ + កិរិយា ២០ )។

**✶~ ក្នុងព្រហ្មទុតិយជ្ឈានភូមិ ៣ ជាន់ បុថុជ្ជន** មាន ចិត្ត ៤០ ដួង **ព្រះអរិយបុគ្គល ៣ ពួក** មានចិត្ត ៣៦ ដួង **ព្រះអរហន្ត** មានចិត្ត ៣២ ដួង។

**✶~ ក្នុងព្រហ្មសុទ្ធាវាស ៥ ជាន់ ព្រះអនាគាមិ-បុគ្គល** មានចិត្ត ៣៥ ដួង **ព្រះអរហន្ត** មានចិត្ត ៣១ ដួង។

**✶~ ក្នុងអរូបព្រហ្ម ៤ ជាន់ មានបុគ្គល ៥ ពួក គឺ**

~ **អរូបព្រហ្ម ទី១ បុថុជ្ជន** មានចិត្ត ២៤ ដួង (កុសល ១២+ អកុសល ១០+ វិបាក ១+ កិរិយា ១) **ព្រះអរិយបុគ្គល ៣ ពួក** មានចិត្ត ២០ ដួង (កុសល ១២+ អកុសល ៥+ វិបាក ២+ កិរិយា ១) **ព្រះអរហន្ត** មានចិត្ត ១៥ ដួង (វិបាក ២+ កិរិយា ១៣)។

~ **អរូបព្រហ្ម ទី២ បុថុជ្ជន** មានចិត្ត ២៣ ដួង **ព្រះអរិយបុគ្គល ៣ ពួក** មានចិត្ត ១៩ ដួង **ព្រះអរហន្ត** មានចិត្ត ១៤ ដួង។

~ **អរូបព្រហ្ម ទី៣ បុថុជ្ជន** មានចិត្ត ២២ ដួង **ព្រះអរិយបុគ្គល ៣ ពួក** មានចិត្ត ១៨ ដួង **ព្រះអរហន្ត** មានចិត្ត ១៣ ដួង។

~ **អរូបព្រហ្ម ទី៤ បុថុជ្ជន** មានចិត្ត ២១ ដួង **ព្រះអរិយបុគ្គល ៣ ពួក** មានចិត្ត ១៧ ដួង **ព្រះអរហន្ត** មានចិត្ត ១២ ដួង។

## **ចិត្តនិយាម**[២០២]

(ទំនៀមរបស់ចិត្ត)

★- ចិត្ត ១៩ គឺ **ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ មគ្គចិត្ត ៤ អភិញ្ញា ២** ប្រព្រឹត្តទៅតែម្តងៗ គឺមួយខណៈតែប៉ុណ្ណោះ មិនជាប់គ្នាពីរដងជាដើមឡើយ ត្រូវចិត្តដទៃទៀតកើតបន្ត[២០៣] ។

★- **សោមនស្សសន្តីរណចិត្ត** ប្រព្រឹត្តទៅម្តងក៏មាន ២ ដងក៏មាន[២០៤] ។

★- **វោដ្ឋព្វនៈ** ប្រព្រឹត្តទៅម្តងក៏មាន ២ ដងក៏មាន ៣ ដងក៏មាន[២០៥] ។

★- ចិត្ត ២៥ ដួង គឺ **រូបាវចរចិត្ត ១៥ ដួង** និង **អរូបាវចរចិត្ត ១០ ដួង** (វៀរនេវសញ្ញានាសញ្ញាយតនកុសល ១ កិរិយា ១) ប្រព្រឹត្តទៅអស់វារៈ ម្តងក៏មាន ច្រើនដងក៏មាន[២០៦] ។

★- ចិត្ត ១០ ដួង គឺ **មហាវិបាកចិត្ត ៨ ដួង** និង **ឧបេក្ខាសន្តីរណចិត្ត ២ ដួង** ប្រព្រឹត្តទៅអស់វារៈ ម្តងក៏មាន ២ ដងក៏មាន ច្រើនដងក៏មាន[២០៧] ។

★- **ហសិតុប្បាទចិត្ត** ប្រព្រឹត្តទៅអស់វារៈ ៧ ដង[២០៨] ។

★- **មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ ដួង** ប្រព្រឹត្តទៅ

អស់វារៈ ៦ ដងក៏មាន ៧ ដងក៏មាន[២០៩] ។

✶- ចិត្ត ១៦ ដួង គឺ **អកុសលចិត្ត ១២ ដួង** និង **មហាកុសលញាណវិប្បយុត្តចិត្ត ៤ ដួង** ប្រព្រឹត្តទៅអស់វារៈ ៥ ដងក៏មាន ៦ ដងក៏មាន ៧ ដងក៏មាន[២១០] ។

✶- ចិត្ត ៨ ដួង គឺ **មហាកុសល** និង **មហាកិរិយាញាណសម្បយុត្តចិត្ត** ប្រព្រឹត្តទៅអស់វារៈ ៣ ដង ៤ ដង ៥ ដង ៦ ដង ៧ ដងក៏មាន[២១១] ។

✶- ចិត្ត ២ ដួង គឺ **សោតាបត្តិផលចិត្ត ១ ដួង** និង **សកទាគាមិផលចិត្ត ១ ដួង** ប្រព្រឹត្តទៅអស់វារៈ ២ ដងក៏មាន ៣ ដងក៏មាន ច្រើនដងក៏មាន[២១២] ។

✶- ចិត្ត ៤ ដួង គឺ **នេវសញ្ញានាសញ្ញាយតនកុសល + កិរិយាចិត្ត ២ ដួង អនាគាមិផលចិត្ត ១ ដួង** និង **អរហត្តផលចិត្ត ១ ដួង** ប្រព្រឹត្តទៅអស់វារៈ ម្តងក៏មាន ២ ដងក៏មាន ៣ ដងក៏មាន ច្រើនដងក៏មាន[២១៣] ។

រួមចិត្តទាំងអស់ ៩១ ដួង ដែលប្រព្រឹត្តទៅតាមនិយាមធម៌ មិនស្តាប់បង្គាប់បញ្ជា ជាអនត្តា ។

# អភិធម្ម ធម្មសង្គណី

## តិកមាតិកា ២២(២១៤)

## តិកមាតិកា ទី១

១~ កុសលា ធម្មា ពួកធម៌ជាកុសល គឺ

- កុសលចិត្តពិស្តារ ៣៧ ដួង
- ចេតសិក ៣៨ ។

២~ អកុសលា ធម្មា ពួកធម៌ជាអកុសល គឺ

- អកុសលចិត្ត ១២ ដួង
- ចេតសិក ២៧ ។

៣~ អព្យាកតា ធម្មា ពួកធម៌ជាអព្យាក្រឹត គឺ

- វិបាកចិត្តពិស្តារ ៥២ ដួង
- កិរិយាចិត្ត ២០ ដួង
- ចេតសិក ៣៨
- រូប ២៨ និង ព្រះនិព្វាន ។

## តិកមាតិកា ទី២

**១. សុខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបជាមួយនឹងសុខវេទនា គឺ

- សុខសហគតចិត្ត ៦៣ ដួង
- ចេតសិក ៤៦ (វៀរទោចតុកៈ ៤ វិចិកិច្ឆានិងវេទនា)។

**២. ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបជាមួយនឹងទុក្ខវេទនា គឺ

- ទុក្ខសហគតចិត្ត ៣ ដួង
- ចេតសិក ២១ (វៀរវេទនា)។

**៣. អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា** ពួកធម៌ប្រកបជាមួយនឹងអទុក្ខមសុខវេទនា គឺ

- ឧបេក្ខាសហគតចិត្ត ៥៥ ដួង
- ចេតសិក ៤៦ (វៀរទោចតុកៈ ៤ បីតិ និង វេទនា)។

## តិកមាតិកា ទី៣

**១. វិបាកា ធម្មា** ពួកធម៌ជាវិបាក គឺ

- វិបាកចិត្តពិស្តារ ៥២ ដួង
- ចេតសិក ៣៨ ។

២. **វិបាកធម្មធម្មា** ពួកធម៌ជាបច្ច័យនៃវិបាក គឺ

- កុសលចិត្តពិស្តារ ៣៧ ដួង
- អកុសលចិត្ត ១២ ដួង
- ចេតសិក ៥២។

៣. **នេវវិបាកនវិបាកធម្មធម្មា** ពួកធម៌មិនមែនជាវិបាក ទាំងមិនមែនជាបច្ច័យនៃវិបាក គឺ

- កិរិយាចិត្ត ២០ ដួង
- ចេតសិក ៣៥
- រូប ២៨ និង ព្រះនិព្វាន ។

## តិកមាតិកា ទី៤

១. **ឧបាទិន្នុបាទានិយា ធម្មា** ពួកធម៌កើតពីកម្មអាស្រ័យតណ្ហា ទាំងជាអារម្មណ៍នៃការប្រកាន់មាំ គឺ

- លោកិយវិបាកចិត្ត ៣២ ដួង
- ចេតសិក ៣៥

- កម្មជរូបទាំងអស់ ។

**២. អនុបាទិន្នុបាទានិយា ធម្មា** ពួកធម៌មិនកើតពីកម្ម អាស្រ័យតណ្ហាទេ តែជាអារម្មណ៍នៃការប្រកាន់មាំ គឺ

- លោកិយកុសលចិត្ត ១៧ ដួង
- អកុសលចិត្ត ១២ ដួង
- កិរិយាចិត្ត ២០ ដួង
- ចេតសិក ៥២
- រូប ៣ សមុដ្ឋាន (វៀរកម្មជរូប)។

**៣. អនុបាទិន្នានុបាទានិយា ធម្មា** ពួកធម៌មិនកើតពីកម្ម អាស្រ័យតណ្ហាទេ ទាំងមិនជាអារម្មណ៍នៃការប្រកាន់មាំឡើយ គឺ

- លោកុត្តរចិត្តពិស្តារ ៤០ ដួង
- ចេតសិក ៣៦
- ព្រះនិព្វាន។

## តិកមាតិកា ទី៥

**១. សង្កិលិដ្ឋសង្កិលេសិកា ធម្មា** ពួកធម៌សៅហ្មង ទាំងជាអារម្មណ៍នៃសេចក្តីសៅហ្មង គឺ

- អកុសលចិត្ត ១២ ដួង
- ចេតសិក ២៧ ។

**២. អសង្កិលិដ្ឋសង្កិលេសិកា ធម្មា** ពួកធម៌មិនសៅហ្មង តែជាអារម្មណ៍នៃសេចក្តីសៅហ្មង គឺ

- លោកិយកុសលចិត្ត ១៧ ដួង
- លោកិយវិបាកចិត្ត ៣២ ដួង
- កិរិយាចិត្ត ២០ ដួង
- ចេតសិក ៣៨
- រូប ២៨ ។

**៣. អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា** ពួកធម៌មិនសៅហ្មង ទាំងមិនជាអារម្មណ៍នៃសេចក្តីសៅហ្មង គឺ

- លោកុត្តរចិត្តពិស្តារ ៤០ ដួង
- ចេតសិក ៣៦
- ព្រះនិព្វាន ។

## តិកមាតិកា ទី៦

**១. សវិតក្កសវិចារា ធម្មា** ពួកធម៌ប្រកបដោយ វិតក្ក

ទាំងប្រកបដោយវិចារ គឺ

- កាមាវចរចិត្ត ៤៤ ដួង (វៀរទ្វិបញ្ចវិញ្ញាណ ១០)
- បឋមជ្ឈានចិត្ត ១១ ដួង
- ចេតសិក ៥០ (វៀរវិតក្កវិចារ) ។

២. **អវិតក្កវិចារមត្តា ធម្មា** ពួកធម៌មិនមានវិតក្ក មានត្រឹមតែវិចារ គឺ

- ទុតិយជ្ឈានចិត្ត ១១ ដួង
- ចេតសិក ៣៦ (វៀរវិចារ)
- វិតក្កចេតសិកក្នុងចិត្ត ៥៥ ដួង ។

៣. **អវិតក្កាវិចារា ធម្មា** ពួកធម៌មិនមានវិតក្ក ទាំងមិនមានវិចារ គឺ

- ទ្វិបញ្ចវិញ្ញាណ ១០ ដួង
- តតិយជ្ឈានចិត្ត ១១ ដួង
- ចតុត្ថជ្ឈានចិត្ត ១១ ដួង
- បញ្ចមជ្ឈានចិត្ត ២៣ ដួង
- ចេតសិក ៣៦
- វិចារចេតសិកក្នុងទុតិយជ្ឈានចិត្ត ១១ ដួង
- រូប ២៨ និង ព្រះនិព្វាន ។

# តិកមាតិកា ទី៧

**១. បីតិសហគតា ធម្មា** ពួកធម៌ប្រព្រឹត្តទៅព្រមជាមួយនឹងបីតិ គឺ

- បីតិសហគតចិត្ត ៥១ ដួង
- ចេតសិក ៤៦ (វៀរទោចតុក: ៤ វិចិកិច្ឆា និងបីតិ)។

**២. សុខសហគតា ធម្មា** ពួកធម៌ប្រព្រឹត្តទៅព្រមជាមួយនឹងសុខវេទនា គឺ

- សុខសហគតចិត្ត ៦៣ ដួង
- ចេតសិក ៤៦ (វៀរទោចតុក: ៤ វិចិកិច្ឆានិងវេទនា)។

**៣. ឧបេក្ខាសហគតា ធម្មា** ពួកធម៌ប្រព្រឹត្តទៅព្រមជាមួយនឹងឧបេក្ខាវេទនា គឺ

- ឧបេក្ខាសហគតចិត្ត ៥៥ ដួង
- ចេតសិក ៤៦ (វៀរទោចតុក: ៤ បីតិ និង វេទនា)។

# តិកមាតិកា ទី៨

**១. ទស្សនេន បហាតព្វា ធម្មា** ពួកធម៌ត្រូវលះដោយ

ទស្សនៈ (សោតាបត្តិមគ្គ) គឺ

- លោភមូលចិត្តទិដ្ឋិគតសម្បយុត្ត ៤ ដួង

- មោហមូលចិត្តវិចិកិច្ឆាសម្បយុត្ត ១ ដួង

- ចេតសិក ២២ + ឥស្សា និង មច្ឆរិយៈ ។

- អកុសលចិត្តុប្បាទ ៦ ដួង ទៀត ដែលនាំឱ្យកើតក្នុងអបាយភូមិ ៤ (វៀរមោហមូលចិត្តឧទ្ធច្ចសម្បយុត្ត)។

**២. ភាវនាយ បហាតព្វា ធម្មា** ពួកធម៌ត្រូវលះដោយភាវនា (មគ្គបីទៀតខាងលើ) គឺ

- អកុសលចិត្ត ៧ ដួង

- ចេតសិក ២៣ (វៀរឥស្សា និង មច្ឆរិយៈ) ។

**៣. នេវ ទស្សនេន ន ភាវនាយ បហាតព្វា ធម្មា** ពួកធម៌ដែលមិនមែនជាពួកធម៌ត្រូវលះដោយមគ្គញ្ញាណទាំង ៤ ឡើយ គឺ កុសលធម៌ទាំងអស់ និង អព្យាកតធម៌ទាំងអស់ ។

## តិកមាតិកា ទី៩

**១. ទស្សនេន បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុត្រូវលះដោយទស្សនៈ គឺ

- អកុសលចិត្ត ៥ ដួង (ទិដ្ឋិវិចិកិច្ឆាសម្បយុត្តចិត្ត)

- ចេតសិក ២២ +ឥស្សាមច្ឆរិយៈ (វៀរមោហចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត)។

- អកុសលចិត្តុប្បាទ ៦ ដួងទៀត ដែលនាំឱ្យកើតក្នុងអបាយភូមិ ៤ (វៀរមោហមូលចិត្តឧទ្ធច្ចសម្បយុត្ត)។

**២. ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌មានហេតុត្រូវលះដោយភាវនា គឺ

- អកុសលចិត្ត ៧ ដួង

- ចេតសិក ២៣ ( វៀរឥស្សាមច្ឆរិយៈ និង មោហចេតសិកក្នុងមោហមូលចិត្តឧទ្ធច្ចសម្បយុត្ត)។

**៣. នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា** ពួកធម៌ដែលមិនមែនជាពួកធម៌មានហេតុត្រូវលះដោយមគ្គញ្ញាណទាំង ៤ ឡើយ គឺ

- កុសលធម៌ទាំងអស់ និង អព្យាកតធម៌ទាំងអស់

- មោហចេតសិកក្នុងមោហមូលចិត្ត ២ ដួង ។

★ មិនមែនមគ្គមិនលះនូវមោហចេតសិកក្នុងមោហមូលចិត្តនោះទេ តែក្នុងតិកមាតិកាទី ៩ នេះសំដៅយកអកុសលមានហេតុ។

## តិកមាតិកា ទី១០

**១. អាចយគាមិនោ ធម្មា** ពួកធម៌សន្សំកពូន (នាំឱ្យសត្វលោកកើតស្លាប់ៗ) គឺ

- លោកិយកុសលចិត្ត ១៧ ដួង
- អកុសលចិត្ត ១២ ដួង
- ចេតសិក ៥២ ។

**២. អបចយគាមិនោ ធម្មា** ពួកធម៌មិនសន្សំកពូន (នាំឱ្យដល់ព្រះនិព្វាន) គឺ

- លោកុត្តរកុសលចិត្ត ២០ ដួង (មគ្គ ៤)
- ចេតសិក ៣៦ ។

**៣. នេវាចយគាមិនោ នាបចយគាមិនោ ធម្មា** ពួកធម៌សន្សំកពូនក៏មិនមែន មិនសន្សំកពូនក៏មិនមែនដែរ បានដល់ **អព្យាកតធម៌** ទាំងអស់ ។

## តិកមាតិកា ទី១១

**១. សេក្ខា ធម្មា** ពួកធម៌ជារបស់ព្រះសេក្ខបុគ្គល គឺ

- លោកុត្តរចិត្ត ៣៥ ដួង (វៀរអរហត្តផល ៥ ដួង)
- ចេតសិក ៣៦ ។

**២- អសេក្ខា ធម្មា** ពួកធម៌ជារបស់ព្រះអសេក្ខបុគ្គល គឺ

- អរហត្តផលចិត្ត ៥ ដួង
- ចេតសិក ៣៦ ។

**៣- នេវសេក្ខា នាសេក្ខា ធម្មា** ពួកធម៌មិនមែនជាសេក្ខធម៌ ទាំងមិនមែនជាអសេក្ខធម៌ គឺ

- លោកិយចិត្ត ៨១ ដួង
- ចេតសិក ៥២
- រូប ២៨ និង ព្រះនិព្វាន ។

## តិកមាតិកា ទី១២

**១- បរិត្តា ធម្មា** ពួកធម៌មានសភាពតូចថ្មារ គឺ

- កាមាវចរចិត្ត ៥៤ ដួង
- ចេតសិក ៥២
- រូប ២៨ ។

**២- មហគ្គតា ធម្មា** ពួកធម៌មានសភាពដ៏ធំ គឺ

- មហគ្គតចិត្ត ២៧ ដួង
- ចេតសិក ៣៥។

៣. **អប្បមាណា ធម្មា** ពួកធម៌ប្រមាណមិនបាន គឺ

- លោកុត្តរចិត្ត ៤០ ដួង
- ចេតសិក ៣៦
- ព្រះនិព្វាន ។

## តិកមាតិកា ទី១៣

១. **បរិត្តារម្មណា ធម្មា** ពួកធម៌មានបរិត្តធម៌ជាអារម្មណ៍ គឺ

- កាមាវចរវិបាកចិត្ត ២៣ កិរិយាមនោធាតុ ១ និង ហសិតុប្បាទចិត្ត ១ ។ ចិត្ត ២៥ ដួងនេះ ព្រមដោយចេតសិក ៣៣ ជាឯកន្តៈ (ចំណែកមួយ គឺមានតែកាមាវចរជាអារម្មណ៍) ។
- កាមាវចរចិត្ត ២៩ ដួងទៀត និង អភិញ្ញា ២ ដួង ព្រមដោយចេតសិក ៥០ (វៀរអប្បមញ្ញា ២) ជាអនេកន្តៈ (ចំណែកមិនតែមួយ គឺមានអារម្មណ៍ក្រៅពីកាមាវចរបាន) ។

២. **មហគ្គតារម្មណា ធម្មា** ពួកធម៌មានមហគ្គតធម៌ជាអារម្មណ៍ គឺ

- វិញ្ញាណញ្ចាយតនៈ ៣ ដួង (កុសល វិបាក កិរិយា)

- នេវសញ្ញានាសញ្ញាយតនៈ ៣ ដួង ។

អរូបាវចរចិត្ត ៦ ដួងនេះ ព្រមដោយចេតសិក ៣០ ជាឯកន្តៈ គឺ មានតែមហគ្គតធម៌ជាអារម្មណ៍ ។

- កាមាវចរចិត្ត ២៩ ដួង អភិញ្ញា ២ ចេតសិក ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) ជាអនេកន្តៈ ។

**៣. អប្បមាណារម្មណា ធម្មា** ពួកធម៌មានអប្បមាណ-ធម៌ជាអារម្មណ៍ គឺ

- លោកុត្តរចិត្ត ៤០ ដួង ចេតសិកសម្បយុត្ត ៣៦ មាននិព្វានជាអារម្មណ៍ ជាឯកន្តៈ ។

- មនោទ្វារាវជ្ជនចិត្ត ១ មហាកុសល និងមហាកិរិយា ញាណសម្បយុត្ត ៨ ដួង អភិញ្ញា ២ ចេតសិក ៣៣ (វៀរវិរតិ ៣ អប្បមញ្ញា ២) មានអប្បមាណធម៌ជាអារម្មណ៍ ជាអនេកន្តៈ ។

## តិកមាតិកា ទី១៤

**១. ហីនា ធម្មា** ពួកធម៌ថោកទាប គឺ

- អកុសលចិត្ត ១២ ដួង និង ចេតសិក ២៧

២~ **មជ្ឈិមា ធម្មា** ពួកធម៌ជាកណ្ដាល (កណ្ដាលហីនធម៌ និង បណីតធម៌) គឺ

- លោកិយកុសលចិត្ត ១៧ ដួង
- លោកិយវិបាកចិត្ត ៣២ ដួង
- កិរិយាចិត្ត ២០ ដួង
- ចេតសិក ៣៨
- រូប ២៨ ។

៣~ **បណីតា ធម្មា** ពួកធម៌ប្រណីតឧត្ដម គឺ

- លោកុត្តរចិត្ត ៤០ ដួង
- ចេតសិក ៣៦
- ព្រះនិព្វាន ។

## តិកមាតិកា ទី១៥

១~ **មិច្ឆត្តនិយតា ធម្មា** ពួកធម៌មានសភាពខុសហើយទៀង (ទៀងតែឱ្យបដិសន្ធិក្នុងនរក ក្នុងជាតិបន្ទាប់) គឺ

- លោភមូលចិត្តទិដ្ឋិគតសម្បយុត្ត ៤ ដួង ចេតសិក ២១ ដែលប្រព្រឹត្តទៅក្នុងនិយតមិច្ឆាទិដ្ឋិ ។

- ទោសមូលចិត្ត ២ ដួង ចេតសិក ២២ ដែលប្រព្រឹត្តទៅក្នុងអនន្តរិយកម្ម ៥ ។

**២. សម្មត្តនិយតា ធម្មា** ពួកធម៌មានសភាពត្រូវហើយទៀង គឺ

- លោកុត្តរកុសលចិត្ត ២០ ដួង
- ចេតសិក ៣៦ ។

**៣. អនិយតា ធម្មា** ពួកធម៌ដែលមិនមែនជាពួកធម៌ទៀងទាំង ២ គឺ

- អកុសលចិត្ត ១២ ដួង ចេតសិក ២៧ (វៀរនិយតមិច្ឆាទិដ្ឋិ និង អនន្តរិយកម្ម ៥ )
- លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨
- អព្យាកតធម៌ទាំងអស់ ។

## តិកមាតិកា ទី១៦

**១. មគ្គារម្មណា ធម្មា** ពួកធម៌មានមគ្គជាអារម្មណ៍ គឺ

- មនោទ្វារាវជ្ជនចិត្ត ដែលជាបុរេចារិកនៃបច្ចវេក្ខណញ្ញាណមានមគ្គជាអារម្មណ៍។

- មហាកុសល និង មហាកិរិយាញាណសម្បយុត្តចិត្ត ៨ ដួងរបស់ព្រះអរិយបុគ្គល ក្នុងការពិចារណាមគ្គ ។

- អភិញ្ញា ២ ដួងរបស់ព្រះអរិយបុគ្គល ដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និង អនាគតំសញ្ញាណ ។

✶- រួមត្រូវជាចិត្ត ១១ ដួង ចេតសិក ៣៣ (វៀរវិរតិ ៣ អប្បមញ្ញា ២) ជាអនេកន្តៈ។

**២- មគ្គហេតុកា ធម្មា** ពួកធម៌មានមគ្គជាហេតុ គឺ

- ន័យទី ១ លោកុត្តរកុសលចិត្តុប្បាទ ២០ ដួង មានចេតសិកអង្គមគ្គ ៨ ជាហេតុ ។

- ន័យទី ២ លោកុត្តរកុសលចិត្តុប្បាទ ២០ ដួង មានចេតសិកគឺ អលោភៈ អទោសៈ និង បញ្ញាជាហេតុ ។

- ន័យទី ៣ លោកុត្តរកុសលចិត្តុប្បាទ ២០ ដួង ចេតសិក ៣៥ មានបញ្ញាជាហេតុ (បញ្ញាជាអង្គមគ្គហើយជាតួហេតុទៀត) ។ ទាំង ៣ ន័យនេះជាឯកន្តៈ។

**៣- មគ្គាធិបតិនោ ធម្មា** ពួកធម៌មានមគ្គជាអធិបតី គឺ

- មហាកុសល និង មហាកិរិយាញាណសម្បយុត្តចិត្ត

៨ ដួង ចេតសិក ៣៣ (វៀរវិរតិ ៣ អប្បមញ្ញា ២) មានមគ្គជាអារម្មណាធិបតិប្បច្ច័យ ចំពោះតែព្រះអរិយបុគ្គលក្នុងការពិចារណានូវអរិយមគ្គ ដែលខ្លួនបានសម្រេចហើយ ជាអនេកន្តៈ។

- លោកុត្តរកុសលចិត្ត ២០ ដួង ចេតសិក ៣៥ មានបញ្ញា ឬ វីរិយៈជាសហជាតាធិបតិប្បច្ច័យ ជាឯកន្តៈ។

## តិកមាតិកា ទី១៧

**១- ឧប្បន្នា ធម្មា** ពួកធម៌ដែលកើតឡើងហើយ គឺខន្ធ ៥ ជាបច្ចុប្បន្ន បានដល់

- ចិត្ត ១២១ ដួង ជាវិញ្ញាណក្ខន្ធ
- ចេតសិក ៥២ ជានាមក្ខន្ធ ៣
- រូប ២៨ ជារូបក្ខន្ធ ។

**២- អនុប្បន្នា ធម្មា** ពួកធម៌ដែលមិនទាន់កើតឡើង គឺក្រៅអំពីវិបាកក្នុងភូមិ ៤ និង កម្មជរូបចេញ ខន្ធដទៃទៀតក្នុងអនាគត ឈ្មោះថា អនុប្បន្នា ធម្មា ។

**៣- ឧប្បាទិនោ ធម្មា** ពួកធម៌ដែលប្រុងនឹងកើតឡើងបានដល់វិបាកក្នុងភូមិ ៤ (វិបាកចិត្ត ៥២ ដួង ចេតសិក ៣៨) និង

កម្មជរូបទាំងអស់ ជាអនាគត ។

## តិកមាតិកា ទី១៨

**១. អតីតា ធម្មា** ពួកធម៌ជាអតីត បានដល់ ចិត្ត ចេតសិក រូប ទាំងអស់ ដែលកន្លងទៅហើយ។

**២. អនាគតា ធម្មា** ពួកធម៌ជាអនាគត បានដល់ ចិត្ត ចេតសិក រូប ទាំងអស់ ដែលមិនទាន់មកដល់។

**៣. បច្ចុប្បន្នា ធម្មា** ពួកធម៌ជាបច្ចុប្បន្ន បានដល់ ចិត្ត ចេតសិក រូប ទាំងអស់ ដែលកើតឡើងកំពុងមាន កំពុងប្រាកដ ។

## តិកមាតិកា ទី១៩

**១. អតីតារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាអតីត គឺ

- វិញ្ញាណញ្ចាយតនៈ ៣ ដួង
- នេវសញ្ញានាសញ្ញាយតនៈ ៣ ដួង
- ចេតសិក ៣០ ។

✶- អរូបាវចរចិត្ត ៦ ដួង ចេតសិក ៣០ នេះ មានអតីតា-រម្មណ៍ជាឯកន្តៈ។

- មនោទ្វារាវជ្ជនចិត្ត ១ ដួង កាមជវ័ន ២៩ ដួង តទាលម្ពណចិត្ត ១១ ដួង និង អភិញ្ញា ២ ដួង ។ ចិត្ត ៤៣ ដួងនេះ ប្រកបដោយចេតសិក ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) កើតតាមមនោទ្វារ មានអតីតារម្មណ៍ជាអនេកន្តៈ ។

**២~ អនាគតារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាអនាគត គឺ

- កាមាវចរចិត្តក្នុងមនោទ្វារ ៤១ ដួង
- អភិញ្ញា ២ ដួង
- ចេតសិក ៥០ (វៀរអប្បមញ្ញា ២)។

✶- ពួកធម៌នេះ មានអនាគតារម្មណ៍ជាអនេកន្តៈ។

**៣~ បច្ចុប្បន្នារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន គឺ

- ទ្វិបញ្ចវិញ្ញាណ ១០ ដួង
- មនោធាតុ ៣ ដួង
- ចេតសិក ១០។

✶- ចិត្តុប្បាទ ១៣ ដួងនេះ មានបច្ចុប្បន្នារម្មណ៍ ជាឯកន្តៈ។

- កាមាវចរចិត្ត ៤១ ដួងក្នុងមនោទ្វារ

- អភិញ្ញា ២ ដួង

- ចេតសិក ៥០ ( វៀរអប្បមញ្ញា ២ )។

✶- ចិត្តុប្បាទ ៤៣ ដួងនេះ ជាអនេកន្តៈ ។

## តិកមាតិកា ទី២០

**១- អជ្ឈត្តា ធម្មា** ពួកធម៌ជាខាងក្នុង គឺ ចិត្ត ចេតសិក រូប ទាំងអស់ដែលជារបស់ខាងក្នុង ដែលសត្វទាំងឡាយប្រកាន់ថាជាខ្លួនឯង ឬដែលសន្មតថាជាខ្លួនឯង ។

**២- ពហិទ្ធា ធម្មា** ពួកធម៌ជាខាងក្រៅ គឺ ចិត្ត ចេតសិក រូប ទាំងអស់ដែលជារបស់ខាងក្រៅដែលសត្វទាំងឡាយប្រកាន់ថាជាអ្នកដទៃឬដែលសន្មតថាជាអ្នកដទៃ ព្រមទាំងរូបដែលមិនជាប់ដោយឥន្ទ្រិយទាំងឡាយ ( ផែនដីព្រៃភ្នំជាដើម ) និង ព្រះនិព្វាន។

**៣- អជ្ឈត្តពហិទ្ធា ធម្មា** ពួកធម៌ជាខាងក្នុងទាំងជាខាងក្រៅ គឺ ចិត្ត ចេតសិក រូប ទាំងអស់ទាំងក្នុងទាំងក្រៅ ( វៀររូប

ដែលមិនជាប់ដោយឥន្ទ្រិយទាំងឡាយ និង ព្រះនិព្វាន ) ។

## តិកមាតិកា ទី២១

**១. អជ្ឈត្តារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាខាងក្នុង គឺ

- វិញ្ញាណញ្ចាយតនៈ ៣ ដួង
- នេវសញ្ញានាសញ្ញាយតនៈ ៣ ដួង
- ចេតសិក ៣០ ។

✶. ចិត្ត ៦ ដួង និង ចេតសិក ៣០ នេះ ជាឯកន្តៈ ។

- កាមាវចរចិត្ត ៥៤ ដួង អភិញ្ញា ២ ដួង ចេតសិក ៤៩ ( វៀរឥស្សា និង អប្បមញ្ញា ២ ) ជាអនេកន្តៈ ។

**២. ពហិទ្ធារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាខាងក្រៅ គឺ

- រូបាវចរចិត្ត ១៥ ដួង
- អាកាសានញ្ចាយតនៈ ៣ ដួង ។

✶. ចិត្ត ១៨ ដួងនេះ និង ចេតសិក ៣៥ មានបញ្ញត្តិអាស្រ័យសភាវៈជាអារម្មណ៍ ជាឯកន្តៈ ។

- លោកុត្តរចិត្ត ៤០ ដួង ចេតសិក ៣៦ មានព្រះ-និព្វាន ជាអារម្មណ៍ ជាឯកន្តៈ។

- កាមាវចរចិត្ត ៥៤ ដួង អភិញ្ញា ២ ដួង ចេតសិក ៤៩ (វៀរឥស្សា និង អប្បមញ្ញា ២) ជាអនេកន្តៈ ។

- ឥស្សា និង អប្បមញ្ញា ២ ជាឯកន្តៈ ។

**៣. អជ្ឈត្តពហិទ្ធារម្មណា ធម្មា** ពួកធម៌មានអារម្មណ៍ជាខាងក្នុងក៏បាន ជាខាងក្រៅក៏បាន គឺ

- កាមាវចរចិត្ត ៥៤ ដួង
- អភិញ្ញា ២ ដួង
- ចេតសិក ៤៩ (វៀរឥស្សា និង អប្បមញ្ញា ២)។

✶. ចិត្តុប្បាទនេះ ខ្លះជាឯកន្តៈ ខ្លះទៀតជាអនេកន្តៈ ។

## តិកមាតិកា ទី២២

**១. សនិទស្សនសប្បដិឃា ធម្មា** ពួកធម៌ដែលឃើញបាន ទាំងដែលប៉ះខ្ទប់បាន គឺរូបារម្មណ៍ ។

✶. ក្នុងរូប ២៨ មានតែរូប ១ គត់ ដែលគួរដល់ការឃើញ គឺវណ្ណរូប (ពណ៌)។ ដែលថាប៉ះខ្ទប់ គឺប៉ះនឹងបសាទរូប ដូច្នេះ

វណ្ណរូប រមែងប៉ះនឹងចក្ខុបសាទ ។

**២. អនិទស្សនសប្បដិឃា ធម្មា** ពួកធម៌ដែលមិនអាចឃើញបាន តែប៉ះខ្ទប់បាន គឺឱឡារិករូប ១១ (វៀរវណ្ណរូប) ។

**៣. អនិទស្សនាប្បដិឃា ធម្មា** ពួកធម៌ដែលមិនអាចឃើញបាន ទាំងមិនអាចប៉ះខ្ទប់បាន គឺ

- ចិត្តចេតសិកទាំងអស់
- សុខុមរូប ១៦
- ព្រះនិព្វាន ។

# ពន្យល់ធម៌តាមលេខយោង

**១. ចេតសិក** ៖ ជានាមក្ខន្ធ ៣ គឺ វេទនាចេតសិក ជាវេទនាខន្ធ សញ្ញាចេតសិកជាសញ្ញាខន្ធ ចេតសិក ៥០ ទៀតជាសង្ខារក្ខន្ធ ។ ចេតសិកជាធម្មជាតិកើតរលត់ជាមួយនឹងចិត្ត ដូច្នេះសូមពុទ្ធបរិស័ទទន្ទេញចេតសិក ៥២ នេះឱ្យចាំជាមុន លុះដល់រៀនអំពីចិត្តប្រកបជាមួយនឹងចេតសិក ពុទ្ធបរិស័ទពិតជាយល់អំពីចេតសិកច្បាស់ ។

ចេតសិក ៥២ ចែកជា ៣ ពួកធំៗ ។

**២. អញ្ញសមានាចេតសិក** គឺជាចេតសិកមានជាតិស្មើគ្នានឹងចេតសិកដទៃ បានសេចក្តីថា បើខ្លួនឯងកើតជាមួយនឹងអកុសលចេតសិក ក៏មានជាតិជាអកុសល បើកើតជាមួយនឹងសោភណចេតសិក ក៏មានជាតិជាសោភណៈ ប៉ុន្តែកាលដែលកើតជាមួយនឹងអហេតុកចិត្ត ១៨ ដួង មិនរួមជាមួយនឹងពួកចេតសិកដទៃឡើយ ។

អញ្ញសមានាចេតសិក ១៣ មានពីរក្រុម ។

**៣. សព្វចិត្តសាធារណចេតសិក** ចេតសិក ៧ នេះកើតរួមជាទូទៅគ្រប់ចិត្តទាំងអស់ ។

**៤. បកិណ្ណកចេតសិក** ចេតសិក ៦ នេះរាត់រាយតាមចិត្តផ្សេងៗ កើតជាមួយនឹងចិត្តនេះ មិនកើតជាមួយនឹងចិត្តនោះ មានដូចតទៅនេះ :

| | | | |
|---|---|---|---|
| **វិតក្ក** | កើតជាមួយនឹងចិត្ត | ៥៥ ដួង | ពិស្ដារ |
| | មិនកើតជាមួយនឹងចិត្ត | ៦៦ ដួង | |
| **វិចារ** | កើតជាមួយនឹងចិត្ត | ៦៦ ដួង | ពិស្ដារ |
| | មិនកើតជាមួយនឹងចិត្ត | ៥៥ ដួង | |
| **អធិមោក្ខ** | កើតជាមួយនឹងចិត្ត | ៧៨ ដួង | សង្ខេប |
| | មិនកើតជាមួយនឹងចិត្ត | ១១ ដួង | |
| **វីរិយៈ** | កើតជាមួយនឹងចិត្ត | ៧៣ ដួង | សង្ខេប |
| | មិនកើតជាមួយនឹងចិត្ត | ១៦ ដួង | |
| **បីតិ** | កើតជាមួយនឹងចិត្ត | ៥១ ដួង | ពិស្ដារ |
| | មិនកើតជាមួយនឹងចិត្ត | ៧០ ដួង | |
| **ឆន្ទះ** | កើតជាមួយនឹងចិត្ត | ៦៩ ដួង | សង្ខេប |
| | មិនកើតជាមួយនឹងចិត្ត | ២០ ដួង | |

★- គិតពិស្ដារព្រោះត្រូវចែកគ្នាតាមឈាន ។

**៥. អកុសលចេតសិក** ចេតសិក ១៤ នេះមានជាតិជាអកុសលសុទ្ធ កើតជាមួយនឹងអកុសលចិត្តតែម្យ៉ាង ចែកជា ៥ ផ្នែក គឺ

(១). **មោចតុក្កៈ** (មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ) កើតជាមួយនឹងអកុសលចិត្តទាំង ១២ ដួង ។

(២). **លោតិកៈ** (លោភោ ទិដ្ឋិ មានោ) :

- លោភៈកើតក្នុងលោភមូលចិត្ត ៨ ដួង
- ទិដ្ឋិកើតក្នុងលោភទិដ្ឋិសម្បយុត្ត ៤ ដួង
- មានះកើតក្នុងលោភទិដ្ឋិវិប្បយុត្ត ៤ ដួង ។

(៣). **ទោចតុក្កៈ** (ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ) កើតជាមួយនឹងទោសមូលចិត្ត ២ ដួង ។

(៤). **ថីទុកៈ** (ថីនំ មិទ្ធំ) កើតជាមួយនឹងអកុសលចិត្តដែលជា សសង្ខារិក ៥ ដួង ។

(៥). **វិចិកិច្ឆា** កើតតែជាមួយនឹងមោហមូលចិត្តវិចិកិច្ឆា-សម្បយុត្ត ១ ដួងប៉ុណ្ណោះ ។

**៦. សោភណចេតសិក** ចេតសិកល្អចែកជា ៤ ផ្នែក គឺ សោភណសាធារណចេតសិក ១៩ មួយផ្នែក វិរតិ ៣ មួយផ្នែក

អប្បមញ្ញា ២ មួយផ្នែក បញ្ញិន្ទ្រិយមួយផ្នែក ។

**៧. សោភណសាធារណចេតសិក** មានចេតសិក ១៩ រាប់ចាប់ពីសទ្ធាដល់ចិត្តុជុកតា កើតទូទៅគ្រប់សោភណចិត្ត ៥៩ ដួង។

**៨. វិរតិចេតសិក ៣** កើតជាមួយនឹងចិត្ត ១៦ ដួងគឺ មហាកុសលចិត្ត ៨ ដួង និង លោកុត្តរចិត្ត ៨ ដួង (លោកុត្តរចិត្តពិស្តារ ៤០ ដួង) ។

**៩. អប្បមញ្ញាចេតសិក ២** កើតជាមួយនឹងចិត្ត ២៨ ដួងគឺ មហាកុសលចិត្ត ៨ ដួង មហាកិរិយាចិត្ត ៨ ដួង និង អប្បមញ្ញាឈានចិត្ត ១២ ដួង (វៀរបញ្ចមជ្ឈាន) ។

✶. មេត្តាគឺអទោសចេតសិក ឧបេក្ខាគឺតត្រមជ្ឈត្តតា-ចេតសិក។ ចេតសិក ២ នេះមិនចំពោះតែអប្បមញ្ញាឡើយ។

ចំណែកបញ្ញិន្ទ្រិយគឺបញ្ញាចេតសិក កើតជាមួយនឹងចិត្ត ៤៧ ដួង (ចិត្តប្រកបដោយបញ្ញាទាំងអស់ ៤៧ ដួង ដោយសង្ខេប) ។

ក្នុងចេតសិក ៥២ មានចេតសិក ១១ ដែលមិនទៀងហៅថា **អនិយតចេតសិក** គឺ **មានះ** ១ **ឥស្សា** ១ **មច្ឆរិយៈ** ១ **កុក្កុច្ចៈ** ១ **ថីនុកៈ** ២ **វិរតិ** ៣ និង **អប្បមញ្ញា** ២ ។ ដែលថាមិនទៀងព្រោះពេលខ្លះកើត ពេលខ្លះមិនកើត ។

**១០. ចិត្ត ៨៩ ឬ ១២១ ដួង** លោកិយចិត្ត ៨១ ដួង លោកុត្តរចិត្តសង្ខេប ៨ ដួង ត្រូវជាចិត្ត ៨៩ ដួងដោយសង្ខេប ។ ដោយពិស្តារគឺលោកិយចិត្ត ៨១ ដួងបូកនឹងលោកុត្តរចិត្តពិស្តារ ៤០ ដួង ត្រូវជា ១២១ ដួង ។

លោកុត្តរចិត្តសង្ខេប ៨ ដួងគឺ មគ្គ ៤ ផល ៤ ប៉ុន្តែដោយអំណាចមគ្គ ៤ ផល ៤ នេះ កើតក្នុងឈានចិត្តទាំង ៥ ទើបគិតសរុប ៨ ដួង × ឈាន ៥ = ៤០ ដួង ។

**១១. មហាកុសលចិត្ត** សូមពុទ្ធបរិស័ទ ទន្ទេញឈ្មោះមហាកុសលចិត្ត ៨ ដួងនេះឱ្យចាំ ។ តាមពិត ត្រូវទន្ទេញតែមហា-កុសលទី ១ ប៉ុណ្ណោះ ចិត្ត ៧ ដួងក្រោយទៀតគ្រាន់តែចំណាំៗ ។ មហាកុសលចិត្តទី ១ ត្រូវចាំថាមាន ៣ កំណាត់បន្តគ្នា គឺ

- កំណាត់ទី ១ សោមនស្សសហគត (ត្រូវអានថា សោម-នស្សសហគតៈ) ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ។
- កំណាត់ទី ២ ញាណសម្បយុត្ត (ត្រូវអានថា ញាណ-សម្បយុត្តៈ) ប្រកបជាមួយនឹងបញ្ញា។
- កំណាត់ទី ៣ អសង្ខារិក (អានជាបាលីថា អសង្ខារិកៈ) មានកម្លាំងខ្លាំង អត់មានអ្នកបបួលដឹកនាំឡើយ ។

មហាកុសលចិត្តទី ២ ខុសពីមហាកុសលចិត្តទី ១ នៅត្រង់កំណាត់ទី ៣ គឺសសង្ខារិក មានកម្លាំងខ្សោយដោយសារគេបបួលដឹកនាំ ។

មហាកុសលចិត្តទី ៣ ខុសពីមហាកុសលចិត្តទី ១ នៅត្រង់កំណាត់ទី ២ គឺញាណវិប្បយុត្ត ប្រាសចាកបញ្ញា ។

មហាកុសលចិត្តទី ៤ ជាញាណវិប្បយុត្តហើយជាសសង្ខា-រិកទៀត ។

មហាកុសលចិត្ត ៤ ដួងបន្តទៅទៀត គឺឧបេក្ខាសហគត (អានថា ឧបេក្ខាសហគតៈ) ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា ។

ចំណែកចេតសិកដែលប្រកបជាមួយនឹងមហាកុសលចិត្ត ៨ ដួងនេះ មានតែពីរពួកប៉ុណ្ណោះ គឺពួកអញ្ញសមានាចេតសិក ១៣ និង ពួកសោភណចេតសិក ២៥ ។

មហាកុសលចិត្ត ៤ ដួង ដែលប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា គឺមានបីតិចេតសិក បើប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា អត់មានបីតិចេតសិកទេ ។

មហាកុសលចិត្តណា ដែលប្រកបដោយបញ្ញា ( ញាណ-សម្បយុត្ត ) គឺមានបញ្ញាចេតសិក បើជាញាណវិប្បយុត្តវិញប្រាកដជារៀរបញ្ញាហើយ ។

ចំណែកអសង្ខារិក និង សសង្ខារិក គឺមានចេតសិកចំនួនដូចគ្នា មួយគូៗ ។

មហាកុសលចិត្ត ៨ ដួង និង ចេតសិកសម្បយុត្ត ៣៨ នេះ ចែកជាខន្ធ ៤ គឺ វេទនាចេតសិក (សោមនស្សវេទនាក្តី ឧបេក្ខាវេទនាក្តី ) ជាវេទនាខន្ធ សញ្ញាចេតសិក ជាសញ្ញាខន្ធ នៅសល់ចេតសិក ៣៦ ទៀតជាសង្ខារក្ខន្ធ ចំណែកចិត្តទាំង ៨ ដួង ជាវិញ្ញាណក្ខន្ធ ។

មហាកុសលចិត្ត៨ ដួងនិងចេតសិកសម្បយុត្តនេះឯង ដែលប្រព្រឹត្តទៅក្នុងបុញ្ញកិរិយាវត្ថុ ១០ មានទាន សីល ភាវនាជាដើម ជានាមក្ខន្ធ ៤ សុទ្ធៗ ឬថាជា **ធម្ម** សុទ្ធៗ ជាទីតាំងនៃសតិថ្នាក់សតិប្បដ្ឋាន ចម្រើនវិបស្សនា ឃើញ**ធម្ម** កំពុងប្រាកដ សត្វ បុគ្គល អ្នកឱ្យទាន រក្សាសីល ចម្រើនភាវនាមិនមានឡើយ ។

ក្នុងបច្ចុប្បន្នសម័យ បើពុទ្ធបរិស័ទមិនបានសិក្សាអភិធម្ម មានមហាកុសលចិត្ត ៨ ដួងនិងចេតសិកសម្បយុត្តជាដើមនេះទេ ពុទ្ធបរិស័ទលំបាកនឹងជឿណាស់ថា ជីវិតជាប្រក្រតីមានសុទ្ធតែ**ធម្ម** ហើយជាទីតាំងនៃសតិប្បដ្ឋានវិបស្សនា ដូច្នេះសូមពុទ្ធបរិស័ទខំប្រឹងសិក្សាអភិធម្មក្នុងជីវិតរាល់ថ្ងៃ ជាប្រយោជន៍ដល់សតិប្បដ្ឋានវិបស្សនា អប់រំភាវនាទៅតាមមាគ៌ាព្រះបរមសាស្តា ។

**១២. រូបាវចរកុសលចិត្ត** នេះជាកុសល ១ ផ្នែកទៀត ផ្សេងពីមហាកុសល ។ មហាកុសលនៅក្នុងភូមិកាម ចំណែករូបាវចរកុសលនៅក្នុងភូមិរូប (រូបជ្ឈាននាំឱ្យបដិសន្ធិក្នុងរូបព្រហ្ម) ។ ចម្រើនអសុភកម្មដ្ឋាន ១០ និងកាយគតាសតិ បានសម្រេចត្រឹមបឋមជ្ឈាន ចម្រើនមេត្តា ករុណា មុទិតា បានសម្រេចពីបឋមជ្ឈានដល់ចតុត្ថជ្ឈាន ចម្រើនឧបេក្ខាព្រហ្មវិហារ បានសម្រេចបញ្ចមជ្ឈាន ចម្រើនអានាបាណ បានសម្រេចពីបឋមជ្ឈានដល់បញ្ចមជ្ឈាន ចម្រើនកសិណ ១០ បានសម្រេចពីបឋមជ្ឈានដល់បញ្ចមជ្ឈាន ហើយជាឧបនិស្សយប្បច្ច័យដល់ការចម្រើននូវអរូបជ្ឈានទៀតផង ។

ចម្រើនអនុស្សតិ ៨ (វៀរកាយគតាសតិ ១ អានាបាណស្សតិ ១) ចតុធាតុវវត្ថាន និង អាហារេបដិកូលសញ្ញា កម្មដ្ឋាន ១០ នេះ បានត្រឹមឧបចារសមាធិប៉ុណ្ណោះ ។ ឧបចារសមាធិ គឺមហាកុសលញាណសម្បយុត្ត មិនមែនជារូបាវចរកុសលទេ តែជាមហាកុសល ដែលចូលជិតអប្បនាសមាធិទើបហៅថាឧបចារសមាធិ ។ អប្បនាសមាធិគឺសមាធិក្នុងឈានចិត្តមានបឋមជ្ឈានជាដើម ។

រូបាវចរកុសលចិត្ត និង ចេតសិកសម្បយុត្ត ចែកជាឈាន ៥ ដោយបញ្ចកន័យ បើដោយចតុក្កន័យ ឈានមានត្រឹមតែ ៤

ប៉ុណ្ណោះ ព្រោះទុតិយជ្ឈានបានលះនូវវិតក្កនិងវិចារហើយស្រេច ដូច្នេះទុតិយជ្ឈានក្នុងចតុក្កន័យស្មើនឹងតតិយជ្ឈានក្នុងបញ្ចកន័យ។

**១៣~ អរូបាវចរកុសលចិត្ត** នេះជាកុសល ១ ផ្នែកទៀត នៅក្នុងភូមិអរូប ជាអប្បនាសមាធិខ្ពស់ជាងរូបាវចរកុសល ។ អរូប ទី២ មានអរូប ទី១ ជាអារម្មណ៍ អរូប ទី៤ មានអរូប ទី៣ ជាអារម្មណ៍ ចំណែកអរូប ទី១ និងអរូប ទី៣ មានបញ្ញត្តិជាអារម្មណ៍។

តាមពិត អរូបជ្ឈាននេះ តាំងនៅក្នុងបញ្ចមជ្ឈានហ្នឹងឯង ព្រោះមានអង្គឈាន ២ គឺ ឧបេក្ខា និង ឯកគ្គតា ប៉ុន្តែខុសពីបញ្ចមជ្ឈានរូបាវចរនៅត្រង់អារម្មណ៍ ។ អរូបជ្ឈានកុសលនាំឱ្យបដិសន្ធិក្នុងអរូបព្រហ្ម ។

**១៤~ លោកុត្តរកុសលចិត្ត** នេះជាកុសល ១ ផ្នែកទៀត នៅក្នុងភូមិលោកុត្តរ ជាអប្បនាលោកុត្តរកុសល មានព្រះនិព្វានជាអារម្មណ៍ ។

លោកុត្តរកុសល ពោលដោយសង្ខេបគឺមគ្គ ៤ ហ្នឹងឯង ប៉ុន្តែដោយអំណាចមគ្គ ៤ នេះកើតតាមឈានទាំង ៥ ទើបពោលដោយពិស្តារត្រូវជា ២០ ដួងចេតសិក ៣៦ ។ ក្នុងមគ្គចិត្តមួយដួងៗ មានចេតសិក ៣៦ (មគ្គចិត្តក្នុងបឋមជ្ឈាន ) ក្នុងចេតសិក ៣៦

មានចេតសិក ៨ គឺបញ្ញា ១ វិតក្ក ១ វិរតិ ៣ វីរិយៈ ១ សតិ ១ និង ឯកគ្គតា ១ ចេតសិក ៨ នេះជាមគ្គសច្ច ។

✶- អប្បមញ្ញា ២ មានតែបញ្ញត្តិជាអារម្មណ៍ ដូច្នេះទើប មិនប្រកបក្នុងលោកុត្តរចិត្ត ។

✶- វិរតិ ៣ កើតក្នុងមហាកុសល មានតែអកុសល និង រូបដែលកើតអំពីអកុសលប៉ុណ្ណោះជាអារម្មណ៍ ទើបមិនកើតក្នុង មហគ្គតកុសលចិត្ត ៩ ដួង (រូបាវចរកុសលចិត្ត ៥ ដួង +អរូបាវចរ-កុសលចិត្ត ៤ ដួង ) ហើយវិរតិ ៣ ក្នុងមហាកុសលចិត្ត មាន អារម្មណ៍ជាបច្ចុប្បន្ន និង អនាគត មិនមានអារម្មណ៍ជាអតីតទេ ចំណែកវិរតិ ៣ ជាលោកុត្តរកុសល មានព្រះនិព្វានជាអារម្មណ៍ សមុច្ឆេទនូវកិលេសដែលនាំឱ្យប្រព្រឹត្តនូវទុច្ចរិត ។

**១៥- លោភមូលចិត្ត** ចិត្តដែលមានលោភចេតសិកជា មូល មាន ៨ ដួង រាប់រៀងដូចជាមហាកុសលចិត្ត ៨ ដួងដែរ ខុស គ្នាត្រង់កំណាត់កណ្តាល គឺ ទិដ្ឋិគតសម្បយុត្ត ប្រកបដោយការ យល់ខុស និង ទិដ្ឋិគតវិប្បយុត្ត ប្រាសចាកការយល់ខុស ។

- សោមនស្សរីករាយក្នុងលោភមូលចិត្តនេះ គឺសោមនស្ស-វេទនាជាអកុសល មិនមែនដូចសោមនស្សវេទនាក្នុងមហាកុសល-ចិត្តទេ ។

- ទិដ្ឋិគតវិប្បយុត្ត ប្រាសចាកទិដ្ឋិតែមានមានះ ប៉ុន្តែពេលខ្លះក៏មិនមាននូវមានះដែរ ។

- សសង្ខារិកមានថីនមិទ្ធៈ ប៉ុន្តែពេលខ្លះក៏អត់ថីនមិទ្ធៈដែរ។

**១៦. ទោសមូលចិត្ត** មានត្រឹមតែ២ ដួងប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅជាមួយនឹងទោមនស្សវេទនាតែម្យ៉ាង និង ប្រកបដោយបដិឃៈ គឺទោសចេតសិកជានិច្ច គ្រាន់តែមួយដួងជាអសង្ខារិក មួយដួងទៀតជាសសង្ខារិក ។

**១៧. មោហមូលចិត្ត** មាន ២ ដួងប្រព្រឹត្តទៅជាមួយ-នឹងឧបេក្ខាវេទនាដូចគ្នា គឺ ១ ដួងប្រកបដោយវិចិកិច្ឆា និង ១ ដួងទៀតប្រកបដោយឧទ្ធច្ចៈ ។

✶. អកុសលចិត្ត ១២ ដួង និង ចេតសិកសម្បយុត្តនេះឯងជាតួបាបអកុសល កាលណាដែលពុទ្ធបរិស័ទបានយល់ ស្គាល់តួបាបពិតប្រាកដ និង ស្គាល់មហាកុសលច្បាស់ ទើបមិនប្រកាន់មង្គលភ្ញាក់ផ្អើល ។

**១៨. អកុសលវិបាកចិត្ត** អកុសលវិបាកគឺជាចិត្ត និងចេតសិកកើតឡើងដឹងអារម្មណ៍មិនល្អ ដោយបរមត្ថអត់មានសត្វបុគ្គលណា ជាអ្នកទទួលវិបាកកម្មឡើយ ។

អកុសលវិបាកតាមផ្លូវកាយ ប្រកបដោយទុក្ខវេទនា ព្រោះអាស្រ័យមហាភូតរូបមកប៉ះខ្ទប់នឹងកាយប្បសាទ ។

អកុសលវិបាកចិត្ត ៧ ដួង ជាវិញ្ញាណធាតុ ៧ រីឯចេតសិក ១០ ជាធម្មធាតុ ។

អកុសលវិបាកចិត្ត ៥ ដួងខាងដើម កើតតាមទ្វារមួយៗ រៀងៗខ្លួន ។ អកុសលវិបាកចិត្តដួងទី ៦ ជាមនោធាតុ កើតតាមទ្វារទាំង ៥ បាន បន្ទាប់ពីបញ្ចវិញ្ញាណណាមួយរលត់ទៅធ្វើសម្បដិច្ឆន្នកិច្ច គឺកិច្ចទទួលអារម្មណ៍បន្តពីបញ្ចវិញ្ញាណណាមួយនោះ ។ អកុសលវិបាកចិត្តដួងទី ៧ ជាមនោវិញ្ញាណធាតុ កើតតាមបញ្ចទ្វារដោយសន្តីរណកិច្ច គឺកិច្ចពិនិត្យអារម្មណ៍បន្តពីសម្បដិច្ឆន្នកិច្ច កើតតាមទ្វារ ៦ ដោយតទាលម្ពណកិច្ចបន្ទាប់ពីជវនកិច្ច កើតក្រៅទ្វារ ៦ ដោយបដិសន្ធិកិច្ច ភវង្គកិច្ច និងចុតិកិច្ចក្នុងអបាយភូមិ ៤ ទើបមានបញ្ញត្តិថាសត្វកើត ។

**១៩~ កុសលវិបាកអហេតុកចិត្ត** មាន ៨ ដួងលើសអកុសលវិបាក ១ ដួង នៅត្រង់ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា មានអារម្មណ៍ជាអតិឥដ្ឋារម្មណ៍ គឺអារម្មណ៍ល្អដ៏ក្រៃលែងតាមទ្វារ ៦ ។

អតិឥដ្ឋារម្មណ៍ក៏ជាអារម្មណ៍នៃកុសលវិបាកអហេតុកចិត្ត ៦ ដួងទៀតដែរ (វៀរឧបេក្ខាសន្តីរណៈ) ប៉ុន្តែកុសលវិបាកអហេតុក-ចិត្តនោះៗ មិនប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនាទេ ។

កាយវិញ្ញាណកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងសុខ-វេទនា (ពាក្យថាប្រព្រឹត្តទៅគឺប្រកបជាមួយហ្នឹងឯង) ។

អ្នកសោយសុខ ឬ សោយទុក្ខតាមផ្លូវកាយមិនមានឡើយ គឺ មានតែសុខវេទនាកុសលវិបាក និង ទុក្ខវេទនាអកុសលវិបាក តែប៉ុណ្ណោះ។

កុសលវិបាកមនោវិញ្ញាណធាតុ ដួងទី ៨ ជាអហេតុកវិបាក ប្រកបដោយឧបេក្ខាវេទនា ក្រៅអំពីធ្វើកិច្ចក្នុងទ្វារ ៦ ហើយ នៅធ្វើកិច្ច បដិសន្ធិ ភវង្គ ចុតិ ក្នុងកាមសុគតិភព សម្រាប់មនុស្ស និង ទេវតាថ្នាក់ទាបដែលខ្វះបុណ្យ ។

**២០~ មហាវិបាកចិត្ត** ក្រៅអំពីធ្វើតទាលម្ពណកិច្ច គឺ កិច្ចកាន់យកអារម្មណ៍ដែលជវន៍សោយហើយតាមទ្វារទាំង ៦ នៅធ្វើកិច្ចបដិសន្ធិ ភវង្គ ចុតិ ក្នុងកាមសុគតិភព ៧ ជាន់ទៀត នេះឯង គឺជាឧបបត្តិភព សត្វបុគ្គលអ្នកកើតមិនមានឡើយ មនុស្សទេវតា គឺបញ្ញត្តចំពោះកំណើតនោះៗឯង ។

អកុសលកម្មនាំឱ្យកើតអកុសលវិបាកចិត្ត ៧ ដួង ចំណែក មហាកុសលកម្មនាំឱ្យកើតកុសលវិបាកចិត្ត ១៦ ដួង រួមបានជា កាមាវចរវិបាកចិត្ត ២៣ ដួង និង ចេតសិក ៣៣ ។

**២១. រូបាវចរវិបាកចិត្ត** មាន ៥ ដួង ជាវិបាករបស់ រូបាវចរកុសលកម្មមួយៗ គ្រប់ឈានទាំង ៥ ។

រូបាវចរវិបាកចិត្ត និង ចេតសិកនេះ ធ្វើកិច្ចបដិសន្ធិ ភវង្គ ចុតិ ក្នុងរូបព្រហ្ម ១៥ ជាន់ដោយវិបាកផ្សេងៗគ្នា ។

**២២. អរូបាវចរវិបាកចិត្ត** មាន ៤ ដួង ជាវិបាករបស់ អរូបាវចរកុសលកម្មមួយៗ រៀងៗខ្លួន កាលដែលកើតឡើងរមែង ធ្វើកិច្ចបដិសន្ធិ ភវង្គ ចុតិ ក្នុងអរូបព្រហ្ម ៤ ជាន់តាមអរូបាវចរ-វិបាកចិត្តនោះៗ ។

កាមាវចរវិបាកចិត្ត ២៣ ដួង និង មហគ្គតវិបាកចិត្ត ៩ ដួង ត្រូវជាលោកិយវិបាកចិត្ត ៣២ ដួង ចេតសិក ៣៥ ។

**២៣. លោកុត្តរវិបាកចិត្ត** បានដល់ ផលចិត្ត ៤ ដួង បើដោយពិស្តារ ២០ ដួង ព្រោះគិតតាមឈានទាំង ៥ ធ្វើតែ ជវនកិច្ចក្នុងមនោទ្វារប៉ុណ្ណោះ មានព្រះនិព្វានជាអារម្មណ៍សុទ្ធ ។

**២៤. អហេតុកកិរិយា** ក្នុងពាក្យថា អហេតុកៈទាំងអស់

ព្រោះមិនមានហេតុ ៦ ណាមួយកើតជាមួយ ។ ហេតុ ៦ គឺ អកុសលហេតុ ៣ បានដល់ លោភចេតសិក ទោសចេតសិក និង មោហចេតសិក ហេតុ ៣ ទៀតជាកុសលហេតុ និងជាអព្យាកតហេតុ បានដល់ អលោភចេតសិក អទោសចេតសិក និង បញ្ញាចេតសិក ។

**២៥. បញ្ចទ្វារាវជ្ជនចិត្ត** ធ្វើអាវជ្ជនកិច្ច គឺកិច្ចរាវរក អារម្មណ៍ក្នុងបញ្ចទ្វារមុននឹងបញ្ចវិញ្ញាណណាមួយកើតឡើង ជា កិរិយាមនោធាតុ ។ មនោធាតុមាន ៣ ដួង គឺ ២ ដួងទៀតធ្វើ សម្បដិច្ឆន្នកិច្ចជាវិបាកមនោធាតុ ។ ដែលជាមនោធាតុ ព្រោះមិន បានអាស្រ័យបសាទរូប ៥ កើតឡើង និង ព្រោះមិនបានដឹង ធម្មារម្មណ៍ ។

**២៦. មនោទ្វារាវជ្ជនចិត្ត** ធ្វើអាវជ្ជនកិច្ច គឺកិច្ចរាវរក អារម្មណ៍ក្នុងមនោទ្វារ និង ធ្វើវោដ្ឋព្វនកិច្ចក្នុងបញ្ចទ្វារ ជា អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា ។

**២៧. ហសិតុប្បាទចិត្ត** ជាចិត្តរបស់ព្រះអរហន្ត ជា បច្ច័យឱ្យញញឹម ធ្វើជវនកិច្ចក្នុងទ្វារទាំង ៦ ជាអហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយសោមនស្សវេទនា ។

✶. អហេតុកចិត្តទាំងអស់ ១៨ ដួង គឺ អកុសលវិបាកចិត្ត ៧ ដួង កុសលវិបាកអហេតុកចិត្ត ៨ ដួង និង អហេតុកកិរិយា-ចិត្ត ៣ ដួង ។

✶. អហេតុកចិត្ត ១៨ ដួង គឺ ទ្វិបញ្ចវិញ្ញាណ ១០ ដួង ជាវិញ្ញាណធាតុ ៥ ចិត្ត ៣ ដួងជាមនោធាតុ នៅសល់ ៥ ដួង ទៀតជាមនោវិញ្ញាណធាតុ រួមបានជាវិញ្ញាណធាតុ ៧ ។

✶. អហេតុកចិត្ត ១៨ ដួង ប្រកបដោយសុខវេទនា ១ ដួង ប្រកបដោយទុក្ខវេទនា ១ ដួង ប្រកបដោយសោមនស្ស- វេទនា ២ ដួង នៅ ១៤ ដួងទៀត ប្រកបដោយឧបេក្ខាវេទនា ។

✶. អហេតុកចិត្ត ១៨ ដួងគឺ ១០ ដួងមានចេតសិកប្រាំពីរៗ ៥ ដួងមានចេតសិកដប់ៗ ២ ដួងមានចេតសិកដប់មួយៗ ចំណែក ហសិតុប្បាទចិត្តមានចេតសិក ១២ ។

មានតែពួកអញ្ញសមានាចេតសិកប៉ុណ្ណោះ ដែលប្រកបជា-មួយនឹងអហេតុកចិត្ត ១៨ ដួង ឆន្ទចេតសិកមិនកើតក្នុងអហេតុក-ចិត្តទាំង ១៨ ដួង បីតិប្រកបក្នុងអហេតុកចិត្តដែលប្រព្រឹត្តទៅជា-មួយនឹងសោមនស្សវេទនា ២ ដួង វីរិយៈប្រកបក្នុងអហេតុក-កិរិយាមនោវិញ្ញាណធាតុ ២ ដួង នៅបកិណ្ណកចេតសិក ៣ ទៀតគឺ វិតក្ក វិចារ អធិមោក្ខ កើតក្នុងអហេតុកចិត្ត ៨ ដួង ។

✶- អហេតុកចិត្ត ១៨ ដួង និង អកុសលចិត្ត ១២ ដួងគឺជា អសោភណចិត្ត ៣០ ដួង ព្រោះមិនមានសោភណចេតសិកកើតរួមជាមួយ ចំណែកចិត្ត ៥៩ ដួងដោយសង្ខេប ឬ ៩១ ដួងដោយពិស្តារ ហៅថាសោភណចិត្ត ។

**២៨- មហាកិរិយាចិត្ត** ចិត្ត ៨ ដួងនេះ មានតែព្រះអរហន្តប៉ុណ្ណោះ ធ្វើជវនកិច្ចក្នុងទ្វារទាំង ៦ មិនមានវិរតិ ៣ ព្រោះព្រះអរហន្តមិនមានបាបអកុសលក្នុងសន្តាន ។

មហាកិរិយាចិត្ត ៨ ដួង និង អហេតុកកិរិយាចិត្ត ៣ ដួង ត្រូវជាកាមាវចរកិរិយាចិត្ត ១១ ដួង ។

**២៩- មហគ្គតកិរិយាចិត្ត** ចិត្ត ៩ ដួងនេះគឺរូមរូបាវចរកិរិយាចិត្ត ៥ ដួង និង អរូបាវចរកិរិយាចិត្ត ៤ ដួង ជាចិត្តរបស់ព្រះអរហន្ត ធ្វើជវនកិច្ចក្នុងមនោទ្វារ ។

**៣០- កាមាវចរចិត្ត** គឺជាចិត្តនៅក្នុងភូមិកាម ជាចិត្តដែលមានវត្ថុកាមគឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍ មាន ៥៤ ដួង ចេតសិកសម្បយុត្ត ៥២ ។

**៣១- រូបាវចរចិត្ត** ជាចិត្តនៅក្នុងភូមិរូប ព្រោះជាការចម្រើនរូបជ្ឈាន ឯវិបាកកើតក្នុងរូបព្រហ្ម។ ចិត្តក្នុងភូមិរូបនេះមាន

បីជាតិ មិនមានអកុសលជាតិទេ ។

**៣២. អរូបាវចរចិត្ត** ជាចិត្តនៅក្នុងភូមិអរូប ព្រោះជាការចម្រើនអរូបជ្ឈាន ឯវិបាកកើតក្នុងអរូបព្រហ្ម ។ ចិត្តក្នុងភូមិអរូបនេះក៏មានតែបីជាតិដែរ ។

*. សរុបចិត្តពីរភូមិគឺរូបភូមិ និង អរូបភូមិចូលគ្នា បានជាមហគ្គតចិត្ត ២៧ ដួង ចេតសិក ៣៥ ។

**៣៣. លោកុត្តរចិត្ត** មានតែពីរជាតិប៉ុណ្ណោះ គឺកុសល-ជាតិ និង វិបាកជាតិ រាប់ដោយសង្ខេបគឺមគ្គ ៤ ផល ៤ ។

**៣៤. វេទនាសង្គហៈ** គឺជាការរាប់វេទនាចេតសិកក្នុងចិត្ត ១២១ ដួង ព្រោះថាវេទនានេះជាតួសោយអារម្មណ៍ ហើយសត្វលោកភ្ញាក់ផ្អើលក្នុងជីវិត ដោយសារមិនដឹងថាអ្វីសោយ ការសោយរបស់អ្នកណា និង ព្រោះហេតុអ្វីទើបសោយ ។

**៣៥. សុខវេទនា ១** ជាកុសលវិបាកអហេតុកៈ កើតព្រោះកុសលកម្មជាបច្ច័យ និង ព្រោះផស្សៈជាបទដ្ឋាន ។

**៣៦. ទុក្ខវេទនា ១** ជាអកុសលវិបាកផ្លូវកាយ កើតព្រោះអកុសលកម្មជាបច្ច័យ និង ព្រោះផស្សៈជាបទដ្ឋាន ។ អ្នកសោយជាសត្វបុគ្គលណានោះមិនមានទេ មានតែវេទនាប៉ុណ្ណោះ

កើតឡើងសោយហើយរលត់ទៅវិញ សញ្ញា សង្ខារ វិញ្ញាណ កើតរលត់ជាមួយវេទនា ឯចំណែករូបជាធាតុមិនដឹងដូចសាកសព។

**៣៧- សោមនស្សសន្តីរណៈ ១** គឺកុសលវិបាកអហេតុកមនោវិញ្ញាណធាតុ ប្រកបដោយសោមនស្សវេទនា ហៅឈ្មោះតាមកិច្ច ១ ថាសោមនស្សសន្តីរណៈ ។

**៣៨- សោមនស្សហសិតុប្បាទចិត្ត ១** គឺអហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយសោមនស្សវេទនា ហៅត្រឹមហសិតុប្បាទចិត្ត ក៏ស្តាប់បានដែរ ។

**៣៩- សោមនស្សលោភមូល ៤** គឺលោភមូលចិត្ត ៤ ដួង ដែលប្រកបដោយសោមនស្សវេទនា ។

**៤០- សោមនស្សមហាកុសល ៤** គឺមហាកុសលចិត្ត ៤ ដួង ដែលប្រកបដោយសោមនស្សវេទនា ។

**៤១- សោមនស្សមហាវិបាក ៤** គឺមហាវិបាកចិត្ត ៤ ដួង ដែលប្រកបដោយសោមនស្សវេទនា ។

**៤២- សោមនស្សមហាកិរិយា ៤** គឺមហាកិរិយាចិត្ត ៤ ដួង ដែលប្រកបដោយសោមនស្សវេទនា ។

*- មហាកុសលចិត្ត ៨ ដួង មហាវិបាកចិត្ត ៨ ដួង និង

មហាកិរិយាចិត្ត ៨ ដួង ត្រូវជាកាមាវចរសោភណចិត្ត ២៤ ដួង ។ ក្នុង ២៤ ដួងនេះ ប្រកបដោយសោមនស្ស ១២ ដួង ប្រកបដោយឧបេក្ខា ១២ ដួង ជាញាណសម្បយុត្ត ១២ ដួង ជាញាណវិប្បយុត្ត ១២ ដួង ជាអសង្ខារិក ១២ ដួង ជាសសង្ខារិក ១២ ដួង ។

**៤៣. សោមនស្សបឋមជ្ឈាន ១១** បានជាមានដល់ ១១ ដួង ព្រោះរូបាវចរចិត្ត ៣ ដួងគឺកុសល ១ វិបាក ១ កិរិយា ១ និង មគ្គចិត្ត ៤ ដួង ផលចិត្ត ៤ ដួង ប្រកបដោយសោមនស្ស-វេទនាទាំងអស់ ហើយសោមនស្សវេទនានេះគឺជាអង្គឈាន ។

★. វិតក្កចេតសិកកើតក្នុងកាមាវចរចិត្ត ៤៤ (វៀរទ្វិបញ្ច-វិញ្ញាណ ១០) រួមនឹងបឋមជ្ឈានចិត្ត ១១ ត្រូវជា ៥៥ ដួង មិនកើតក្នុងចិត្ត ៦៦ ដួងផ្សេងទៀត ។

**៤៤. សោមនស្សទុតិយជ្ឈាន ១១** វៀរវិតក្កចេតសិក (បញ្ចកន័យ) នៅមានវិចារ ដូច្នេះវិចារចេតសិកកើតក្នុងចិត្តដែលមានវិតក្កចេតសិក ៥៥ ដួងហើយ រួមនឹងទុតិយជ្ឈានចិត្ត ១១ ដួងទៀត ត្រូវជា ៦៦ ដួង មិនកើតក្នុងចិត្ត ៥៥ ដួងផ្សេងទៀត ។

**៤៥. សោមនស្សតតិយជ្ឈាន ១១** វៀរវិចារចេតសិកចេញទៀត នៅមានបីតិ ដូច្នេះបីតិចេតសិកកើតក្នុងឈានចិត្ត

ទាំង ៣ ថ្នាក់ ត្រូវជា ៣៣ ដួង រួមនឹងសោមនស្សកាមាវចរចិត្ត ១៨ ដួង ត្រូវជា ៥១ ដួង បីតិមិនមានក្នុងចិត្ត ៧០ ដួង ។

**៤៦~ សោមនស្សចតុត្ថជ្ឈាន ១១** មិនមានបីតិ ប៉ុន្តែនៅប្រកបជាមួយនឹងសោមនស្សវេទនា ដោយអំណាចតត្រមជ្ឈត្ត-តាចេតសិកជាឈានូបេក្ខា ។

**៤៧~ ទោមនស្សវេទនា** គឺជាទុក្ខផ្លូវចិត្ត កើតរួមតែជាមួយនឹងទោសមូលចិត្ត ២ ដួងប៉ុណ្ណោះ ។

**៤៨~ ឧបេក្ខាអកុសលវិបាក ៦** វៀរទុក្ខសហគត-កាយវិញ្ញាណ ១ ដួងចេញ ។

**៤៩~ ឧបេក្ខាកុសលវិបាកអហេតុកៈ ៦** វៀរសុខ-សហគតកាយវិញ្ញាណ ១ ដួង និង សោមនស្សសន្តីរណៈ ១ ដួង។

**៥០~ ឧបេក្ខាកិរិយាអហេតុកៈ ២** វៀរហសិតុប្បាទ-ចិត្ត (ហសិតុប្បាទចិត្តប្រកបដោយសោមនស្ស)។

**៥១~ ឧបេក្ខាអកុសល ៦** គឺលោភមូលចិត្តប្រកបដោយឧបេក្ខា ៤ ដួង និង មោហមូលចិត្ត ២ ដួង ។

**៥២,៥៣,៥៤~** គឺឧបេក្ខាក្នុងកាមាវចរសោភណចិត្ត ១២ ដួង (កាមាវចរសោភណចិត្តទាំងអស់ មាន ២៤ ដួង)។

ក្នុងកាមាវចរចិត្ត ៥៤ ដួង មានអសោភណចិត្ត ៣០ ដួងគឺ អកុសលចិត្ត ១២ ដួង និង អហេតុកចិត្ត ១៨ ដួង នៅសល់ ២៤ ដួងទៀតជាសោភណចិត្ត ។

**៥៥,៥៦,៥៧~** គឺឧបេក្ខាក្នុងបញ្ចមជ្ឈានចិត្ត ២៣ ដួង ។

**៥៨~ ហេតុសង្គហៈ** ជាការរាប់ប្រមូលនូវហេតុរបស់ចិត្ត ព្រោះហេតុជាឫសគល់ ប្រៀបដូចជាឫសកែវនៃដើមឈើ ។ អកុសលធម៌ទាំងឡាយ មានលោភៈ ទោសៈ មោហៈ ជាឫសគល់ ចំណែកកុសលធម៌ទាំងឡាយ និង អព្យាកតធម៌ខ្លះ មានឫសគល់គឺ អលោភៈ អទោសៈ និង អមោហៈ ។

**៥៩~ អហេតុកចិត្ត ១៨** មិនមែនកើតឡើងឯងៗដោយ អត់បច្ច័យនោះទេ ពាក្យថាអហេតុកៈនេះ សំដៅត្រង់អត់មាន ហេតុគឺចេតសិក ៦ ជាតួហេតុណាមួយ ប្រកបជាមួយ ។ នៅក្នុង ចិត្តទាំង ១៨ ដួង មានតែអញ្ញសមានាចេតសិកប៉ុណ្ណោះ ដូចបាន ពន្យល់ក្នុងចំណុចលេខ ២៧ ហើយ ។

**៦០~ ឯកហេតុកចិត្ត ២** ក្នុងមោហមូលចិត្តមួយដួងៗ មានចេតសិក ១៥ នៅក្នុងមោចតុកៈមានមោហចេតសិក នេះឯង ជាតួហេតុ ចំណែកមោហមូលចិត្ត ១ ដួង និង ចេតសិក ១៤ ទៀត

មិនមែនជាហេតុ តែប្រកបដោយហេតុ ១ ។

**៦១~ ទុហេតុកចិត្ត ២២** គឺលោភមូលចិត្ត ៨ ដួង ទោសហេតុមិនមានក្នុងលោភមូលចិត្តទេ ដូច្នេះទើបក្នុងលោភ-មូលចិត្តមួយៗ មានហេតុត្រឹមតែ ២ គឺលោភហេតុក្នុងលោតិកៈ និង មោហហេតុក្នុងមោចតុកៈ សូម្បីចេតសិកដែលប្រកបជាមួយ-នឹងហេតុ ក៏ឈ្មោះថាមានហេតុដែរ គឺ សហេតុកចេតសិក ។

**៦២~ ទោសមូលចិត្ត ២** លោភហេតុមិនមានក្នុង ទោសមូលចិត្តទេ ទាំងដែលអកុសលហេតុទាំង ៣ ក៏មិនមានក្នុង ចិត្តដទៃក្រៅអំពីអកុសលចិត្តដែរ តើគួរប្រកាន់លោភៈ ទោសៈ មោហៈ ថាជាយើង ខ្លួនយើងដែរទេ ?

**៦៣,៦៤,៦៥~** កាមាវចរសោភណញាណវិប្បយុត្ត ១២ ដួង នៅក្នុងសោភណចេតសិកសម្បយុត្តវៀរបញ្ញា ដូច្នេះទើបចិត្ត ១២ ដួងនេះមានហេតុតែ ២ ។

**៦៦,៦៧,៦៨,៦៩~** តិហេតុកចិត្ត ៤៧ ដួងដោយសង្ខេប ដោយពិស្ដារ ៧៩ ដួង ។ ក្នុងចិត្ត ៤៧ ដួងឬ ៧៩ ដួងនេះ សុទ្ធតែ មានបញ្ញា កាលណា ចិត្តមានបញ្ញា កាលនោះ ចិត្តត្រូវតែមាន អលោភហេតុ និង អទោសហេតុជានិច្ច ។

កាមាវចរចិត្ត ៤២ ដួងប្រាសចាកបញ្ញា។ ក្នុងកាមាវចរចិត្ត ៤២ ដួងនេះ មាន ១២ ដួងជាសោភណចិត្ត រីឯ ៣០ ដួងទៀតជាអសោភណចិត្ត។ ក្នុងអសោភណចិត្ត ៣០ ដួង មាន ១២ ដួងជាអកុសលចិត្ត រីឯ ១៨ ដួងទៀតជាអហេតុកចិត្ត។ កាលដែលពោលអំពី **អហេតុកា ធម្មា** ពួកធម៌ជាអហេតុកៈ បានដល់អហេតុកចិត្ត ១៨ ដួង ចេតសិកសម្បយុត្ត ១២ ព្រមដោយមោហចេតសិកក្នុងមោហមូលចិត្ត ២ ដួងផង រូប ២៨ ផង និងព្រះនិព្វានផង ។

**សហេតុកា ធម្មា** ពួកធម៌មានហេតុ គឺ សហេតុកចិត្ត ៧១ ដួង ដោយសង្ខេប ( វៀរអហេតុកចិត្ត ១៨ ដួង ) ចេតសិក ៥២ (វៀរមោហចេតសិកក្នុងមោហមូលចិត្ត ២ ដួង ) ។

**៧០~ កិច្ចសង្គហៈ** ជាការរាប់ប្រមូលចិត្តដែលធ្វើកិច្ចផ្សេងៗ ចិត្តធ្វើកិច្ចតាំងពីកើតដល់ស្លាប់ គឺធ្វើកិច្ចជាមួយនឹងអារម្មណ៍ តៗគ្នារហូត មិនមែនជាសត្វបុគ្គល មិនមែនជាយើងដែលធ្វើនូវកិច្ចទាំងអស់នេះឡើយ ។

**៧១~ បដិសន្ធិកិច្ច** ចិត្តចេតសិកនិងកម្មជរូប ដែលកើតក្នុងខណៈបដិសន្ធិ សម្រាប់ភពដែលមានខន្ធ ៥។ ឧបេក្ខាសន្តីរណៈ

២ គឺ អហេតុកវិបាកមនោវិញ្ញាណធាតុ , ១ ដួងជាកុសលវិបាក , ១ ដួងទៀតជាអកុសលវិបាក ។ កាមាវចរបដិសន្ធិ មានចិត្ត ១០ ដួង គឺ ឧបេក្ខាសន្តីរណចិត្ត ២ ដួង និង មហាវិបាកចិត្ត ៨ ដួង ។

**៧២. ភវង្គកិច្ច** ភវង្គគឺជាអង្គនៃឧបបត្តិភព។ បន្ទាប់ពីបដិសន្ធិចិត្ត ១ ខណៈកន្លងទៅ វិបាកចិត្តបានធ្វើភវង្គកិច្ចជាបន្ត ។ រស់នៅរាល់ថ្ងៃ កាលដែលមិនមានវិថីចិត្ត[១] ហ្នឹងឯងជាភវង្គ បើបដិសន្ធិដោយវិបាកចិត្តដូចម្ដេច ភវង្គក៏ជាវិបាកចិត្តដូច្នោះដែរ ។

**៧៣. អាវជ្ជនកិច្ច** ចិត្ត ២ ដួងគឺ កិរិយាមនោធាតុ ហៅបញ្ចទ្វារាវជ្ជនចិត្តក៏បាន ១ អហេតុកកិរិយាមនោវិញ្ញាណធាតុប្រកបដោយឧបេក្ខាវេទនា ហៅមនោទ្វារាវជ្ជនចិត្តក៏បាន ១ ។ បញ្ចទ្វារាវជ្ជនចិត្តកើតមុនគេក្នុងបញ្ចទ្វារ ចំណែកមនោទ្វារាវជ្ជនចិត្ត កើតមុនគេក្នុងមនោទ្វារ ។

**៧៤. ទស្សនកិច្ច** កិច្ចឃើញនូវរូបារម្មណ៍ជាកុសលវិបាក ១ អកុសលវិបាក ១ ។ ដែលប្រកាន់ថា ខ្លួនអ្នកឃើញរូប ព្រោះមិនអប់រំសតិរលឹករឿយៗ ត្រង់ចិត្តឃើញ ត្រឹមតែជាចិត្តដឹងនូវរូបារម្មណ៍ ។

---

១. វិថី ហៅតាមទម្លាប់ប្រើក្នុងសៀវភៅព្រះអភិធម្ម តាមបាលីមិនមាន **វិថី** ទេ មានតែ **វីថិ** ។

**៧៥. សវនកិច្ច** កិច្ចស្តាប់ឮនូវសំឡេង ជាកិច្ចរបស់ចិត្ត ២ ដួង កុសលវិបាក ១ អកុសលវិបាក ១ អត់មានអ្នកឮផ្សេងពីចិត្តកំពុងឮហ្នឹងទៀតទេ ។

**៧៦. ឃាយនកិច្ច** កិច្ចធុំក្លិន ជាកិច្ចរបស់ចិត្ត ២ ដួង ផ្សេងទៀត កុសលវិបាក ១ និង អកុសលវិបាក ១ ។

**៧៧. សាយនកិច្ច** កិច្ចលិឍដឹងនូវរសារម្មណ៍ គឺជាចិត្តផ្សេងទៀតដែលធ្វើកិច្ចដឹងរស ។ កាលណាបើចិត្តផ្សេងៗធ្វើកិច្ចដឹងអារម្មណ៍ដូច្នេះ តើមានខ្លួនយើងជាអ្នកដឹងអារម្មណ៍ដូចម្តេចទៅ ។

**៧៨. ផុស្សនកិច្ច** កិច្ចដឹងនូវផោដ្ឋព្វៈ ផោដ្ឋព្វៈគឺលក្ខណៈដែលប្រាកដនឹងកាយប្បសាទ។ តាំងពីចុងសក់ដល់បាតជើង ទ្រង់ទ្រាយសណ្ឋាន ក្បាលមុខមាត់ ដៃជើងជាដើម សុទ្ធតែជានិមិត្តដែលចិត្តក្នុងមនោទ្វារគិតទាំងអស់ អ្វីដែលប្រាកដនឹងកាយ ហើយកាយវិញ្ញាណបានដឹង គឺ លក្ខណៈរឹងទន់ ក្តៅត្រជាក់ តឹងញ៉រ ។ កាយប្បសាទមិនដែលបានប៉ះនឹងអ្វី ដែលជាតួខ្លួនប្រាណយើងនោះទេ ឯកាយវិញ្ញាណបានត្រឹមតែដឹងនូវអ្វី ដែលប្រាកដត្រង់កាយប៉ុណ្ណឹងឯង ។

**៧៩. សម្បដិច្ឆន្នកិច្ច** កិច្ចទទួលអារម្មណ៍បន្តអំពីបញ្ច-វិញ្ញាណណាមួយរលត់ទៅ ដូចជាផ្លូវភ្នែក ចក្ខុវិញ្ញាណរលត់ទៅ កើតសម្បដិច្ឆន្នចិត្ត។ ផ្លូវត្រចៀក សោតវិញ្ញាណរលត់ទៅ កើតសម្បដិច្ឆន្នចិត្ត ដូច្នេះជាដើម។ សម្បដិច្ឆន្នចិត្តគឺជាវិបាកមនោធាតុ ២ ដួង ធ្វើសម្បដិច្ឆន្នកិច្ចក្នុងបញ្ចទ្វារ ។

**៨០. សន្តីរណកិច្ច** គឺជាអហេតុកវិបាកមនោវិញ្ញាណ-ធាតុ ៣ ដួងហ្នឹងឯង បានជាហៅថាសន្តីរណចិត្ត ព្រោះចិត្ត ៣ ដួងនេះធ្វើសន្តីរណកិច្ចផងដែរក្នុងបណ្តាកិច្ចទាំងឡាយ ហើយម្យ៉ាងទៀត មិនមានចិត្តដទៃមកធ្វើសន្តីរណកិច្ចឱ្យច្រឡំឡើយ ។ សន្តីរណកិច្ចនេះ ជាកិច្ចបន្តពីសម្បដិច្ឆន្នកិច្ចក្នុងបញ្ចទ្វារ គឺកាលដែលសម្បដិច្ឆន្នចិត្តធ្វើកិច្ចទទួលហើយ សន្តីរណចិត្តក៏ធ្វើកិច្ចពិនិត្យនូវអារម្មណ៍នោះ។

**៨១. វោដ្ឋព្វនកិច្ច** កិច្ចកំណត់អារម្មណ៍ បន្ទាប់ពីសន្តីរណកិច្ចហើយ ។ កិច្ចនេះត្រូវធ្វើដោយអហេតុកកិរិយាមនោ-វិញ្ញាណធាតុប្រកបដោយឧបេក្ខាវេទនា ជាកិច្ចក្នុងបញ្ចទ្វារ ។

**៨២. ជវនកិច្ច** កាមជវន៍ ២៩ ដួងធ្វើជវនកិច្ចក្នុងទ្វារទាំង ៦ ក្នុងបញ្ចទ្វារបន្ទាប់ពីវោដ្ឋព្វនកិច្ច ចំណែកក្នុងមនោទ្វារគឺ

បន្ទាប់ពីអាវជ្ជនកិច្ចហើយ។ អប្បនាជវន៍ ២៦ ដួងដោយសង្ខេប បើដោយពិស្តារ ៥៨ ដួង ធ្វើជវនកិច្ចក្នុងមនោទ្វារតែប៉ុណ្ណោះ។

ជវន៍ ៥៥ ដួង (សង្ខេប) មាន ៤ ជាតិ គឺ

- កុសលចិត្ត ២១ ដួង
- អកុសលចិត្ត ១២ ដួង
- លោកុត្តរវិបាកចិត្ត ៤ ដួង
- កិរិយាចិត្ត ១៨ ដួង។

**៨៣. តទាលម្ពណកិច្ច** កិច្ចកាន់យកនូវអារម្មណ៍ដែលជវន៍សោយហើយ ប្រៀបដូចអ្នកបរិភោគនូវក្រយាដែលសល់ពីព្រះរាជា។ កម្មបានញុំាងកាមាវចរវិបាកចិត្ត ១១ ដួងណាមួយ និងចេតសិកសម្បយុត្ត ឱ្យកាន់យកនូវអារម្មណ៍តាមទ្វារទាំង ៦ បន្ទាប់ពីកាមាវចរជវន៍ធ្វើកិច្ចហើយ ។

ជាប្រក្រតីកាមាវចរជវន៍កើត ៧ ខណៈតគ្នា រលត់ទៅទើបតទាលម្ពណៈកើត ២ ខណៈ។ បើរាប់ខណៈចិត្តបន្តគ្នាក្នុងបញ្ចទ្វារ គឺមាន ១៤ ខណៈ គឺបញ្ចទ្វារាវជ្ជនៈ ១ ខណៈ បញ្ចវិញ្ញាណណាមួយ ១ ខណៈ សម្បដិច្ឆន្នៈ ១ ខណៈ សន្តីរណៈ ១ ខណៈ វោដ្ឋព្វនៈ ១ ខណៈ ជវនៈ ៧ ខណៈ តទាលម្ពណៈ ២ ខណៈ។

បើរាប់ក្នុងមនោទ្វារមាន ១០ ខណៈគឺ មនោទ្វារាវជ្ជនៈ ១ ខណៈ កាមជវ័ន ៧ ខណៈ តទាលម្ពណៈ ២ ខណៈ ។

**៨៤. ចុតិកិច្ច** គឺជាវិបាករបស់កម្មដែលជាខណៈក្រោយគេក្នុងមួយជាតិ បន្ទាប់ពីបដិសន្ធិហើយភវង្គ ភវង្គច្រើនខណៈរាប់មិនអស់ ដល់ចុងក្រោយគឺចុតិកិច្ចនេះឯង នេះជាវិបាកក្រៅទ្វារ ៦។

**៨៥. សរុបចិត្តក្នុងកិច្ចសង្គហៈ** សន្តីរណចិត្ត ២ ដួងប្រកបដោយឧបេក្ខាវេទនា (វៀរសោមនស្សសន្តីរណចិត្ត) ១ ដួងជាអកុសលវិបាកមនោវិញ្ញាណធាតុ , ១ ដួងទៀតជាកុសលវិបាក-អហេតុកមនោវិញ្ញាណធាតុប្រកបដោយឧបេក្ខាវេទនា។ អកុសល-វិបាកមនោវិញ្ញាណធាតុ ១ ដួង គឺ ឧបេក្ខាសន្តីរណអកុសលវិបាកធ្វើកិច្ច ៥ គឺ ធ្វើសន្តីរណកិច្ចក្នុងបញ្ចទ្វារ ធ្វើតទាលម្ពណកិច្ចក្នុងទ្វារ ៦ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ចក្នុងអបាយភូមិ ៤ ។ ចំណែកឧបេក្ខាសន្តីរណកុសលវិបាក ធ្វើសន្តីរណកិច្ចក្នុងបញ្ចទ្វារ ធ្វើតទាលម្ពណកិច្ចក្នុងទ្វារ ៦ ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ចក្នុងកំណើតមនុស្សទេវតាខ្វះបុណ្យ ។

មហាវិបាកចិត្ត ៨ ដួង ធ្វើតទាលម្ពណកិច្ចក្នុងទ្វារ ៦ ធ្វើបដិសន្ធិកិច្ចជាដើមក្នុងកំណើតមនុស្សទេវតាសម្បូណ៌បុណ្យ។

មហគ្គតវិបាកចិត្ត ៩ដួង ធ្វើបដិសន្ធិកិច្ចជាដើមក្នុងរូបព្រហ្ម និង អរូបព្រហ្ម ជាចិត្តធ្វើកិច្ចក្រៅទ្វារ ៦ តែម្យ៉ាង។

ចិត្ត ២ ដួង មួយដួងៗ ធ្វើកិច្ចពីររៀងខ្លួន សុទ្ធតែជាកិច្ចក្នុងទ្វារ (កិច្ចក្នុងទ្វារគឺចាប់ពីអាវជ្ជនកិច្ចដល់តទាលម្ពណកិច្ច )។

ជវន៍ចិត្ត ៥៥ ដួង ធ្វើតែជវនកិច្ច។ ទ្វិបញ្ចវិញ្ញាណ ១០ ដួង គឺចិត្ត ២ ដួងធ្វើកិច្ចមួយ រៀងៗខ្លួន ដូចជាចក្ខុវិញ្ញាណ ២ ដួងធ្វើទស្សនកិច្ចជាដើម។ មនោធាតុ ៣ គឺ បញ្ចទ្វារាវជ្ជនចិត្តធ្វើអាវជ្ជន-កិច្ចក្នុងបញ្ចទ្វារ នៅសម្បដិច្ឆន្នចិត្ត ២ ដួងទៀតធ្វើសម្បដិច្ឆន្នកិច្ចក្នុងបញ្ចទ្វារដែរ ព្រោះចិត្ត ៣ ដួងនេះ កើតតែតាមបញ្ចទ្វារប៉ុណ្ណោះ។

សរុបចិត្ត ៦៨ ដួង មួយដួងៗ ធ្វើកិច្ចតែមួយ (រួមមានកិច្ច ៨ ) ចិត្ត ២ ដួង មួយដួងៗ ធ្វើកិច្ចពីរ ចិត្ត ៩ ដួង មួយដួងៗ ធ្វើកិច្ចបី ចិត្ត ៨ ដួង មួយដួងៗ ធ្វើកិច្ចបួន ចិត្ត ២ ដួង មួយដួងៗ ធ្វើកិច្ចប្រាំ។ ចិត្ត ៨៩ ដួងធ្វើកិច្ច ១៤ ក្នុងភពបីតាមសមគួរ។

មហគ្គតវិបាកចិត្ត ៩ ដួង ធ្វើកិច្ចក្រៅទ្វារតែម្យ៉ាង។

ចិត្ត ១០ ដួងគឺមហាវិបាកចិត្ត ៨ ដួង ឧបេក្ខាសន្តីរណចិត្ត ២ ដួង ធ្វើកិច្ចក្នុងទ្វារផង ក្រៅទ្វារផង។

ចិត្ត ៧០ ដួង ធ្វើតែកិច្ចក្នុងទ្វារ។

**៨៦~ ទ្វារសង្គហៈ** ជាការរាប់ប្រមូលចិត្តដែលកើតតាមទ្វារនីមួយៗ ព្រោះថា តាមទ្វារទាំង ៦ មានតែចិត្ត និង ចេតសិកប៉ុណ្ណោះ ដែលកើតឡើងដឹងនូវអារម្មណ៍ ហើយក៏កន្លងទៅ ព្រោះតែការកន្លងទៅនៃនាមរូប ទើបមានម្សិលមិញ ខែមុន ឆ្នាំមុន និងជាតិមុនៗ។

**៨៧~ ចក្ខុបសាទ** កាលដែលមានរូបារម្មណ៍មកប៉ះខ្ទប់នាំឱ្យចក្ខុទ្វារវិថីចិត្ត ៤៦ ដួង កើតបន្តគ្នាដឹងនូវរូបារម្មណ៍នោះ គឺខណៈមុនរលត់ទៅ ទើបខណៈថ្មីកើតបន្ត ចាប់ពីបញ្ចទ្វារាវជ្ជនៈរហូតដល់តទាលម្ពណៈ។ តទាលម្ពណៈក្នុងកាមសុគតិភព ៧ ជាន់មានចិត្ត ១១ ដួង ប៉ុន្តែព្រោះរាប់សន្តីរណចិត្ត ៣ ដួងធ្វើសន្តីរណកិច្ចរួចហើយ ទើបរាប់តែមហាវិបាកចិត្ត ៨ ដួងក្នុងតទាលម្ពណកិច្ច។

**៨៨~ សោតប្បសាទ** កាលដែលមានសំឡេងមកប៉ះខ្ទប់នាំឱ្យមានសោតទ្វារវិថីចិត្ត ៤៦ ដួង កើតបន្តគ្នាដឹងនូវសំឡេងនោះ ប៉ុន្តែមិនមែនមួយវារៈនៃវិថីនោះ មានចិត្តគ្រប់ទាំង ៤៦ ដួងទេ ព្រោះថាសោតវិញ្ញាណដួងណាមួយក្នុង ២ ដួង និង សម្បដិច្ឆន្នចិត្តដួងណាមួយ សន្តីរណចិត្តដួងណាមួយ កាមជវនៃដួងណាមួយ

និង តទាលម្ពណកិច្ចដោយចិត្តដួងណាមួយ តែប៉ុណ្ណោះ។

**៨៩. ឃានប្បសាទ** កាលដែលមានក្លិនមកប៉ះខ្ទប់ នាំឱ្យមានឃានទ្វារវិថីចិត្ត ៤៦ ដួង កើតបន្តគ្នាដឹងនូវក្លិននោះ។ ចិត្ត ៤៦ ដួងនេះគឺជាកាមាវចរចិត្តទាំងអស់ វៀរតែវិញ្ញាណ ៨ ដួង ដែលកើតតាមទ្វាររៀងខ្លួន ដូចជាចក្ខុវិញ្ញាណ ២ ដួងកើតតែតាមចក្ខុទ្វារជាដើម។

**៩០. ជិវ្ហាបសាទ** កាលដែលមានរសមកប៉ះខ្ទប់ នាំឱ្យមានជិវ្ហាទ្វារវិថីចិត្ត ៤៦ ដួង កើតបន្តគ្នាដឹងនូវរសនោះ។ បញ្ចទ្វារាវជ្ជនៈ និង វោដ្ឋព្វនៈជាកិរិយា ជិវ្ហាវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ និង តទាលម្ពណៈជាវិបាក ចំណែកកាមជវ័នជាកុសលក៏មាន ជាអកុសលក៏មាន ជាកិរិយាក៏មាន។

**៩១. កាយប្បសាទ** កាលដែលមានផោដ្ឋព្វៈក្តៅឬត្រជាក់ រឹងឬទន់ តឹងឬញ័រ មកប៉ះខ្ទប់ នាំឱ្យមានកាយទ្វារវិថីចិត្ត ៤៦ ដួង កើតបន្តគ្នាដឹងនូវផោដ្ឋព្វៈនោះ។ កាយវិញ្ញាណមិនដែលដឹងអ្វីជាតួខ្លួន ជាសត្វបុគ្គលនោះឡើយ តាំងពីចុងសក់ដល់បាតជើង ទាំងក្នុងទាំងក្រៅ ព្រោះលក្ខណៈដែលប្រាកដត្រង់កាយ មានតែក្តៅឬត្រជាក់ រឹងឬទន់ តឹងឬញ័រប៉ុណ្ណោះឯង។

**៩២. មនោទ្វារ** មុននឹងវិថីចិត្តកើតឡើង គឺចិត្តធ្វើភវង្គ-កិច្ច។ ភវង្គកើតរលត់បន្តគ្នា ភវង្គចុងក្រោយដែលជាអនន្តរប្បច្ច័យនៃមនោទ្វារាវជ្ជនចិត្ត ភវង្គនោះឯងជាមនោទ្វារ ។ មនោទ្វារវិថី-ចិត្តមាន ៦៧ ដួង ដឹងអារម្មណ៍ ៦ តាមសមគួរ។

**៩៣. ទ្វារវិមុត្តចិត្ត** ក្នុងរវាងបដិសន្ធិ និង ចុតិ ចិត្តដែលធ្វើកិច្ចក្រៅទ្វារសព្វថ្ងៃគឺភវង្គចិត្តដួងណាមួយ មានអារម្មណ៍ដែលជាអារម្មណ៍របស់មរណាសន្នជវ័ន កាលពីជាតិមុន។

**៩៤. តារាងវិថីចិត្ត** I ដែលរាប់តទាលម្ពណៈ ៨ គឺរាប់មហាវិបាកចិត្ត ៨ ដួងតែប៉ុណ្ណោះ ព្រោះសន្តីរណចិត្ត ៣ ដួងរាប់រួចហើយ តាមពិតចិត្ត ១១ ដួង ធ្វើតទាលម្ពណកិច្ច។

**៩៥. តារាងវិថីចិត្ត** II រាប់តទាលម្ពណៈ ១១ ទៅតាមចំនួនចិត្ត ១១ ដួង ប៉ុន្តែចិត្ត ១១ ដួងនោះ មានចិត្ត ៣ ដួង ធ្វើសន្តីរណកិច្ចដែរ ដូច្នេះក្នុងការបូករាប់ចំនួនចិត្តក្នុងទ្វារ ត្រូវកុំបូកសន្តីរណចិត្ត ៣ ដួង ពីរដង ទើបឃើញចិត្ត ៤៦ ដួង បើរាប់សរុបចិត្តទាំង ៥ ទ្វារ ឃើញកាមាវចរចិត្ត ៥៤ ដួង។

នៅក្នុងទ្វារវិមុត្តិ មានអកុសលវិបាកមនោវិញ្ញាណធាតុបដិសន្ធិក្នុងអបាយភូមិ ៤។ ចំណែកកាមសុគតិភព ៧ ជាន់ មាន

កុសលវិបាកចិត្ត ៩ ដួងធ្វើកិច្ចបដិសន្ធិ  ក្នុងចិត្ត ៩ ដួងនោះ មាន ១ ដួងជាអហេតុកៈ  ៨ ដួងជាសហេតុកៈ ។ រីឯមហគ្គតវិបាកចិត្ត ៩ ដួង បដិសន្ធិក្នុងព្រហ្មលោក ១៩ ជាន់ (វៀរព្រហ្មអសញ្ញី)។

**៩៦~ អារម្មណសង្គហៈ** ជាការរាប់ប្រមូលចិត្តដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ។ ពាក្យថា អារម្មណ៍ គឺ អ្វីណាដែលចិត្តចេតសិកបានដឹង អ្វីនោះហៅថាអារម្មណ៍។ រាល់ពេលដែលដឹងនូវអារម្មណ៍ សតិថ្នាក់សតិប្បដ្ឋានអាចរលឹកសិក្សាបាននូវធម្មជាតិដែលដឹងនូវអារម្មណ៍នោះ ឃើញតួ **ធម្ម** តែប៉ុណ្ណោះ។

**៩៧~ ចិត្ត ២៥ ដួង** មានតែកាមាវចរជាអារម្មណ៍ (កាមាវចរគឺរូប ២៨ កាមាវចរចិត្ត ៥៤ ចេតសិកសម្បយុត្ត ៥២)។ ចិត្ត ២៥ ដួង គឺ ទ្វិបញ្ចវិញ្ញាណ ១០ ដួង មានអារម្មណ៍តាមទ្វារមួយ រៀងៗខ្លួន មនោធាតុ ៣ មានអារម្មណ៍តាមបញ្ចទ្វារ នៅចិត្ត ១២ ដួងទៀត មានអារម្មណ៍តាមទ្វារ ៦។

**៩៨~ ចិត្ត ២០ ដួង** មានអារម្មណ៍វៀរតែលោកុត្តរចេញ ពោលគឺចិត្ត ២០ ដួងនេះ  អាចដឹងអារម្មណ៍ជាលោកិយ និង បញ្ញត្តិបានទាំងអស់។

**៩៩~ ចិត្ត ៥ ដួង** មានអារម្មណ៍ទាំងលោកិយ ទាំង

លោកុត្តរ និង បញ្ញត្តិ វៀរតែអរហត្តមគ្គ អរហត្តផលចេញ។ បាន ជាវៀរ ព្រោះកាលដែលបច្ចវេក្ខណញ្ញាណពិចារណាអរហត្តមគ្គ និង ពិចារណាអរហត្តផល បច្ចវេក្ខណញ្ញាណនោះជាមហាកិរិយា ទៅហើយ មិននៅជាមហាកុសលទៀតឡើយ។ ចំណែកអភិញ្ញាក៏ ដូច្នោះដែរ កាលដែលដឹងនូវអរហត្តមគ្គ អរហត្តផល ទាល់តែ អភិញ្ញានោះជារបស់ព្រះអរហន្ត គឺ អភិញ្ញាកិរិយា ។

**១០០~ ចិត្ត ៦ ដួង** មានអារម្មណ៍មិនមានវៀរ កាមាវចរក៏ដឹង រូបាវចរក៏ដឹង អរូបាវចរក៏ដឹង លោកុត្តរមគ្គផលនិព្វានក៏ ដឹង បញ្ញត្តិក៏ដឹង។

**១០១~ ចិត្ត ២១ ដួង** មានតែបញ្ញត្តិជាអារម្មណ៍ ប៉ុណ្ណោះ។

**១០២~ ចិត្ត ៦ ដួង** មានតែមហគ្គតៈជាអារម្មណ៍ មហគ្គតៈនោះជាអតីតតែម្យ៉ាង និង ជាខាងក្នុងគឺជារបស់ខ្លួនឯង អ្នកបានសម្រេចតែប៉ុណ្ណោះ។

**១០៣~ លោកុត្តរចិត្ត ៨ ដួង** គឺមគ្គ ៤ ផល ៤ មាន ព្រះនិព្វានជាអារម្មណ៍តែម្យ៉ាង។

**១០៤~ សរុបចិត្ត** ចិត្ត ៧ ពួកមាន ៩១ ដួង ដោយរាប់

បន្ថែមអភិញ្ញា ២ ដួងផង។

**១០៥. វត្ថុសង្គហៈ** ជាការរាប់ប្រមូលចិត្តដែលអាស្រ័យវត្ថុរូបកើតឡើង។

**១០៦. ចក្ខុវត្ថុ** ជាទីកើតនៃចក្ខុវិញ្ញាណ គឺ ដោយឥន្ទ្រិយប្បច្ច័យក៏បាន ដោយវត្ថុបុរេជាតប្បច្ច័យក៏បាន និង ដោយនិស្សយប្បច្ច័យក៏បាន។ ពោលដោយបរមត្ថ សត្វ បុគ្គលអ្នកឃើញមិនមានឡើយ។

**១០៧. សោតវត្ថុ** ជាទីកើតនៃសោតវិញ្ញាណ។ សោតវិញ្ញាណកើតឡើង ទើបសន្មតថាយើងឮ អ្នកដទៃស្តាប់ឮ។

**១០៨. ឃានវត្ថុ** ជាទីកើតនៃឃានវិញ្ញាណ។ ការធុំក្លិនជា **ធម្ម** មួយបែបដែលអាស្រ័យបច្ច័យកើតឡើង ក៏ជាទីតាំងនៃការសិក្សាចម្រើនបញ្ញា ដូចជា **ធម្ម** ដទៃទៀតដែរ។

**១០៩. ជិវ្ហាវត្ថុ** ជាទីកើតនៃជិវ្ហាវិញ្ញាណ។ ជាធម្មតានៃការដឹងរស បើមិនបានសិក្សាក៏សម្គាល់ខុសថា ខ្លួនយើងដឹងរស។

**១១០. កាយវត្ថុ** ជាទីកើតនៃកាយវិញ្ញាណ។ ការដឹងផោដ្ឋព្វៈមានគ្រប់ពេល បើមិនបានស្តាប់ព្រះធម៌ដោយល្អទេ ក៏ជាបុគ្គលប្រមាទ រំលងចោល ដោយមិនសិក្សានូវ **ធម្ម** ជាប្រក្រតី

បញ្ញាមិនចម្រើនឡើងឡើយ អវិជ្ជានុស័យនៅតែដេកសំងំរហូត។

**១១១, ១១២, ១១៣, ១១៤~ហទយវត្ថុ** ជាទីកើតនៃមនោធាតុ និង មនោវិញ្ញាណធាតុ ក្នុងបញ្ចវោការភព។ ចិត្តក្នុងអរូបព្រហ្មមិនអាស្រ័យវត្ថុរូបឡើយ ប៉ុន្តែ នៅតែមានការកើតហើយរលត់ និង កើតបន្ត ដោយអាស្រ័យអារម្មណប្បច្ច័យ និង អនន្តរប្បច្ច័យជាដើម។

**១១៥~ ស្ថានរបស់ចិត្ត** គឺជាកន្លែងកើតរលត់នៃចិត្ត ឬជាកន្លែងដែលចិត្តធ្វើកិច្ច ព្រោះកិច្ចទាំង ១៤ ស្ថិតនៅក្នុងស្ថាន ១០ ដោយទ្វិបញ្ចវិញ្ញាណ ១០ ដួង សរុបកិច្ចមាន ៥ ស្ថិតនៅក្នុងស្ថានតែមួយគឺរវាងបញ្ចទ្វារាវជ្ជនកិច្ច និង សម្បដិច្ឆន្នកិច្ច។

**១១៦~ បដិសន្ធិស្ថាន** គឺចិត្តធ្វើកិច្ចបដិសន្ធិនៅត្រង់រវាងចុតិកិច្ច និង ភវង្គកិច្ច ពោលគឺចុតិរូចបដិសន្ធិ បដិសន្ធិ ១ ខណៈរលត់ទៅភវង្គកើតបន្ត។

**១១៧~ ភវង្គស្ថាន** មាន ៦ កន្លែង គឺភវង្គស្ថាន ទី១ ស្ថិតនៅរវាងបដិសន្ធិ និង មនោទ្វារាវជ្ជនៈ ព្រោះថាសត្វដែលកើតហើយក្នុងភព ៣០ ជាន់ រមែងមានមនោទ្វារវិថីចិត្ត កើតមុនវិថីចិត្តដទៃ ទាំងដែលជាលោភជវន័ក្នុងវិថីនោះទៀតផង។

**១១៨. តទាលម្ពនស្ថាន ទី២** ភវង្គនៅខាងមុខតទាលម្ពណៈ ដែលតទាលម្ពណៈនោះនៅក្នុងទ្វារ ៦ ជាប្រក្រតីអាវជ្ជនៈណាមួយ ត្រូវនៅមុខភវង្គ (តទាលម្ពណៈ ភវង្គ អាវជ្ជនៈ)។

**១១៩. តទាលម្ពនស្ថាន ទី៣** ភវង្គនៅខាងមុខជវន័ ដែលជវន័នោះនៅក្នុងទ្វារ ៦ (ជវន័ ភវង្គ អាវជ្ជនៈ)។

**១២០. តទាលម្ពនស្ថាន ទី៤** ភវង្គនៅខាងមុខវោដ្ឋព្វនៈ ដែលវោដ្ឋព្វនៈនោះនៅក្នុងបញ្ចទ្វារ (វោដ្ឋព្វនៈ ភវង្គ អាវជ្ជនៈ)។

**១២១. តទាលម្ពនស្ថាន ទី៥** ចុតិមុខភវង្គ ដែលភវង្គនៅមុខតទាលម្ពណៈ (តទាលម្ពណៈ ភវង្គ ចុតិ)។

**១២២. តទាលម្ពនស្ថាន ទី៦** ចុតិមុខភវង្គ ដែលភវង្គនៅមុខជវន័ (ជវន័ ភវង្គ ចុតិ)។

**១២៣. អាវជ្ជនស្ថាន** មាន ២ កន្លែង កន្លែងទី ១ គឺកន្លែងនៃបញ្ចទ្វារាវជ្ជនកិច្ច (ភវង្គ អាវជ្ជនៈ បញ្ចវិញ្ញាណ)។

**១២៤. អាវជ្ជនស្ថាន ទី២** គឺកន្លែងនៃមនោទ្វារាវជ្ជនកិច្ច (ភវង្គ អាវជ្ជនៈ ជវន័)។

**១២៥. បញ្ចវិញ្ញាណស្ថាន** ទស្សនកិច្ចក្តី សវនកិច្ចក្តី ឃាយនកិច្ចក្តី សាយនកិច្ចក្តី ផុស្សនកិច្ចក្តី នៅក្នុងស្ថានតែមួយនេះ

ឯង (អាវជ្ជនៈ បញ្ចវិញ្ញាណ សម្បដិច្ឆន្នៈ)។

**១២៦. សម្បដិច្ឆន្នស្ថាន** ជាស្ថានក្នុងបញ្ចទ្វារ។

**១២៧. សន្តីរណស្ថាន** ជាស្ថានក្នុងបញ្ចទ្វារ។

**១២៨. វោដ្ឋព្វនស្ថាន** ជាស្ថានក្នុងបញ្ចទ្វារ មាន ២ កន្លែង គឺ កន្លែង ទី១ មានជវនៈកើតបន្ត ព្រោះអារម្មណ៍ជាអតិមហន្តារម្មណ៍ ឬមហន្តារម្មណ៍។

**១២៩. វោដ្ឋព្វនស្ថាន ទី២** មិនមានជវនៈកើតបន្តឡើយ ព្រោះអារម្មណ៍ជាបរិត្តារម្មណ៍ វោដ្ឋព្វនកិច្ច ២ ឬ ៣ ខណៈ ហើយធ្លាក់ចុះកាន់ភវង្គ (សន្តីរណៈ វោដ្ឋព្វនៈ ភវង្គ)។

**១៣០. ជវនស្ថាន** មាន ៦ កន្លែង គឺជវនស្ថាន ទី១ ក្នុងបញ្ចទ្វារ អារម្មណ៍ជាអតិមហន្តារម្មណ៍ វិថីចិត្តមានដល់តទាលម្ពណៈ (វោដ្ឋព្វនៈ ជវនៈ តទាលម្ពណៈ) ។

**១៣១. ជវនស្ថាន ទី២** ក្នុងបញ្ចទ្វារ អារម្មណ៍ជាមហន្តារម្មណ៍ វិថីចិត្តមានត្រឹមជវនៈ ហើយធ្លាក់ចុះកាន់ភវង្គ។

**១៣២. ជវនស្ថាន ទី៣** ក្នុងបញ្ចទ្វារ ចុតិមុខជវនៈ។

**១៣៣. ជវនស្ថាន ទី៤** ក្នុងមនោទ្វារ អារម្មណ៍ជាវិភូតារម្មណ៍ វិថីចិត្តមានដល់តទាលម្ពណៈ។

**១៣៤. ជវនស្ថាន ទី៥** ក្នុងមនោទ្វារ អារម្មណ៍ជាអវិភូតារម្មណ៍ វិថីចិត្តមានត្រឹមជវ័នប៉ុណ្ណោះ ត្រូវធ្លាក់ចុះកាន់ភវង្គ (មនោទ្វារាវជ្ជនៈ ជវ័ន ភវង្គ)។

**១៣៥. ជវនស្ថាន ទី៦** ក្នុងមនោទ្វារ ចុតិមុខជវ័ន។

**១៣៦. តទាលម្ពណស្ថាន** មាន ២ កន្លែង ក្នុងទ្វារទាំង ៦ ដូចគ្នា កន្លែង ទី១ គឺភវង្គមុខតទាលម្ពណៈ។

**១៣៧. តទាលម្ពណស្ថាន ទី២** គឺ ចុតិនៅមុខតទាលម្ពណៈ (ជវ័ន តទាលម្ពណៈ ចុតិ)។

**១៣៨. ចុតិស្ថាន** មាន ៣ កន្លែង កន្លែង ទី១ គឺចុតិមុខជវ័នក្នុងទ្វារទាំង ៦ (ជវ័ន ចុតិ បដិសន្ធិ)។

**១៣៩. ចុតិស្ថាន ទី២** គឺចុតិមុខតទាលម្ពណៈក្នុងទ្វារទាំង ៦ (តទាលម្ពណៈ ចុតិ បដិសន្ធិ)។

**១៤០. ចុតិស្ថាន ទី៣** គឺចុតិមុខភវង្គ។

**១៤១. អំពីប្រភេទអារម្មណ៍** អារម្មណ៍ជាលោកនៃការរស់នៅ តាមពិត លោកនៃការរស់នៅ គ្រាន់តែជាអារម្មណ៍របស់វិថីចិត្តប៉ុណ្ណោះ ចិត្តកើតឡើងក្នុងវិថី សត្វលោកឈ្មោះថាកំពុងរស់នៅក្នុងលោក ចិត្តរលត់អស់ទៅ សត្វលោកឈ្មោះថាស្លាប់

ហើយ។

**១៤២, ១៤៣, ១៤៤, ១៤៥.** អារម្មណ៍តាមបញ្ចទ្វារ មាន ៤ ប្រភេទ :

(១). អតិមហន្តារម្មណ៍ អារម្មណ៍ធំដ៏ក្រៃលែង នៅពេលអារម្មណ៍ប៉ះខ្ទប់ទ្វារ ឆាប់ដាច់ខ្សែភវង្គ ទើបវិថីចិត្តឡើងដល់តទាលម្ពណៈ ហៅថា តទាលម្ពណវារៈ។

(២). មហន្តារម្មណ៍ អារម្មណ៍ធំល្មម នៅពេលអារម្មណ៍ប៉ះខ្ទប់ទ្វារ មានភវង្គលើសពី ៣ ខណៈទើបដាច់ នាំឱ្យវិថីចិត្តត្រូវអស់ត្រឹមជវនៈ ហៅថា ជវនវារៈ។

(៣). បរិត្តារម្មណ៍ អារម្មណ៍តូចល្មម នៅពេលអារម្មណ៍ប៉ះខ្ទប់ទ្វារ មានភវង្គច្រើនខណៈទើបដាច់ នាំឱ្យវិថីចិត្តមិនអាចឡើងដល់ជវនៈ ត្រឹមវោដ្ឋព្វនៈ ២ ឬ ៣ ខណៈក៏ធ្លាក់ចុះកាន់ភវង្គ ហៅថា វោដ្ឋព្វនវារៈ។

(៤). អតិបរិត្តារម្មណ៍ អារម្មណ៍តូចដ៏ក្រៃលែង នៅពេលអារម្មណ៍ប៉ះខ្ទប់ទ្វារ មានភវង្គច្រើនខណៈ ហើយត្រឹមតែញ័រប៉ុណ្ណោះ មិនបានដាច់ភវង្គឡើយ ទើបវិថីចិត្តមិនមានទាល់តែសោះ ហៅថា មោឃវារៈ។

**១៤៦, ១៤៧.** អារម្មណ៍របស់មនោទ្វារវិថីចិត្ត មាន ២ ប្រភេទ :

(១). វិភូតារម្មណ៍ អារម្មណ៍ប្រាកដច្បាស់ ហៅថា តទាលម្ពណវារៈ។

(២). អវិភូតារម្មណ៍ អារម្មណ៍មិនសូវប្រាកដច្បាស់ ហៅថា ជវនវារៈ។

**១៤៨. អំពីរូប** រូបជាធាតុមិនដឹង ដូចជាសាកសព ឬ ដូចអង្កត់អុស  រូបបរមត្ថមាន ២៨ រូប :

- បសាទរូប ៥ គឺចក្ខុបសាទ សោតប្បសាទ ឃានប្បសាទ ជិវ្ហាបសាទ និង កាយប្បសាទ។

- វិសយរូប ៤ គឺ វណ្ណរូប សទ្ទរូប គន្ធរូប និង រសរូប ។ វិសយរូប ៤ បូកនឹងផោដ្ឋព្វរូប ៣ គឺ បឋវី តេជោ វាយោ បានជាគោចររូប ៧ ។  បសាទរូប ៥ និង គោចររូប ៧ បានជាឱឡារិករូប គឺរូបគ្រោតគ្រាត ១២ ។ នៅសល់រូប ១៦ ទៀតជាសុខុមរូប។

**១៤៩. ចែករូបតាមសមុដ្ឋាន** សមុដ្ឋាននាំឱ្យរូបកើតមាន ៤ គឺ កម្ម ចិត្ត ឧតុ និង អាហារ។

**១៥០. កម្មជរូបសុទ្ធ** គឺកើតអំពីកម្មតែម្យ៉ាង បសាទរូប

៥ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត និង កាយ សំដៅយកតួបសាទរូបដែលប៉ះខ្ទប់នឹងគោចររូប ៧ នាំឱ្យកើតទ្វិបញ្ចវិញ្ញាណ ឬ នាំឱ្យកើតបញ្ចទ្វារវិថីចិត្ត។ ភាវរូប ២ គឺក្នុងមនុស្សប្រុសមានបុរិសភាវរូប ក្នុងមនុស្សស្រីមានឥត្ថីភាវរូប មនុស្សប្រុសស្រីគ្រាន់តែសន្មតប៉ុណ្ណោះ ព្រោះអាស្រ័យភាវរូបនេះឯង។ ជីវិតរូប ឬ រូបជីវិតិន្ទ្រិយ ជារូបតាមរក្សាសហជាតកម្មជរូប។ ហទយវត្ថុ ជាទីអាស្រ័យនៃមនោធាតុ និង មនោវិញ្ញាណធាតុ។

**១៥១~ ចិត្តជរូបសុទ្ធ** គឺកើតអំពីចិត្តតែម្យ៉ាង ចិត្តជាសមុដ្ឋាននាំឱ្យមានវាយោធាតុ វាយោធាតុប្រៀបដូចជាខ្សែទាញ នាំឱ្យមានកាយវិញ្ញត្តិរូបគឺកម្រើកកាយ ដូច្នេះចិត្តប្រៀបដូចជាអ្នកទាញខ្សែ។ ចិត្តក៏ជាសមុដ្ឋាននាំឱ្យមានបឋវីធាតុដែរ បឋវីធាតុប្រៀបដូចអន្ទងវាយស្គរ នាំឱ្យមានវចីវិញ្ញត្តិរូប គឺកម្រើកវាចា និង សទ្ទរូបកើតឡើង។ សំឡេងពីរោះ មិនពីរោះ សំឡេងស្រីប្រុសជាដើម វាស្ថិតនៅត្រង់កន្លែងនៃសំឡេង ដែលប្រៀបដូចជាតួស្គរកន្លែងនៃសំឡេងនេះ ជាកម្មជរូប រីឯចិត្តដូចជាអ្នកទូងស្គរ។

**១៥២~ សទ្ទរូប** សំឡេងខាងក្រៅ ដូចជាសំឡេងខ្យល់ ផ្គរ រន្ទះ ជាដើម មានឧតុជាសមុដ្ឋានតែម្យ៉ាង។ សំឡេងខាងក្នុងមនុស្សសត្វជាដើម មានសមុដ្ឋាន ២ គឺ ចិត្ត និង ឧតុ ។

**១៥៣. ទិភាររូប ៣** មានចំពោះតែខាងក្នុង មនុស្សសត្វជាដើមដែលនៅរស់ប៉ុណ្ណោះ។

**១៥៤. រូប ៩ នេះមានទូទៅ** ទាំងក្នុងទាំងក្រៅ ចំណែករូបខាងក្រៅមានតែឧតុជាសមុដ្ឋាន ដូចជាសាកសព គល់ឈើ ដុំដី ដុំថ្មជាដើម គឺមានរូប ១០ គត់ ថែមសទ្ទរូប ១ ទៀត។

**១៥៥. លក្ខណរូប** គឺ ឧបចយរូប រូបសន្សំ ពោលគឺរូបខណៈកើតឡើងជាដំបូង ១ សន្តតិរូប រូបកើតបន្ត ពោលគឺរូបខណៈចម្រើនឡើង ១ ជរតារូប រូបជរា ពោលគឺរូបខណៈទ្រុឌទ្រោម ១ អនិច្ចតារូប រូបមិនទៀង ពោលគឺរូបខណៈបែកធ្លាយ ១។ ឧបចយរូប ១ និង សន្តតិរូប ១ រូប ២ នេះជាជាតិរូប ព្រោះជាលក្ខណៈកើតឡើងនៃសភាវរូប ចំណែកជរតារូប គឺរូបតាំងនៅក្នុងការទ្រុឌទ្រោមនៃសភាវរូប រួចហើយក៏បែកធ្លាយ ជាលក្ខណៈនៃអនិច្ចតារូប។ លក្ខណរូប ៤ នេះ មិនមានសភាវៈខ្លួនឯងទេ ដូច្នេះមិនចាំបាច់ពោលពីសមុដ្ឋានអ្វីឡើយ ប៉ុន្តែគ្រប់សភាវរូបទាំងអស់ ដូចជាកម្មជរូបជាដើម សុទ្ធតែមានលក្ខណៈ ៤ យ៉ាងនេះឯង។

**១៥៦. កលាបរូប** គឺជារូបដែលកើតរួមគ្នា ព្រោះអាស្រ័យសមុដ្ឋានណាមួយ ហៅថាសំណុំរូប។

**១៥៧. កម្មជកលាបរូប** សំណុំរូបដែលកើតអំពីកម្ម មាន ៩ សំណុំ។

**១៥៨. ចក្ខុទសកកលាបរូប** គឺអវិនិព្ភោគរូប ៨ រួមនឹងជីវិតរូប មានចក្ខុបសាទរូបជាគម្រប់ ១០ ។ អវិនិព្ភោគរូប ប្រែថារូបមិនបែកគ្នាមាន ៨ រូបហ្នឹងឯង។

**១៥៩. សោតទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មានសោតប្បសាទជាគម្រប់ ១០ ។

**១៦០. ឃានទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មានឃានប្បសាទជាគម្រប់ ១០ ។

**១៦១. ជិវ្ហាទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មានជិវ្ហាបសាទជាគម្រប់ ១០ ។

**១៦២. កាយទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មានកាយប្បសាទជាគម្រប់ ១០ ។

**១៦៣. វត្ថុទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មាន ហទយវត្ថុជាគម្រប់ ១០ ។

**១៦៤. ឥត្ថីភាវទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មានឥត្ថីភាវរូបជាគម្រប់ ១០ ។

**១៦៥. បុរិសភាវទសកកលាបរូប** សំណុំរូបកើតអំពីកម្ម មានបុរិសភាវរូបជាគម្រប់ ១០ ។

**១៦៦. ជីវិតនវកកលាបរូប** សំណុំរូបកើតអំពីកម្ម មានរូបជីវិតិន្ទ្រិយជាគម្រប់ ៩ ។

✶. កម្មជកលាបរូបមាន ៩ សំណុំ បូកចូលគ្នាបាន ៨៩ រូប ប៉ុន្តែដោយសង្ខេបមានត្រឹម ១៨ រូបប៉ុណ្ណោះ គឺកម្មជរូបសុទ្ធ ៩ រូប (ឥន្ទ្រិយរូប ៨ + ហទយវត្ថុ) បូកនឹងអវិនិព្ភោគរូបកើតពីកម្ម ៨ រូប ថែមបរិច្ឆេទរូបកើតពីកម្ម ១ ទៀត ត្រូវជាកម្មជរូប ១៨ អាចបូកនឹងជាតិរូប ២ (ឧបចយរូប ១ សន្តតិរូប ១) បានកម្មជរូប ២០។

**១៦៧. ចិត្តជកលាបរូប** សំណុំរូបដែលកើតអំពីចិត្ត មាន ៦ សំណុំ។

**១៦៨. សុទ្ធដ្ឋកកលាបរូប** សំណុំរូបកើតអំពីចិត្ត មានរូប ៨ គត់គឺអវិនិព្ភោគរូប។

**១៦៩. កាយវិញ្ញត្តិនវកកលាបរូប** សំណុំរូបកើតអំពីចិត្ត មានកាយវិញ្ញត្តិរូបជាគម្រប់ ៩ ។

**១៧០. វចីវិញ្ញត្តិសទ្ទទសកកលាបរូប** សំណុំរូបកើតអំពីចិត្ត មានវចីវិញ្ញត្តិរូប និង សទ្ទរូបជាគម្រប់ ១០ ។

**១៧១- លហុតាទិត្រយេកាឧសកកលាបរូប** សំណុំរូបកើតអំពីចិត្ត មានវិការរូប ៣ ជាគម្រប់ ១១ ។

**១៧២-កាយវិញ្ញត្តិលហុតាទិត្រយទ្វាទសកកលាបរូប** សំណុំរូបកើតអំពីចិត្ត មាន ១២ រូប។

**១៧៣- វចីវិញ្ញត្តិសទ្ទលហុតាទិត្រយតេរសកកលា-បរូប** សំណុំរូបកើតអំពីចិត្ត មាន ១៣ រូប។

✶- ចិត្តជកលាបរូបមាន ៦ សំណុំ បូកចូលគ្នាបាន ៦៣ រូប ប៉ុន្តែដោយសង្ខេបមានត្រឹម ១៥ រូបប៉ុណ្ណោះ គឺ ចិត្តជរូបសុទ្ធ ២ (វិញ្ញត្តិរូប ២) បូកនឹងសទ្ទរូបកើតពីចិត្ត ១ វិការរូបកើតពីចិត្ត ៣ អវិនិព្ភោគរូបកើតពីចិត្ត ៨ និង បរិច្ឆេទរូបកើតពីចិត្ត ១ ទៀត ត្រូវជាចិត្តជរូប ១៥ អាចបូកនឹងជាតិរូប ២ ទៀត សរុបទៅបាន ចិត្តជរូប ១៧។

**១៧៤- ឧតុជកលាបរូប** សំណុំរូបដែលកើតអំពីឧតុខាងក្នុង មាន ៤ សំណុំ។

**១៧៥- សុទ្ធដ្ឋកកលាបរូប** សំណុំរូបកើតអំពីឧតុ មាន អវិនិព្ភោគរូប ៨ គត់។

**១៧៦- សទ្ទនវកកលាបរូប** សំណុំរូបកើតអំពីឧតុ មាន

សំឡេងជាគម្រប់ ៩ ។

**១៧៧. លហុតាទិត្រយោភានសកកលាបរូប** សំណុំរូបកើតអំពីឧតុ មានវិការរូប ៣ ជាគម្រប់ ១១ ។

**១៧៨. សទ្ទលហុតាទិត្រយទ្វានសកកលាបរូប** សំណុំរូបកើតអំពីឧតុ មាន ១២ រូប។

✶. ឧតុជកលាបរូបមាន ៤ សំណុំ បូកចូលគ្នាបាន ៤០ រូប ប៉ុន្តែដោយសង្ខេបមានត្រឹម ១៣ រូបប៉ុណ្ណោះ គឺអវិនិព្ភោគរូប ៨ សទ្ទរូប ១ វិការរូប ៣ និង បរិច្ឆេទរូប ១ ត្រូវជាឧតុជរូប ១៥ ព្រោះ បូកជាមួយនឹងជាតិរូប ២ ផង។

**១៧៩. ឧតុជកលាបរូបខាងក្រៅ** គឺក្រៅអំពីសត្វមានជីវិត រូបខាងក្រៅនោះមាន ២ សំណុំ។

**១៨០. សុទ្ធដ្ឋកកលាបរូប** សំណុំរូបកើតអំពីឧតុខាងក្រៅ មានអវិនិព្ភោគរូប ៨ គត់។

**១៨១. សទ្ទនវកកលាបរូប** សំណុំរូបកើតអំពីឧតុខាងក្រៅ មានសំឡេងជាគម្រប់ ៩ ។

✶. ឧតុជកលាបរូបខាងក្រៅ មានតែ ២ សំណុំ បូកចូលគ្នាបាន ១៧ រូប ដោយសង្ខេបមានត្រឹមរូប ១០ ប៉ុណ្ណោះ គឺ

អវិនិព្ភោគរូប ៨ សទ្ទរូប ១ និង បរិច្ឆេទរូប ១ ចំណែកលក្ខណរូប ៤ រមែងជាប់តាមសភាវរូបទាំងអស់ ប៉ុន្តែដែលយកត្រឹមតែជាតិរូប ២ មកបូកនឹងកម្មជរូបជាដើម ព្រោះទាក់ទងនឹងការកើតឡើងនៃសភាវរូបនោះៗ ដោយអាស្រ័យសមុដ្ឋាននាំឱ្យកើត លុះដល់សភាវរូបទ្រុឌទ្រោម និង បែកធ្លាយ គឺទ្រុឌទ្រោមបែកធ្លាយដោយខ្លួនឯង។

**១៨២. អាហារជកលាបរូប** សំណុំរូបកើតអំពីអាហារ មាន ២ សំណុំ។

**១៨៣. សុទ្ធដ្ឋកកលាបរូប** សំណុំរូបកើតអំពីអាហារ មានអវិនិព្ភោគរូប ៨ គត់។

**១៨៤. លហុតាទិត្រយេកាទសកកលាបរូប** សំណុំរូបកើតអំពីអាហារ មានវិការរូប ៣ ជាគម្រប់ ១១ ។

✶. អាហារជកលាបរូបមាន ២ សំណុំ បូកចូលគ្នាបាន ១៩ រូប ប៉ុន្តែដោយសង្ខេបមានត្រឹមតែ ១២ រូបប៉ុណ្ណោះ គឺ អវិនិព្ភោគរូប ៨ វិការរូប ៣ បរិច្ឆេទរូប ១ ត្រូវជាអាហារជរូប ១៤ ព្រោះបូកជាមួយនឹងជាតិរូប ២ ផង។

**១៨៥. សរុបរូបខាងក្នុងទាំង ៤ សមុដ្ឋាន** ការបូក

សរុបរូបដូច្នេះ ជាការសម្ដែងឱ្យឃើញថា រូបផ្សេងៗគ្នាទៅតាម សំណុំ និង ទៅតាមសមុដ្ឋាន រួមបានជារូបកាយនេះឯង អត់មាន សត្វបុគ្គលតួខ្លួនក្នុងរូបកាយនេះឡើយ។

**១៨៦៚ ចេតនាក្នុងចិត្ត ២៥ ដួង** ជាតួកម្មនាំឱ្យកើត កម្មជរូបក្នុងកាមភព និង ក្នុងរូបភព។

**១៨៧៚ ចិត្ត ៧៥ ដួង** នាំឱ្យកើតចិត្តជរូប ចំណែក ទ្វិបញ្ចវិញ្ញាណ ១០ ដួង អរូបវិបាក ៤ ដួង និង ខណៈបដិសន្ធិ ព្រមទាំងចុតិចិត្តនៃព្រះអរហន្ត មិនញុំាងរូបឱ្យកើតឡើងឡើយ។

**១៨៨៚ ឥន្ទ្រិយរូប ៨** ក្នុងរូប ២៨ មានរូបជាធំក្នុង ការងាររបស់ខ្លួន ៨ រូប គឺ បសាទរូប ៥ ជាធំក្នុងទ្វាររបស់ខ្លួន ឬ ជាធំក្នុងលក្ខណៈនៃការឃើញជាដើម ភាវរូប ២ ជាធំក្នុងភាវៈ របស់ខ្លួន និង ជីវិតិន្ទ្រិយរូបជាធំក្នុងលក្ខណៈតាមរក្សា។

**១៨៩៚ វត្ថុរូប ៦** ក្នុងរូប ២៨ មានរូបជាទីអាស្រ័យ កើតនៃចិត្តចេតសិក ៦ រូប ហៅថាវត្ថុរូប មានក្នុងវត្ថុសង្គហៈ ស្រាប់ហើយ។ កុំច្រឡំថា វត្ថុរូបជាទីអាស្រ័យនៅនៃចិត្តឱ្យសោះ ព្រោះគ្រាន់តែជាទីកើតឬអាស្រ័យកើត (និស្សយប្បច្ច័យ ) ហើយ រលត់ទៅវិញតែប៉ុណ្ណោះ ។

**១៩០. ទ្វាររូប ៧** ក្នុងរូប ២៨ មានរូបជាទ្វារ ៧ រូប គឺ បសាទរូប ៥ ជាទ្វារនៃវិថីចិត្ត ដោយអត្ថថាជាផ្លូវចូល វិញ្ញត្តិរូប ២ ជាទ្វារនៃកាយកម្ម វចីកម្ម និង មនោកម្ម ។

**១៩១. គោចររូប ៧** ក្នុងរូប ២៨ មានរូប ៧ ជាទីគោចរនៃបញ្ចវិញ្ញាណ។ គោចររូប ៧ នេះ ជារូបគ្រោតគ្រាត ប៉ះខ្ទប់នឹងបសាទរូប ជាអារម្មណ៍ប្រាកដច្បាស់ ងាយដឹងជាងរូបដទៃ។ បសាទរូប ៥ ឈ្មោះថាគោចរគ្គាហិករូប គឺរូបប៉ះខ្ទប់នឹងអារម្មណ៍បាន ។

**១៩២. អវិនិព្ភោគរូប ៨** ក្នុងរូប ២៨ មានរូប ៨ ដែលមិនបែកគ្នា ។ នៅក្នុងសំណុំរូបតែងមានអវិនិព្ភោគ ៨ ជានិច្ច ទោះជាសំណុំរូបនោះមានរូបប៉ុន្មានក៏ដោយ ប៉ុន្តែពាក្យថា សុទ្ធដ្ឋកកលាបរូប គឺសំណុំរូបមានត្រឹមរូប ៨ គត់ (៨ សុទ្ធ ) ។

**១៩៣. សនិទស្សនរូប ១** ក្នុងរូប ២៨ មានត្រឹមតែវណ្ណរូប ១ គត់ ដែលគួរដល់ការឃើញ ។

ចក្ខុវិញ្ញាណមានឃើញមនុស្សរាំទេ ?

**១៩៤. សប្បដិឃរូប ១២** ក្នុងរូប ២៨ មានរូប ១២ គឺ បសាទរូប ៥ និង គោចររូប ៧ ឈ្មោះថា **សប្បដិឃរូប** គឺ

រូបគួរដល់ការប៉ះខ្ទប់ បានដល់រូបនិងរូបប៉ះខ្ទប់គ្នា។ រូប ១២ នេះ ឈ្មោះថា **ឱឡារិករូប** គឺរូបគ្រោតគ្រាត ព្រោះងាយដឹងជាងសុខុមរូប ១៦ ។ ម្យ៉ាងទៀត ឈ្មោះថា **សន្តិកេរូប** គឺរូបជិត ព្រោះជារូបដែលមានលក្ខណៈយល់បានងាយ ដោយអត្ថថា កំណត់ជាអារម្មណ៍បានងាយ ( ជិតក្នុងទីនេះពោលដោយលក្ខណៈ មិនពោលដោយឱកាសគឺទីតាំងនោះឡើយ ) ។

**១៩៥~ សភាវរូប ១៨** ក្នុងរូប ២៨ មានរូប ១៨ ដែលមានលក្ខណៈចំពោះខ្លួន គឺជារូបមានលក្ខណៈកើតរលត់ចំពោះខ្លួនឯង ។

**១៩៦~ អជ្ឈត្តិករូប ៥** ក្នុងរូប ២៨ មានរូប ៥ ដែលអាចប៉ះនឹងអារម្មណ៍បាន គឺបសាទរូប ៥ ហ្នឹងឯង ទើបហៅថាជារូបខាងក្នុង (មិនសំដៅត្រង់រូបទាំងអស់ដែលសន្មតថាខ្លួនឯងនោះទេ ) ។

**១៩៧~ មហាភូតរូប ៤** ក្នុងរូប ២៨ មានរូបជាធំ ជាប្រធាន ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ។ មហាភូតរូប ៤ នេះ តែងញុំាងរូប ៤ ទៀតឱ្យកើតរួមជាមួយក្នុងសំណុំរូប គឺពណ៌ ក្លិន រស ឱជា ។ នៅមានឧបាទាយរូបផ្សេងទៀត ដែលអាស្រ័យនឹងមហា-

ភូតរូប ៤ កើតឡើងជាសំណុំៗ មានអាកាសធាតុចែកសំណុំរូប នោះៗ ឱ្យដាច់ចេញពីគ្នា ។ ក្នុងរូបកាយមនុស្សយើងជាដើមនេះ សុទ្ធតែជាកលាបរូប គឺសំណុំរូបទាំងអស់ ។

**១៩៨. អប្បនាជវន័ ៥៨** វៀរមហគ្គតវិបាក ៩ ដួង ចេញ នៅឈានចិត្តទាំងប៉ុន្មានគឺជាអប្បនាជវន័ទាំងអស់។ បើគិត តាមឈានមួយៗ គឺ បឋមជ្ឈានចិត្ត ១០ ដួង ទុតិយជ្ឈានចិត្ត ១០ ដួង តតិយជ្ឈានចិត្ត១០ ដួង ចតុត្ថជ្ឈានចិត្ត១០ ដួង បញ្ចមជ្ឈាន-ចិត្ត ១៨ ដួង។ ចិត្ត ៥៨ ដួងនេះ និង ចេតសិកសម្បយុត្ត សុទ្ធតែ ធ្វើជវនកិច្ចទាំងអស់ ទាំងដែលពួកធម៌នេះនៅក្នុងឈាន មាន បឋមជ្ឈានជាដើម ទើបហៅ ថា អប្បនាជវន័ ។

**១៩៩. ចិត្តកើតក្នុងភព ៣០ ជាន់** វៀរភពអសញ្ញី ចេញ នៅភព ៣០ ជាន់ សុទ្ធតែមានចិត្តទាំងអស់។ សូមពុទ្ធបរិស័ទ សិក្សា និង គិតគូរតាមសប្បាយ ក្នុងភពមួយៗសុទ្ធតែបរមត្ថធម៌ សត្វបុគ្គលគ្រាន់តែសន្មតប៉ុណ្ណោះ ។

**២០០. សរុបចិត្តក្នុងភពផ្សេងៗ** គ្រាន់តែជាការ ប្រមូលមកវិញនូវចិត្តក្នុងភពនីមួយៗប៉ុណ្ណោះ ព្រោះការរៀបរាប់ អំពីចិត្តដែលកើតក្នុងភព ៣០ ជាន់នោះ រួចស្រេចហើយ ។

**២០១~ សរុបចិត្តក្នុងបុគ្គល ៨ ពួក** ជាការសិក្សាពិចារណា ឱ្យឃើញក្នុងបុគ្គលមួយពួកៗ មានចិត្តប៉ុន្មានដួង អ្វីខ្លះ តើចិត្តនោះជាបុគ្គលនោះឬទេ ដូចជាព្រះអរហន្តក្នុងនេវសញ្ញា-នាសញ្ញាយតនភព មានចិត្តត្រឹម ១២ ដួងប៉ុណ្ណោះ តើចិត្តដួងណាជាព្រះអរហន្តនោះ ។

រូបព្រហ្មបុថុជ្ជន មានចិត្ត ៣៩ ដួង ឬ ៤០ ដួង គឺលោកិយ-កុសលចិត្ត ១៧ ដួង អកុសលចិត្ត ១០ ដួង វិបាកចិត្ត ១០ ដួង និងកិរិយាចិត្ត ២ ដួង បើព្រហ្មទុតិយជ្ឈានភូមិវិបាកចិត្ត ១១ ដួង។ ព្រះអរិយបុគ្គល ៣ ពួក មានចិត្ត ៣៥ ដួង ឬ ៣៦ ដួង ព្រោះអកុសលចិត្តមានតែ ៥ ដួង ប៉ុន្តែត្រូវថែមលោកុត្តរផលចិត្ត ១ ដួង តាមព្រះអរិយបុគ្គលនោះៗ ។ ព្រះអរហន្តមានចិត្ត ៣១ ដួង ឬ ៣២ ដួង ព្រោះមិនមានអកុសលចិត្ត មានតែវិបាកចិត្ត ១១ ដួង ក្នុងព្រហ្មទុតិយជ្ឈានភូមិវិបាក ១២ ដួង និង កិរិយាចិត្ត ២០ ដួង។

អរូបព្រហ្មទី ១ បុថុជ្ជនមានចិត្ត ២៤ ដួង គឺ កុសលចិត្ត ១២ ដួង អកុសលចិត្ត ១០ ដួង អរូបវិបាកចិត្ត ១ ដួង និង មនោ-ទ្វារាវជ្ជនចិត្ត ១ ដួង។ ព្រះអរិយបុគ្គល ៣ ពួក មានចិត្ត ២០ ដួង ព្រោះត្រូវវៀរអកុសលចិត្ត ៥ ដួង ថែមលោកុត្តរផលចិត្ត ១ ដួង។ ព្រះអរហន្តមានចិត្ត ១៥ ដួង គឺ កិរិយាចិត្ត ១៣ ដួង អរូបវិបាកចិត្ត

១ ដួង និង អរហត្តផលចិត្ត ១ ដួង។ តទៅអរូបព្រហ្មជាន់លើៗ ត្រូវដកអរូបកុសល ឬ អរូបកិរិយាមួយៗ ជាបន្តបន្ទាប់ ចំណែក អរូបវិបាកមានតាមភពរបស់ខ្លួន ។

**២០២~ ចិត្តនិយាម** ជាទំនៀមរបស់ចិត្ត ដែលប្រព្រឹត្ត ទៅម្តង ឬប៉ុន្មានដង អត់មានអ្វីបង្គាប់បញ្ជាឡើយ។ ចិត្តនិយាម នេះតាម **គម្ពីរថេរវាទ** ។

**២០៣~ ចិត្ត ១៩ ដួង** មិនដែលកើត ២ ខណៈជាប់ គ្នាទេ បើអរិយមគ្គ ៤ ដួងវិញ កើតតែម្តងគត់ក្នុងសង្សារវដ្ត។

**២០៤~ សោមនស្សសន្តីរណចិត្ត** ម្តងដោយសន្តីរណកិច្ច និង ពីរដងដោយតទាលម្ពណកិច្ច ។

**២០៥~ ទោដ្ឋព្វនៈ** ម្តងព្រោះអារម្មណ៍ធំ ឬធំដ៏ក្រៃលែង និង ពីរ ឬ បីដងព្រោះបរិត្តារម្មណ៍ ។

**២០៦~ ចិត្ត ២៥ ដួង** មហគ្គតវិបាកចិត្ត ៩ ដួង ប្រព្រឹត្តទៅអស់វារៈម្តងដោយបដិសន្ធិកិច្ច និង ចុតិកិច្ច ច្រើនដង ព្រោះភវង្គកិច្ច ។ នៅអប្បនាជវ័ន ១៦ ដួងទៀត ម្តងព្រោះ អាទិកម្មិកឈានវិថី និង ច្រើនដងព្រោះឈានសមាបត្តិ។

**២០៧~ ចិត្ត ១០ ដួង** គឺ មហាវិបាកចិត្ត ៨ ដួង

ប្រព្រឹត្តទៅអស់វារៈម្ដងព្រោះបដិសន្ធិកិច្ច និងចុតិកិច្ច ពីរដងព្រោះតទាលម្ពណកិច្ច ច្រើនដងព្រោះភវង្គកិច្ច។ ឧបេក្ខាសន្តីរណចិត្ត ២ ដួង ម្ដងព្រោះបដិសន្ធិកិច្ច ចុតិកិច្ច និង សន្តីរណកិច្ច ពីរដងព្រោះតទាលម្ពណកិច្ច និង ច្រើនដងព្រោះភវង្គកិច្ច ។

**២០៨~ ហសិតុប្បាទចិត្ត** កាមជវ័ន ៧ ខណៈជាប្រក្រតី។

**២០៩~ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ ដួង** ៦ ដងមុនសន្លប់ និង ៧ ដងជាប្រក្រតី ។

**២១០~ ចិត្ត ១៦ ដួង** ប្រព្រឹត្តទៅអស់វារៈ ៥ ដងមុនស្លាប់ ៦ ដងមុនសន្លប់ ៧ ដងជាប្រក្រតី ។

**២១១~ ចិត្ត ៨ ដួង** មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ប្រព្រឹត្តទៅអស់វារៈ ៣ ដង ក្នុងខាងដើមនៃមគ្គវិថី អាទិកម្មិកឈានវិថី ផលសមាបត្តិវិថី ឈានសមាបត្តិវិថី អភិញ្ញាវិថី និងនិរោធសមាបត្តិវិថី នៃតិក្ខបុគ្គល (បុគ្គលរហ័ស ) បើកើត ៤ ដងក្នុងមន្ទបុគ្គល (បុគ្គលយឺត ) ។

មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ប្រព្រឹត្តទៅអស់វារៈ ៣ ដងក្នុងខាងដើមនៃអាទិកម្មិកឈានវិថី អរហត្តផលសមាបត្តិវិថី ។ល។ នៃតិក្ខបុគ្គល (វៀរមគ្គវិថី ) ។ ប្រព្រឹត្តទៅ ៤ ដង

សម្រាប់មន្ទបុគ្គល និង ក្នុងបច្ចវេក្ខណវិថីរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងខណៈដែលព្រះអង្គសម្តែងយមកប្បាដិហារ្យជាដើម ។

ចិត្តទាំង ៨ ដួងនេះ ប្រព្រឹត្តទៅ ៥ ដងមុនពេលស្លាប់ ឬ បរិនិព្វាន ៦ ដងមុនសន្ទប់ និង ៧ ដងជាប្រក្រតី ។

**២១២. ចិត្ត ២ ដួង** ប្រព្រឹត្តទៅអស់វារៈពីរដងក្នុងមគ្គវិថីនៃមន្ទបុគ្គល ៣ ដងក្នុងមគ្គវិថីនៃតិក្ខបុគ្គល និង ច្រើនដងក្នុងផលសមាបត្តិវិថី ។

**២១៣. ចិត្ត ៤ ដួង** អរូប ២ ដួង ប្រព្រឹត្តទៅអស់វារៈម្តងដោយអាទិកម្មិកឈានវិថី ពីរ ឬ បីដងក្នុងនិរោធសមាបត្តិ-វិថី និង ច្រើនដងក្នុងឈានសមាបត្តិ ។

ចំណែកលោកុត្តរផលចិត្ត ២ ដួងថ្នាក់លើ កើតម្តងពេលចេញពីនិរោធសមាបត្តិ ពីរដងក្នុងមគ្គវិថីនៃមន្ទបុគ្គល ៣ ដងក្នុងមគ្គវិថីនៃតិក្ខបុគ្គល និង ច្រើនដងក្នុងផលសមាបត្តិវិថី ។

✶. ក្នុងចិត្តនិយាមនេះ កាលពុទ្ធបរិស័ទសិក្សាឃើញខុសគ្នាពីគម្ពីរដទៃហើយ សូមឱ្យខុសគ្នាតែគម្ពីរចុះ ព្រោះយើងគិតមិនដឹងឡើយចំពោះខណៈចិត្តល្អិតល្អន់យ៉ាងនេះ ។

**២១៤. តិកមាតិកា ២២** មានតិកវិមុត្តិ ៩ គឺ

(១). **តិកមាតិកា ទី២** មានតិកវិមុត្តិ បានដល់វេទនា-ចេតសិកក្នុងចិត្ត ១២១ ដួង រូប ២៨ និង ព្រះនិព្វាន ។

(២). **តិកមាតិកា ទី៦** មានតិកវិមុត្តិ បានដល់វិចារ-ចេតសិកក្នុងសវិតក្កសវិចារចិត្ត ៥៥ ដួង ។

(៣). **តិកមាតិកា ទី៧** មានតិកវិមុត្តិ បានដល់ទុក្ខសហ-គតចិត្ត ៣ ដួង ចេតសិកសម្បយុត្ត ២២ ។ សុខវេទនាចេតសិក ១២ គឺក្នុងកាយវិញ្ញាណ ១ ដួង និង ក្នុងចតុត្ថជ្ឈានចិត្ត ១១ ដួង។ ឧបេក្ខាវេទនាក្នុងចិត្ត ៥៥ ដួង ។ រូប ២៨ និង ព្រះនិព្វាន ។

(៤). **តិកមាតិកា ទី១៣** មានតិកវិមុត្តិ បានដល់ចិត្ត ២១ ដួង ចេតសិក ៣៥ ដែលមានបញ្ញត្តិជាអារម្មណ៍ជាឯកន្តៈ។ មនោ-ទ្វារាវជ្ជនចិត្ត១ ដួង កាមជវ័ន២៨ (វៀរហសិតុប្បាទចិត្ត) អភិញ្ញា ២ ដួង ចេតសិក ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) ដែលមានបញ្ញត្តិជាអារម្មណ៍ជាអនេកន្តៈ ។ អប្បមញ្ញា ២ មានបញ្ញត្តិជាអារម្មណ៍ជាឯកន្តៈ។ រូប ២៨ និង ព្រះនិព្វានមិនមានអារម្មណ៍ ។

(៥). **តិកមាតិកា ទី១៦** មានតិកវិមុត្តិ បានដល់ចិត្ត ៧៦ ដួង (វៀរមនោទ្វារាវជ្ជនចិត្ត ១ ដួង មហាកុសល និងមហាកិរិយា-ញាណសម្បយុត្តចិត្ត ៨ ដួង អភិញ្ញា ២ ដួង និង មគ្គចិត្ត ៤ ដួង)

ចេតសិក ៥២ ដែលមិនមានមគ្គជាអារម្មណ៍ ជាឯកន្តៈ ។ សូម្បី មនោទ្វារាវជ្ជនចិត្ត ១ ដួង មហាកុសល និង មហាកិរិយាញាណ-សម្បយុត្តចិត្ត ៨ ដួង អភិញ្ញា ២ ដួង ចេតសិក ៣៣ (វៀរវិរតិ ៣ អប្បមញ្ញា ២) ដែលមិនមានមគ្គជាអារម្មណ៍ក៏ជា តិកវិមុត្តិ ដែរ ដោយអនេកន្តៈ រីឯវិរតិ ៣ និង អប្បមញ្ញា ២ មិនមានមគ្គជា អារម្មណ៍ជាឯកន្តៈ។

✶. មនោទ្វារាវជ្ជនចិត្ត មិនមានមគ្គជាអារម្មណាធិបតីទេ ព្រោះជាអហេតុកចិត្ត ដូចក្មេងតូចដែលមិនចេះគោរពព្រះរាជា ។ ចំណែកអភិញ្ញា ២ ដួងក៏មិនមានមគ្គជាអារម្មណាធិបតីដែរ ព្រោះជាមហគ្គតចិត្ត ប្រៀបដូចជាព្រះមាតាបិតានៃព្រះរាជា ដែលមិនថ្វាយបង្គំព្រះរាជា ដូច្នោះឯង ។

✶. មានតែមគ្គចិត្តុប្បាទ ៤ ដួង ប៉ុណ្ណោះ ដែលមានមគ្គជាហេតុ និង មានមគ្គជាអធិបតី ជាឯកន្តៈ ។

(៦). **តិកមាតិកា ទី១៧** មានតែព្រះនិព្វានប៉ុណ្ណោះ ជាតិកវិមុត្តិ ព្រោះព្រះនិព្វាន មិនមែនជាធម៌កើតឡើងហើយ មិនមែនជាធម៌មិនទាន់កើតឡើង និង មិនមែនជាធម៌ប្រុងនឹងកើតឡើងឡើយ គឺព្រះនិព្វានជាការរលត់ទុក្ខទាំងពួង ។

(៧)_ **តិកមាតិកា ទី១៨** មានតែព្រះនិព្វានប៉ុណ្ណោះ ជា តិកវិមុត្តិ ចំណែកសង្ខតធម៌ទាំងអស់ សុទ្ធតែប្រព្រឹត្តទៅក្នុងកាលទាំង ៣ ។

(៨)_ **តិកមាតិកា ទី១៩** ចិត្តចេតសិកដែលមានបញ្ញត្តិ និង ព្រះនិព្វានជាអារម្មណ៍ទាំងអស់ សុទ្ធតែជា តិកវិមុត្តិ ជា ឯកន្តៈក៏មាន ជាអនេកន្តៈក៏មាន ។

រូប និង ព្រះនិព្វាន ជា **អនារម្មណា ធម្មា** ពួកធម៌មិនមានអារម្មណ៍ ។

(៩)_ **តិកមាតិកា ទី២១** មានតិកវិមុត្តិ គឺ

_ **នត្ថិភាវបញ្ញត្តារម្មណឯកន្តៈ** បានដល់ អាកិញ្ចញ្ញាយតនចិត្ត ៣ ដួង ចេតសិក ៣០ ។

_ **នត្ថិភាវបញ្ញត្តារម្មណអនេកន្តៈ** បានដល់ មនោទ្វារាវជ្ជនចិត្ត ១ ដួង កាមជវន៍ ២៨ ដួង (វៀរហសិតុប្បាទចិត្ត) អភិញ្ញា ២ ដួង ចេតសិក ៤៥ (វៀរវិរតិ ៣ អប្បមញ្ញា ២ ឥស្សា មច្ឆរិយៈ) ។

រូប និង ព្រះនិព្វាន ជា **អនារម្មណា ធម្មា** ពួកធម៌មិនមានអារម្មណ៍ ។

# ឧទ្ទិសវាចា

សូមឧទ្ទិសធម្មទាន **អភិធម្មកថា** នេះ ដល់សព្វសត្វ មនុស្ស
ទេវតាទាំងអស់ សូមមានចិត្តសោមនស្ស ត្រេកអរ អនុមោទនា ។

**សាធុ ! សាធុ ! សាធុ !**

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការងារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក ទូច គីមស្រ៊ាង |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូជា | ២០. ឧបាសិកា ហាយច័ន្ទធរី |
| ២១. ឧបាសក អ៊ឹម រ៉ែយ៉ា | ២២. ឧបាសក ហាន សីហៈ |

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- ឧ.ស.យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម + បុត្រ ........... ស.រ.អ.
២- ឧ.ស.ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសៃ + បុត្រ ......... ស.រ.អ.
៣- ឧ.ស.ឆាយអ៊ីវ ស្រេងលីម និង ឧ.សិ.ហួត ឃីម+បុត្រ ...... ស.រ.អ.
៤- ឧ.ស.ហៃ ប៊ុនណារិន និង ឧ.សិ.អោង ស៊ីថាន់+បុត្រ ........... ស.រ.អ.
៥- ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ .. ស.រ.អ.
៦- ឧ.សិ.ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ ...................... ស.រ.អ.
៧- ឧ.សិ.ប៊ិត ថងខាំ និង ឧ.សិ.សាន ផល្លីន ព្រមទាំងបុត្រ+ចៅ. ស.រ.អ.
៨- ឧ.សិ.ស៊ីវ យក់លុយ ព្រមទាំងបុត្រ និងចៅ .................... ស.រ.អ.
៩- ឧ.សិ.អ៊ឹង ស៊ីវន ព្រមទាំងបុត្រ និងចៅ .......................... ស.រ.អ.
១០- ឧ.ស.ស៊ូ ហុកឡុង និង ឧ.សិ.តាន់ ឈីវហា ព្រមទាំងបុត្រ. ស.រ.អ.
១១- ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . ស.រ.អ.
១២- ឧ.សិ.តែ សាយជូ ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.
១៣- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ +ចៅ ..... ស.រ.អ.
១៤- ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ ............................ ស.រ.អ.
១៥- ឧ.ស.ឆេង សារឿន ឧ.សិ.ជុំ លាភ+ឧ.ស.ហ៊ីស៊ី ឧ.សិ.អាន . ស.រ.អ.
១៦- លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ ព្រមទាំងបុត្រ .. ស.រ.អ.
១៧- លោកយាយ ពិន សាត ព្រមទាំងបុត្រ និងចៅ............... ស.រ.អ.
១៨- លោក ចាន់ ម៉ល់ និង អ្នកស្រី ជា សុផា ព្រមទាំងបុត្រ...... ស.រ.អ.
១៩- ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ព្រមទាំងបុត្រ .. ស.រ.អ.
២០- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ............................................... ស.រ.អ.

២១- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ ស.រ.អ.

២២- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... ស.រ.អ.

២៣- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. ស.រ.អ.

២៤- ឧ.សិ.ស្រង់ អែ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ ស.រ.អ.

២៥- ឧ.ស.វ៉ាង សាវុធ និង ឧ.សិ.គង់ ស៊ីណាត ព្រមទាំងបុត្រ .. ស.រ.អ.

២៦- ភិក្ខុ ឈួម បូ ( វត្តពន្លឺពុទ្ធចក្រ លោវែល ) ................... ស.រ.អ.

២៧- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................ ស.រ.អ.

២៨- លោកគ្រូធម្មបណ្ឌិត អឿ សៅ ................................. ស.រ.អ.

២៩- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង វិទ្ធារី ព្រមទាំងបុត្រ ...... ស.រ.អ.

៣០- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា +បុត្រ ..... ស.រ.អ.

៣១- ឧ.សិ.ឡុង អ៊ុម ព្រមទាំងបុត្រ និងចៅ ....................... ស.រ.អ.

៣២- ឧ.ស.សំណាង យឹម និង ឧ.សិ.ឡូរ៉ា យឹម ព្រមទាំងបុត្រ ... ស.រ.អ.

៣៣- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... ស.រ.អ.

៣៤- ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.វូច អ៊ុម ព្រមទាំងបុត្រ ..... ស.រ.អ.

៣៥- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងបុត្រ+ចៅ... ស.រ.អ.

៣៦- ឧ.សិ.តាំង លេខគៀវ ព្រមទាំងបុត្រ និងចៅ ................ ស.រ.អ.

៣៧- ឧ.សិ.នួន ប៊ិច និង ឧ.សិ.រស់ សុផល ព្រមទាំងបុត្រ+ចៅ... ស.រ.អ.

៣៨- ឧ.ស.ហោ លាន និង ឧ.សិ.អ៊ឹង អូន +ឧ.សិ.អុន ញ៉ ........ ស.រ.អ.

៣៩- ឧ.ស.អ៊ុន នៃត្រី និង ភរិយា ព្រមទាំងបុត្រ .................. ស.រ.អ.

៤០- ឧ.សិ.មិល យ៉ែម និង ឧ.សិ.គួយ ឡេង ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៤១- ឧ.សិ.ហុក ឈិន និង ឧ.សិ.ប្រាក់ អៀត ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៤២- ឧ.សិ.ប៉ាន់ ពិណ្ណារី និង ស្វាមី ព្រមទាំងបុត្រ និងចៅ ........ ស.រ.អ.

៤៣- ឧ.សិ.ស៊ុន ឡេង ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.

៤៤- លោក សួន សាលាភ និង អ្នកស្រី សួ សកនីន ព្រមទាំងបុត្រ ស.រ.អ.

៤៥- ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ ស.រ.អ.
៤៦- ឧ.សិ.ឈ គឹមហោ ព្រមទាំងបុត្រ និងចៅ ..................... ស.រ.អ.
៤៧- ឧ.សិ.ឡាំង គឹមឆេង ព្រមទាំងបុត្រ ........................... ស.រ.អ.
៤៨- ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ ស.រ.អ.
៤៩- ឧ.សិ.លឹម សុខុម ព្រមទាំងបុត្រ ................................ ស.រ.អ.
៥០- ឧ.ស.ពឹង សេងគី និង ឧ.សិ.អ៊ឹង ធឿម ព្រមទាំងបុត្រ+ចៅ ស.រ.អ.
៥១- ឧ.សិ.ប៉ាន សារិទ្ធ ( ហៅង៉ា ) ព្រមទាំងបុត្រ និងចៅ ....... ស.រ.អ.
៥២- ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.
៥៣- ឧ.សិ.រស់ លីណា និង ឧ.សិ.នឹម វណ្ណី ព្រមទាំងកូនចៅ .... ស.រ.អ.
៥៤- ឧ.សិ.ទូច ផានី និង ស្វាមីLeslie Mael ព្រមទាំងបុត្រ . ស.រ.អ.
៥៥- ឧ.សិ.ទីន ឈីវ ព្រមទាំងបុត្រ និងចៅ ........................ ស.រ.អ.
៥៦- ភិក្ខុ ឡូញ ផល្លី និង ភិក្ខុ ភឿក បូរ ............................. អូស្ត្រាលី
៥៧- ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ .......... អូស្ត្រាលី
៥៨- ឧ.សិ.ឱម លក្ខណា ព្រមទាំងបុត្រធីតា ........................ អូស្ត្រាលី
៥៩- ឧ.ស.លឹម ងីនសួ និង ឧ.សិ. អ៊ឹង ឆាយហួ +បុត្រ. .......... អូស្ត្រាលី
៦០- ឧ.ស.ប៉ុច វឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. អូស្ត្រាលី
៦១- ឧ.សិ.ឈ គឹមស៊ីន និង ក្រុមគ្រួសារកូនចៅ .................. អូស្ត្រាលី
៦២- ឧ.សិ.សេង សៀងឈុន ព្រមទាំងបុត្រ និងចៅ ............. អូស្ត្រាលី
៦៣- ឧ.សិ.ស៊ិត ស៊ីវ៉ន ព្រមទាំងបុត្រ និងចៅ ..................... អូស្ត្រាលី
៦៤- ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ ................................. អូស្ត្រាលី
៦៥- ឧ.សិ.ស៊ុយ គឹមស៊ាន និងកូនស្រី សេង ផល្លា ................ អូស្ត្រាលី
៦៦- កញ្ញា ស៊ុយ ដាណែត ................................................ អូស្ត្រាលី
៦៧- កញ្ញា គា ដារ៉ា ( ហៅ ស្រីណេ ) ............................... អូស្ត្រាលី
៦៨- យុវជន ចាន់ ឌីណា ................................................ អូស្ត្រាលី

៦៩- ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. អូស្ត្រាលី

៧០- ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... អូស្ត្រាលី

៧១- ឧ.ស.សរ ប៊ុនធៀង ព្រមទាំងបុត្រ និងចៅ.................. អូស្ត្រាលី

៧២- លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ អូស្ត្រាលី

៧៣- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . អូស្ត្រាលី

៧៤- ឧ.ស.ង៉ូវ ឃីវ និង ឧ.សិ.ហេង ពាស៊ីម ព្រមទាំងបុត្រ+ចៅ អូស្ត្រាលី

៧៥- ឧ.ស.ឃិន ថុងអ៊ាន និង ឧ.សិ.ម៉េង គិមស៊ាន ព្រមទាំងបុត្រ. អូស្ត្រាលី

៧៦- ឧ.ស.សុខ សារឿន និង ឧ.សិ.មោក មី ព្រមទាំងបុត្រ...... អូស្ត្រាលី

៧៧- ឧ.ស. លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី ព្រមទាំងបុត្រ... អូស្ត្រាលី

៧៨- ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... អូស្ត្រាលី

៧៩- ឧ.សិ.ម៉េង ប៊ុន្នារី ( ហៅស្រីពៅ ) និង ស្វាមី ព្រមទាំងបុត្រ. អូស្ត្រាលី

៨០- ឧ.សិ.ជា ឡេង ព្រមទាំងបុត្រ .................................. អូស្ត្រាលី

៨១- ឧ.ស.សាប់ ភូរិន្ទ .................................................... អូស្ត្រាលី

៨២- ឧ.ស.ស៊ូ ឃីម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ+ចៅ.. អូស្ត្រាលី

៨៣- លោក ឃឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ........ អូស្ត្រាលី

៨៤- ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ........ អូស្ត្រាលី

៨៥- លោក ញាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ អូស្ត្រាលី

៨៦- ឧ.ស.ដែន គង់ហួត និង ឧ.សិ.កាំង គឹមស៊ុន ព្រមទាំងបុត្រ អូស្ត្រាលី

៨៧- ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. អូស្ត្រាលី

៨៨- ឧ.ស.កាំង ប៉េងជីវ និង ឧ.សិ.លឹម អ៊ីហ៊ាម + កូនចៅ ..... អូស្ត្រាលី

៨៩- ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់ រិទ្ធ ព្រមទាំងបុត្រ ........... អូស្ត្រាលី

៩០- ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ....................... អូស្ត្រាលី

៩១- ឧ.សិ.លឹម ស៊ូឆេង ................................................ អូស្ត្រាលី

៩២- ឧ.សិ.ជូរ រ៉េន ........................................................ អូស្ត្រាលី

| | | |
|---|---|---|
| ៩៣- | ឧ.ស.ឡុង ហ៊ន និង ឧ.សិ.លិម យូរអេង ..................... | អូស្ត្រាលី |
| ៩៤- | ព្រឹទ្ធាចារ្យ សេង ទូច ព្រមទាំងបុត្រ និងចៅ ................. | អូស្ត្រាលី |
| ៩៥- | ឧ.ស.ស៊ីវ សៀងថៃ និង ឧ.សិ.ឯក សុកហាក់ +បុត្រ ...... | អូស្ត្រាលី |
| ៩៦- | លោក យូណូស អាស៊ីស  និង អ្នកស្រី ហុក ណារី+បុត្រ ... | បារាំង |
| ៩៧- | ឧ.ស.ង៉ូវ ជូនណារេត ឧ.សិ.ង៉ូវ សោភ័ណ ព្រមទាំងបុត្រ... | បារាំង |
| ៩៨- | ឧ.ស.ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ........... | បារាំង |
| ៩៩- | ឧ.ស.ជីន ជុង និងភរិយា.......................................... | បារាំង |
| ១០០- | ឧ.ស.ឡោ សេងជ្រុន និង ឧ.សិ.ផាំង លី កូនចៅ .......... | បារាំង |
| ១០១- | ឧ.ស.ហ្វាន់ វ៉ាន់ហួ និង ឧ.សិ.ហ្វាន់ យូលាង ព្រមទាំងបុត្រ | បារាំង |
| ១០២- | ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ ............... | បារាំង |
| ១០៣- | ឧ.សិ.ទាវ គីមហ៊ួន ព្រមទាំងកូនចៅ ......................... | បារាំង |
| ១០៤- | ឧ.សិ.ដៀប រុន ព្រមទាំងបុត្រធីតា .......................... | បារាំង |
| ១០៥- | ឧ.ស.បាន ណារិន និង ឧ.សិ.ហោ ចន្ទូ ព្រមទាំងបុត្រ .... | បារាំង |
| ១០៦- | ឧ.សិ.អ៊ឹង ហ្គេចតេង ព្រមទាំងបុត្រ  ........................ | បារាំង |
| ១០៧- | ឧ.សិ.អ៊ឹង យ៉េកសាង ព្រមទាំងបុត្រ ........................ | បារាំង |
| ១០៨- | ឧ.សិ.គឹម ហួយ ព្រមទាំងបុត្រ និងចៅ ..................... | បារាំង |
| ១០៩- | ឧ.សិ.ហែម ពៅ ព្រមទាំងបុត្រ ............................... | បារាំង |
| ១១០- | ឧ.សិ.ង៉ែត យ៉េន ព្រមទាំងបុត្រ និងចៅ .................. | បារាំង |
| ១១១- | ឧ.ស.ប៊ុន ឈឹម និង ឧ.សិ.គី គីមលាង ព្រមទាំងបុត្រ .. | បារាំង |
| ១១២- | ឧ.សិ.ឆាយ ស៊ន ព្រមទាំងបុត្រ និងចៅ+ចៅទួត......... | កាណាដា |
| ១១៣- | ឧ.ស.ពុធ ប៉ោលាង និង ឧ.សិ.ហ៊ុន ស៊ីវអៀង+កូនចៅ . | កាណាដា |
| ១១៤- | Chhem Sokreth.Puth Kunthea+Rothmony+Bunnawat.. | កាណាដា |
| ១១៥- | Su Sokunora et Inn Visal+Narita et Raksa ..... | កាណាដា |
| ១១៦- | ឧ.សិ.អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ  .................... | កាណាដា |

| | | |
|---|---|---|
| ១១៧- | ឧ.សិ.ចំណាន ព្រមទាំងក្រុមគ្រួសារ ........................ | កាណាដា |
| ១១៨- | ឧ.សិ. លី វ៉ន ព្រមទាំងក្រុមគ្រួសារ ........................ | កាណាដា |
| ១១៩- | ឧ.ស.ឡាវ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន+បុត្រ .. | កាណាដា |
| ១២០- | កូនចៅរបស់ ឧ.សិ.លាន ម៉ិច ................................ | កាណាដា |
| ១២១- | ឧ.សិ.តាន់ វួចឆាយ .......................................... | កាណាដា |
| ១២២- | ឧ.សិ.អ៊ាប គិមអ៊ីន ព្រមទាំងបងប្អូនកូនចៅ ............ | កាណាដា |
| ១២៣- | ឧ.សិ.ត្រា វ៉ាន្នី និង ឧ.ស.ត្រា ពិសារ ............................ | ស្វីស |
| ១២៤- | ឧ.សិ.កាំង ប៉ោទាង និង ឧ.ស.ហេ អេន +កូនចៅ ....... | ភ.ព. |
| ១២៥- | ឧ.សិ.ខៀវ វុត្ថា (ហៅមុំ)................................... | ភ.ព. |
| ១២៦- | ឧ.សិ.គង់ ម៉ៃ ព្រមទាំងបុត្រ និងចៅ ........................ | ភ.ព. |
| ១២៧- | ឧ.ស.គង់ សៀងហៃ និង ឧ.សិ.ប៉ក់ សូត្រតារាភិឱន+បុត្រ | ភ.ព. |
| ១២៨- | ឧ.ស.គង់ ហេង និង ឧ.សិ.ធាវ ស៊ីប ព្រមទាំងកូនចៅ .. | ភ.ព. |
| ១២៩- | ឧ.សិ.គឹម សុខុន ព្រមទាំងបុត្រ និងចៅ ................... | ភ.ព. |
| ១៣០- | ឧ.សិ.គឹម ឆេង ព្រមទាំងកូនចៅ ........................... | ភ.ព. |
| ១៣១- | ឧ.សិ.គ្រី ណៃប៊ួយ ព្រមទាំងបុត្រ ........................... | ភ.ព. |
| ១៣២- | ឧ.សិ.ឃុត គឹមថន+លោក ប្រាក់ខេមរិទ្ធ និងភរិយា ..... | ភ.ព. |
| ១៣៣- | ឧ.ស.ឃ្លោក យិត និងពុទ្ធបរិស័ទខេត្តព្រះសីហនុ ........ | ក.ព.ស. |
| ១៣៤- | ឧ.ស.ងីម ញាណ និង ឧ.សិ.កាំង ប៉ូលីន ព្រមទាំងបុត្រ . | ភ.ព. |
| ១៣៥- | ឧ.ស.ង៉ែត ផេង និង ឧ.សិ.ហៅ ហេង+បុត្រ ផេង បូរ៉ា . | ភ.ព. |
| ១៣៦- | ឧ.ស.ង៉ូវ គា និង ឧ.សិ.ឈុន គឹមអេង ព្រមទាំងបុត្រ ... | ប.ប. |
| ១៣៧- | ឯ.ឧ.កាន់ វ៉ាត់ និង ឧ.សិ.កែវ កល្យាណ+ក.កាន់សុថារ័ត្ន | ភ.ព. |
| ១៣៨- | ឯ.ឧ.ចែម វីឡ៉ា និង លោកជំទាវ សុខា ស៊ូលីវណ្ណ+បុត្រ. | ភ.ព. |
| ១៣៩- | ឯ.ឧ.ធ្នាំ (ធម្ម)ប៊ុនស្រុន លោកជំទាវ យ៉ែម សួស្តី+បុត្រ. | ភ.ព. |
| ១៤០- | ឯ.ឧ.ស្បោង សារ៉ាត់ និង លោកជំទាវ ស៊ាន ឈុនហេង+បុត្រ | ក.ព.ស. |

| | | |
|---|---|---|
| ១៤១- | ឯ.ឧ.អ៊ិត ប្រាំង និង លោកជំទាវ ញ៉ែម សេដ្ឋា+បុត្រចៅ | ភ.ព. |
| ១៤២- | ឯ.ឧ.ឯម ប៊ុនសាត និង លោកជំទាវ នូ ចន្ធា ព្រមទាំងបុត្រ | ភ.ព. |
| ១៤៣- | ឯ.ឧ.ឧកញ៉ា ទុយ គី និង លោកជំទាវ កង វុទ្ធា ( ស្រីម៉ៅ) | ភ.ព. |
| ១៤៤- | ឧកញ៉ា ស៊ិន សុខា និង លោកជំទាវ សុខា ផល្លី +បុត្រ+ចៅ | ភ.ព. |
| ១៤៥- | ឧកញ៉ា សេង ឆាយអ៊្វរ និង ឧ.សិ.កាំង ហ្គិចណៃ+បុត្រ+ចៅ | ភ.ព. |
| ១៤៦- | ឧកញ៉ា សុខ សុខា និង លោកជំទាវ ចាន់ លាង+បុត្រ ... | ភ.ព. |
| ១៤៧- | ឧ.សិ.ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា ...................... | ភ.ព. |
| ១៤៨- | ឧ.សិ.ច័ន្ទ ណារឿន+ឪពុក ច័ន្ទ ឆឹង និងម្ដាយ មួង ភី ..... | ភ.ព. |
| ១៤៩- | ឧ.ស.ច័ន្ទ សុខុម និង ឧ.សិ.គឹម ចន្ធា ព្រមទាំងកូនចៅ ... | ភ.ព. |
| ១៥០- | ឧ.ស.ចាន់ យូរ៉ាន់ និង ឧ.សិ.ពត សារ៉ាន់ +បុត្រ .......... | ភ.ព. |
| ១៥១- | ឧ.សិ.ចាន់ សុស ( ហៅ សាម៉េត ) ព្រមទាំងបុត្រ ....... | ភ.ព. |
| ១៥២- | ឧ.សិ.ច្រឹង គីមស្រ៊ុ ព្រមទាំងបុត្រ ........................... | ភ.ព. |
| ១៥៣- | យុវជន ជា សុភ័ក្រ្ត និងមាតាបិតា ............................ | ភ.ព. |
| ១៥៤- | ឧ.សិ.ជា សុណារី និងក្មួយស្រី ជា សុមេធាធីតា ........... | ភ.ព. |
| ១៥៥- | លោក ជា សារ៉ាយ និង អ្នកស្រី អ៊ុំ សុផានី +បុត្រ+ចៅ. | ភ.ព. |
| ១៥៦- | ឧ.ស.ជា សុខុម និង ឧ.សិ.អ៊ុន ពូន ព្រមទាំងបុត្រ ....... | ភ.ព. |
| ១៥៧- | ឧ.សិ.ជា ស៊ីវយ៉េក+ឧ.សិ.ហេងមួយចេង+ហេងមួយឡាង | ភ.ព. |
| ១៥៨- | ឧ.ស.ជាន យ៉ែត និង ឧ.សិ.សុក ចេង ព្រមទាំងបុត្រ ..... | ភ.ព. |
| ១៥៩- | ឧ.សិ.ជិន ហូ ព្រមទាំងកូនចៅ ................................ | ភ.ព. |
| ១៦០- | លោកស្រី ជីវ គីមឆេង និង ឧ.សិ.ជីវ យ៉ា .................. | ប.ប. |
| ១៦១- | ឧ.សិ.ជូ ឆេងហោ .............................................. | ភ.ព. |
| ១៦២- | ឧ.សិ.ជុំ ស៊ីម៉ុន និងបុត្រ ពេជ្រ សុឃុន ...................... | ភ.ព. |
